# ទស្សនាវដ្ដីកសិកម្ម

# THE AGRICULTURE MAGAZINE



ឆ្នាំទី ១២ ត្រីមាសទី ៤ (តុលា-ធ្នូ) ឆ្នាំ ២០១៣ លេខ ៤៨

[illegible]
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh

# មាតិកា ទំព័រ


- លិខិតសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........០១
- ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីទិវាស្បៀងអាហារពិភពលោក ឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា...........០២
- សមិទ្ធផលសំខាន់ៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់សន្តិសុខស្បៀង និងកំណើនសេដ្ឋកិច្ច ចីរភាព ការអភិវឌ្ឍន៍..........................................................................០៨
- មតិសំណេះសំណាលលោកជំទាវ **ហោ ម៉ាលីន** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីប្រកាសក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ..................................................១៧
- ផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង ក្នុងបរិបទប្រែប្រួលអាកាសធាតុ វេទិកាកសិករថ្នាក់ជាតិលើកទី៤ ..........................................................................................................២១
- ដំណាំត្រសក់..........................................................................................................២៨
- បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ.................................................................................៣៦
- បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ..............................................................................៤៨
- បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ..............................................................................៥៨
- ជំងឺប្រផេះសលើស្លឹកកៅស៊ូ...........................................................................................៦៨
- សារាចរណែនាំស្តីពីផែនការជំរុញការស្តារឡើងវិញការខូចខាតដោយគ្រោះទឹកជំនន់រដូវវស្សាឆ្នាំ២០១៣....................................................................................................៧២
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..................................................៧៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ផ្ញើជូន**

ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ឯកឧត្តម ជាទីស្រឡាញ់រាប់អាន

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណប្រកបដោយក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ចំពោះឯកឧត្តម និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ព្រមទាំងនិយោជិតទាំងអស់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលបានសម្តែងនូវការអបអរសាទរ ជូនពរសព្ទសាធុការពរចំពោះរូបខ្ញុំ ក្នុងឱកាស **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទាន ត្រាស់បង្គាប់តែងតាំងរូបខ្ញុំ ធ្វើជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់នីតិកាល ទី ៥ នៃរដ្ឋសភា នាពេលថ្មីៗនេះ ។

តបចំពោះសមានចិត្ត និងពាក្យពេចន៍ពរជ័យដ៏មានអត្ថន័យទូលំទូលាយប្រពៃថ្លៃថ្លា សរសើរលើកទឹកចិត្តចំពោះរូបខ្ញុំ ។ ជាថ្មីម្តងទៀត ខ្ញុំនិងភរិយា សូមប្រសិទ្ធពរជ័យសិរីមង្គល ជូនឯកឧត្តម និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ព្រមទាំងនិយោជិតទាំងអស់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ៖ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តម ទទួលនូវការគោរពស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣*

**ហ៊ុន សែន**

# សន្ទរកថា
# ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីទិវាស្បៀងអាហារពិភពលោក ឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

(ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ )



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីទិវាស្បៀងអាហារពិភពលោក ឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា*

សូមគោរព

- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកអគ្គរាជទូត និងរដ្ឋទូត
- លោក Gianpietro Bordignon តំណាងកម្មវិធីស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជា
- លោក តំណាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ អន្តរជាតិ និងបងប្អូនតំណាងកសិករ និងសហគមន៍កសិកម្ម ព្រមទាំងក្មួយៗនិស្សិតទាំងអស់ ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយក្រៃលែងដោយបានចូលរួមជាអធិបតីក្នុងទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៣ ក្រោមប្រធានបទ "ប្រព័ន្ធស្បៀងមាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ" នាពេលនេះ ដែលទិវានេះបានរៀបចំជារៀងឆ្នាំ ដើម្បីពិនិត្យមើល និងបង្កើនការយល់ដឹងពីបញ្ហា និងដំណោះស្រាយនូវសន្តិសុខស្បៀង និងឆ្ពោះទៅបញ្ចប់ភាពអត់ឃ្លាន។ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមគាំទ្រទាំងស្រុងនូវខ្លឹមសារនៃសាររបស់ឯកឧត្តមអគ្គនាយកអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងសាររបស់កម្មវិធីស្បៀងអាហារពិភពលោក ដែលសបញ្ជាក់ឲ្យឃើញថានៅក្នុងទសវត្សរ៍នេះយើងរួមគ្នាប្រយុទ្ធប្រឆាំងនឹងគ្រោះអត់ឃ្លាន និងឆ្ពោះទៅបំបាត់ភាពអត់ឃ្លាន ស្របតាមគោលដៅ អភិវឌ្ឍសហស្សវត្សរ៍នៅឆ្នាំ ២០១៥ ។

គួរកត់សម្គាល់ថា ការរៀបចំទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៣ថ្ងៃនេះ ស្របពេលជាមួយនឹងការអំពាវនាវរបស់អង្គការសហប្រជាជាតិ និងបណ្តាប្រទេសនានានៅលើសាកលលោកដែលបាននឹងកំពុងប្រារព្ធធ្វើឡើង ដើម្បីពិនិត្យមើល និងបង្កើនការយល់ដឹងពីបញ្ហានិងដំណោះស្រាយនូវសន្តិសុខស្បៀង និងឆ្ពោះទៅបញ្ចប់ភាពអត់ឃ្លានព្រមទាំងចូលរួមចំណែកក្នុងការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម និងចីរភាពនៃកំណើនសេដ្ឋកិច្ចជាតិ។

អង្គពិធីទាំងមូលជាទីមេត្រី!

នៅក្នុងសាកលលោកបានទទួលស្គាល់ថា សុខភាពរបស់មនុស្សគឺអាស្រ័យលើប្រព័ន្ធស្បៀងមានភាពរឹងមាំ និងនិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនាពេលបច្ចុប្បន្ន ហើយដែលមានប្រជាជនប្រមាណជាង៨៧០ លាននាក់នៅតែប្រឈមនឹងកង្វះអាហារូបត្ថម្ភ។ ពិតណាស់ថាសារសំខាន់នៃប្រព័ន្ធស្បៀង គឺជាប្រព័ន្ធមួយធ្វើឲ្យបរិស្ថាន ប្រជាពលរដ្ឋ ស្ថាប័ន និងដំណើរការ នៃផលិតផលកសិកម្មដែលបានផលិត កែច្នៃ បានទៅដល់អ្នកប្រើប្រាស់ដោយផ្ទាល់។ គ្រប់ទិដ្ឋភាពទាំងអស់នៃប្រព័ន្ធស្បៀងអាហារមួយដែលមានប្រសិទ្ធភាពនោះគឺផ្តោតជាសំខាន់ទៅលើភាពមានស្បៀងគ្រប់គ្រាន់ ការទទួលបានស្បៀង ស្បៀងមានអាហារូបត្ថម្ភ

គ្រប់គ្រាន់ ហើយចុងក្រោយអ្នកប្រើប្រាស់មានលទ្ធភាពជ្រើសរើសទៅតាមតម្រូវការគុណភាព របបអាហារហូបចុកសម្រាប់សុខភាពរបស់ពួកគេ។

បច្ចុប្បន្ននេះនៅលើសាកលលោក ផលិតកម្មកសិកម្ម និងបញ្ហាសន្តិសុខស្បៀងកំពុងប្រឈមមុខនឹងតម្រូវការស្បៀងអាហារច្រើនក្នុងខណៈដែលប្រជាជនមានកំណើនយ៉ាងរហ័ស ជាពិសេសនៅតំបន់ទីក្រុងនិងជាយក្រុងក៏ដូចជាការ រងសម្ពាធលើធនធានធម្មជាតិ ការបម្រែបម្រួលអាកាសធាតុ និងការប្រកួតប្រជែងទីផ្សារផលិតផលកសិកម្មជាដើម។ ទោះជាយ៉ាងណា វិស័យកសិកម្មបានផ្ដល់និងផ្គត់ផ្គង់នូវគ្រាប់ធញ្ញជាតិសម្រាប់ស្បៀងអាហារ និងចំណីសត្វ ចំណីអាហារដែលមានប្រភពមកពីសត្វមានដូចជាផលិតផលសាច់ ស៊ុត ទឹកដោះ ត្រី និងវារីវប្បកម្ម។ល។ហើយការបង្កើនផលិតកម្មស្បៀងអាហារក៏តម្រូវការកម្លាំងពលកម្មច្រើននៅជនបទ ការទទួលយកវិធីសាស្ត្រផលិតកម្មមានប្រសិទ្ធភាពខ្ពស់ និងមានចីរភាព ព្រមទាំងវិធីសាស្ត្របន្សាំ និងបន្ធូរបន្ថយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ យ៉ាងណាមិញ ការប្រើប្រាស់វិធីសាស្ត្រប្រព័ន្ធបច្ចេកទេសចម្រុះ គឺជាយុទ្ធសាស្ត្រមួយចាំបាច់សម្រាប់ដោះស្រាយដើម្បីធានាបាននូវបរិមាណ និងគុណភាពស្បៀងអាហារទាំងនៅទីក្រុង និងជនបទ តាមរយៈខ្សែចង្វាក់ផ្គត់ផ្គង់ស្បៀងអាហារឆាប់រហ័ស ការទំនាក់ទំនងដ៏រឹងមាំរវាងទីក្រុងនឹងជនបទ និងធានាការគ្រប់គ្រងបាននូវធនធានធម្មជាតិ ព្រមទាំងវិធានការត្រៀមបម្រុងនឹងការប្រែប្រួលអាកាសធាតុផងដែរ។

យើងទាំងអស់គ្នាបានជ្រាបហើយថានៅកម្ពុជាខណៈដែលពិពិធកម្មសេដ្ឋកិច្ចដែលរួមទាំងឧស្សាហូបនីយកម្មស្ថិតជាអាទិភាពសម្រាប់ការអភិវឌ្ឍនៅពេលអនាគតនោះ វិស័យកសិកម្មនៅតែដើរតួនាទីដ៏សំខាន់ក្នុងការជំរុញផលិតផលក្នុងស្រុក ការបង្កើតការងារ និងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ធានាបាននូវចីរភាពកំណើនសេដ្ឋកិច្ច ការកែលម្អសន្តិសុខស្បៀង និងពន្លឿនការកាត់បន្ថយភាពក្រីក្រ។ និយាយរួម រាជរដ្ឋាភិបាលបានចាត់ទុករួចហើយថា វិស័យកសិកម្មគឺជាវិស័យអាទិភាពមួយគ្រប់កាលៈទេសៈ។ វិស័យនេះបានចូលរួមចំណែកក្នុងផលិតផលសរុបក្នុងស្រុកប្រមាណ ២៧,៥ភាគរយនៅឆ្នាំ ២០១២ និងបានរក្សាកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណពី៤ទៅ៥ភាគរយនៅចន្លោះឆ្នាំ ២០០៦-



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីទិវាស្បៀងអាហារពិភពលោក ឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា*

២០១២។ នៅឆ្នាំ២០១២ វិស័យកសិកម្មមានកំណើនជាមធ្យមប្រមាណ៤,៣% ក្នុងនោះមានការចូលរួមពីអនុវិស័យដំណាំកសិកម្មមានប្រមាណ៥៤.៨% ជលផល ២៥.៤% ផលិតកម្មសត្វ ១៤.១ %និងអាជីវកម្មព្រៃឈើមាន ៥.៧%។ នេះជាសមិទ្ធផលដែលសម្រេចបានតាមរយៈការទទួលយកទៅប្រើប្រាស់នូវបច្ចេកវិទ្យាសមស្រប ធាតុចូលនិងសេវាគាំទ្រផ្សេងៗទៀតក្នុងចំណោមប្រជាកសិករ។

ទោះជាយ៉ាងណាយើងក៏ទទួលស្គាល់ថា វិស័យកសិកម្មនៅកម្ពុជាក៏មានជួបបញ្ហាប្រឈម ដូចជាការរក្សានូវទម្លាប់ចាស់ ការធ្វើស្រែប្រវាស់មេឃ ការប្រែប្រួលអាកាសធាតុ សម្ពាធទៅលើធនធានធម្មជាតិ និងសមត្ថភាពប្រកួតប្រជែងទីផ្សារលើផលិតកម្មនៅក្នុងតំបន់ និងនៅលើសាកលលោកនៅមានកម្រិត គួបផ្សំទៅនឹងកត្តាបច្ចេកទេសរបស់យើងក៏នៅមានកម្រិតនៅឡើយ។ ទោះបីជាមានបញ្ហាប្រឈម ក៏វិស័យកសិកម្មនៅកម្ពុជានៅមានកាលានុវត្តភាព និងឧត្តមភាពប្រៀបធៀបជាច្រើន ដើម្បីពង្រីកផលិតភាពរបស់ខ្លួន តាមរយៈការបង្កើនប្រពលវប្បកម្ម និងពិពិធភាវូបនីយកម្មកសិកម្ម ដោយប្រើប្រាស់ឲ្យអស់លទ្ធភាពនូវធនធានដី និងទឹក បច្ចេកវិទ្យា និងតាមរយៈការទាញយកកាលានុវត្តភាពទីផ្សារក្នុងស្រុកក្នុងតំបន់ និងនៅលើសាកលលោក។

ជាក់ស្ដែងក្នុងឆ្នាំ២០១២កន្លងមកនេះ វិស័យផលិតកម្មដំណាំ យើងផលិតស្រូវបានសរុបចំនួនប្រមាណ៩,៣លានតោន និងមានសល់ស្បៀងអាហារក្រៅពីហូបចុកគិតជាស្រូវប្រមាណ ៤,៧លាន និងគិតជាអង្ករសល់ប្រមាណ៣លានតោន



*ទិដ្ឋភាពភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីទិវាស្បៀង អាហារពិភពលោក ឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា*

សម្រាប់នាំចេញ។ ដំណាំផ្សេងៗទៀតដូចជាដំណាំបន្លែ ឈើហូបផ្លែ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មក៏បានកើនឡើងគួរឲ្យកត់សម្គាល់ដែរ ក្នុងនោះផ្ទៃដីដំណាំកៅស៊ូបានកើនឡើងជិត ៣០០ពាន់ហិកតា។ ពិនិត្យលើការនាំចេញអង្ករវិញ ក្នុងរយៈពេល០៩ខែដើមឆ្នាំនេះកើនដល់២៦៦.១២៣តោនខណៈដែលក្នុងរយៈពេល៩ខែដើមឆ្នាំ២០១២ មានតែ ១២៩.២៣៣ តោនប៉ុណ្ណោះ (មានកំណើន១៣៦.៨៩០តោនឬ១០៥,៩%) ដែលអង្ករកម្ពុជាយើង បានធ្វើការនាំចេញ ទៅកាន់ទិសដៅចំនួន៥៧ប្រទេស។

ក្រៅពីផលិតកម្មដំណាំកសិកម្ម វិស័យចិញ្ចឹមសត្វនិងជលផល ក៏មានតួនាទីសំខាន់ ក្នុងការចូលរួមចំណែកធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ។ ការចិញ្ចឹមសត្វបានចូលរួមដោយផ្ទាល់ក្នុងតម្រូវការចំណីអាហារ និងបង្កើនប្រាក់ចំណូលគ្រួសារសម្រាប់ប្រជាជនកម្ពុជាដែលរស់នៅជនបទ ជាពិសេសកសិករតូចតាច។ ជាទូទៅផលិតកម្មនេះមានកំណើនប្រមាណ២% ក្នុង១ឆ្នាំ ដែលវិស័យនេះត្រូវបានខិតខំបន្ថែមទៀត ដើម្បីសម្រេចបានគោលដៅក្នុងការធានាការផ្គត់ផ្គង់ក្នុងស្រុកឲ្យបានគ្រប់គ្រាន់ និងការធ្វើពាណិជ្ជកម្មក្នុងរយៈពេលមធ្យម និងវែង។ បច្ចុប្បន្នកម្ពុជានៅមានសក្តានុពលច្រើនក្នុងការពង្រីកវិស័យចិញ្ចឹមសត្វ ដោយសារកម្ពុជាមានប្រភពចំណីសត្វច្រើន វាលស្មៅ និងអាកាសធាតុអំណោយផលល្អ។ ក្នុងន័យនេះ យើងបាន និងកំពុងជំរុញការវិនិយោគក្នុងវិស័យចិញ្ចឹមសត្វ តាមរយៈការផ្តល់ជូនគ្រួសារកសិករខ្នាតតូចនូវកញ្ចប់សេវាកម្មនានា រួមមានបច្ចេកវិទ្យាពូជសត្វចំណីសត្វសេវាថែទាំសុខភាពសត្វ និងជីវសុវត្ថិភាព ឥណទាន និងដំណោះស្រាយទីផ្សារ។ល។ ដែលមកដល់ពេលនេះយើងមានភ្នាក់ងារសុខភាពសត្វភូមិស្ម័គ្រចិត្តប្រមាណ១៤ ពាន់នាក់ ត្រូវបានបណ្តុះបណ្តាលហើយត្រូវបានផ្តល់សេវាចាំបាច់ បន្ទាន់លើផលិតកម្មសត្វ និងបសុសត្វទៅដល់កសិករ នៅតាមមូលដ្ឋានភូមិ ឃុំ។ ដោយឡែកវិស័យជលផលក៏បានចូលរួមចំណែកមួយយ៉ាងសំខាន់ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋក្រីក្រ និងបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ កន្លងមកផលនេសាទប្រចាំឆ្នាំ ដែលមានទាំងផលនេសាទទឹកសាបទាំងសមុទ្រ និងផលិតផលវារីវប្បកម្ម មានចំនួនសរុបពី៤០០ពាន់ ទៅ៦០០ពាន់តោន និងបានចូលរួមប្រមាណ១២%នៃផលទុនក្នុងស្រុក។ ដោយឡែកការនេសាទតាមវាលស្រែក៏ជាផ្នែកមួយសំខាន់ក្នុងការបង្កើនផលចាប់ ដែលមានរហូតដល់២៨% នៃផលនេសាទសរុបនៅកម្ពុជា ហើយបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងតម្រូវការអាហារប្រចាំថ្ងៃ។ លើសពីនេះទៅទៀត ស្រះជម្រកត្រីដែលត្រូវបានបង្កើតតាមភូមិ ឃុំ សម្រាប់បង្កើនផលិតត្រីប្រកបដោយនិរន្តរភាព និងអាចជួយផ្តល់សារសំខាន់ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ក្នុងការធ្វើនេសាទក្នុងដែនសាធារណៈ ជាពិសេសប្រជាពលរដ្ឋក្រីក្រ ក្នុងការនេសាទសម្រាប់ស្បៀងអាហារ និងប្រាក់ចំណូលក្នុងគ្រួសារ។

ជារួម វិស័យកសិកម្ម បានផ្តល់នូវប្រព័ន្ធផលិតកម្មចែកចាយ និងផ្គត់ផ្គង់ស្បៀងអាហារប្រកបនិរន្តរភាព និងសុវត្ថិភាពសម្រាប់ស្បៀងអាហារ និងអាហារូបត្ថម្ភរបស់ប្រជាជនស្របតាមគោលបំណងនៃទិវាស្បៀងអាហារពិភពឆ្នាំ២០១៣ ដែលកំពុងប្រព្រឹត្តទៅនាថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣នេះ ក្រោមប្រធានបទ "ប្រព័ន្ធស្បៀងមាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ"។

**អង្គពិធីទាំងមូលជាទីមេត្រី!**

ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខស្បៀង ប្រទេសកម្ពុជាបានទទួលជោគជ័យ ដោយសម្រេចបាននូវគោលដៅទី១ នៃគោលដៅសហសវត្ស ក្នុងការប្រយុទ្ធនឹងភាពក្រីក្រ និងអត់ឃ្លាន ក្នុងចំណោមប្រទេស៣៨ នៅលើសាកលលោក ដោយបានទទួលប័ណ្ណទទួលស្គាល់សមិទ្ធផលប្រយុទ្ធនឹងភាពអត់ឃ្លាននៃគោលដៅសហស្សវត្សរ៍គិតត្រឹមឆ្នាំ២០១២ មុនគោលដៅសហស្សវត្សរ៍៣ឆ្នាំ ពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) នៅក្នុងខែមិថុនា ឆ្នាំ២០១៣។

ឆ្លៀតឱកាសដ៏មានសារសំខាន់នេះ ខ្ញុំសូមជម្រាបជូនឯកឧត្ដម លោកជំទាវ អស់លោក លោកស្រីពីស្ថានភាពបង្កបង្កើនផលនៅរដូវវស្សាឆ្នាំ២០១៣ នេះថា ពិតមែនតែមានភាពមិនប្រក្រតីនៃបាតុភូតធម្មជាតិ មានកង្វះទឹក និងមានជំនន់ទឹកភ្លៀងនៅតាមតំបន់មួយចំនួនក៏ពិតមែន ក៏ស្ថានភាពបង្កបង្កើនផលគិតមកដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ជារួមមានកម្រិតល្អប្រសើរទូទាំងប្រទេស យើងអនុវត្តបានលើសផែនការដោយការដាំដុះដំណាំស្រូវបានសរុបចំនួនជាង២,៥៥៤លានហិកតា ស្មើនឹង ១០៦,៤៤% នៃផែនការ ២.៣៩៩.៦៣៧ ហិកតា លឿនជាងឆ្នាំមុនចំនួន៦០.៥២៦ហិកតា បើប្រៀបធៀបរយៈពេលដូចគ្នា។ ទន្ទឹមនឹងលទ្ធផលខាងលើ ដំណាំស្រូវរដូវវស្សានៅតាមបណ្ដាខេត្តមួយចំនួន ត្រូវទទួលរងនូវគ្រោះទឹកជំនន់ជាបន្តបន្ទាប់ ហើយថ្មីៗនេះទៀត ក៏ត្រូវទទួលរងនូវបាតុភូតគ្រោះធម្មជាតិបង្កឡើងដោយទឹកជំនន់ទឹកភ្លៀងពីប៉ែកខាងលើ ដែលគិតត្រឹមថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ បានបង្កការប៉ះពាល់លើផ្ទៃដីសន្ទូង និងស្រូវពង្រោះចំនួន២៧៩.៣១៦ ហ.ត បណ្ដាលឲ្យមានការខូចខាតចំនួន២៣.៣២៤ហិកតា។ គ្រោះធម្មជាតិនេះ ក៏នឹងអាចកើតមាននៅពេលដ៏ខ្លីខាងមុខ ដែលយើងមិនអាចមើលរំលងបាន ជាពិសេសការហក់ឡើងយ៉ាងគំហុកជាថ្មីទៀតនៃទឹកជំនន់ទន្លេមេគង្គស្របពេលមានទឹកជំនន់ទឹកភ្លៀងនៅប៉ែកខាងលើ។

ក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការអនុវត្តកម្មវិធី និងគម្រោងជាច្រើនជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងគោលបំណងកែលម្អសន្តិសុខស្បៀងគ្រួសារ ជីវភាពរស់នៅ និងប្រាក់ចំណូលគ្រួសារនៅជនបទ តាមរយៈជំរុញផលិតកម្ម និងពិពិធកម្មកសិកម្មតាមគ្រួសារកសិករមាន ការធ្វើប្រពលវប្បកម្មដំណាំស្រូវ និងពិពិធកម្មដំណាំរួមផ្សំដំណាំបន្លែ ដំណាំឈើហូបផ្លែ ការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈគ្រួសារនិងប្រព័ន្ធកសិកម្មចម្រុះ ការរៀបចំ និងពង្រឹងក្រុមកសិករជួយខ្លួនឯងមានក្រុមសន្សំប្រាក់ក្រុមផលិតស្បៀង ធនាគារស្រូវ ធនាគារជី។ល។ និងការអនុវត្តគម្រោងសហគមន៍ខ្នាតតូច និងជំនួញខ្នាតតូច ព្រមទាំងជំរុញការបង្កើត និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដែលមកទល់ពេលនេះមានចំនួន៤៨២សហគមន៍ ដោយមិនរាប់បញ្ចូលសហគមន៍ព្រៃឈើ(៣៤២សហគមន៍) និងសហគមន៍នេសាទ (៣២៨ សហគមន៍) ដែល



*ទិដ្ឋភាពរួមក្នុងពិធីទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា*

ទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនោះឡើយ។

**អង្គពិធីទាំងមូលជាទីមេត្រី!**

ដើម្បីចូលរួមអបអរសាទរទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៣ ស្ដីពី "ប្រព័ន្ធស្បៀងមាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ " ខ្ញុំសូមចូលរួមផ្ដល់អនុសាសន៍នូវចំណុចគន្លឹះមួយចំនួនដូចតទៅ៖

ទី១. សូមអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តការគាំទ្រ ក្នុងការលើកកម្ពស់វិស័យកសិកម្មដោយជំរុញការបង្កើនផលិតភាពពិពិធកម្មភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដើម្បីចូលរួមចំណែកកែលម្អសន្តិសុខស្បៀងអាហារ បំបាត់ភាពអត់ឃ្លាន និងចីរភាពកំណើនសេដ្ឋកិច្ច និងដើម្បីធានាប្រព័ន្ធស្បៀងមាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងនៅក្នុងសហគមន៍ ថ្នាក់ជាតិ ថ្នាក់តំបន់ និងនៅលើសាកលលោក ដោយអនុលោមទៅតាមមុំសមរភូមិទាំង ៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។

ទី២. អង្គភាពជំនាញពាក់ព័ន្ធ មន្ទីរកសិកម្មរាជធានី ខេត្ត និងមន្ត្រីកសិកម្មនៅថ្នាក់មូលដ្ឋានត្រូវបន្តជំរុញតាមដាននូវផលប៉ះពាល់ពីទឹកជំនន់លើផលដំណាំនិងការចិញ្ចឹមសត្វ ព្រមទាំងការត្រៀមបម្រុងនូវមធ្យោបាយសរុបមានធាតុចូលកសិកម្មចាំបាច់នានា និងមន្ត្រីជំនាញដើម្បីស្តារនូវការខូចខាតឲ្យទាន់ពេលវេលា ដោយធានាបានទាំងបរិមាណ និងគុណភាពផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ស្បៀងអាហារ និងប្រព័ន្ធស្បៀងមាន





*ទិដ្ឋភាពរួមក្នុងពិធីទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា*

និរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ពោលគឺត្រូវអនុវត្តតាមសារាចរណែនាំស្តីពីវិធានការជំរុញការស្តារឡើងវិញនូវការខូចខាតដោយគ្រោះទឹកជំនន់រដូវវស្សាឆ្នាំ២០១៣នេះ។ ដោយឡែក ឯកឧត្តមថ្នាក់ដឹកនាំទទួលបន្ទុកខេត្តនីមួយៗ អង្គភាពជំនាញមន្ទីរកសិកម្មរាជធានី-ខេត្តទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាននិងគោងគិតថាតើយើងត្រូវធ្វើអ្វីខ្លះចំពោះមុខដើម្បីស្តារការខូចខាតក្រោយទឹកស្រក? នេះជាកាតព្វកិច្ចចំពោះមុខដែលត្រូវធ្វើ។

ទី៣. ជំរុញការអនុវត្តប្រព័ន្ធកសិកម្មចម្រុះក្នុងគ្រួសារនិងកសិដ្ឋានរបស់កសិករជាពិសេសគ្រួសារកសិករខ្នាតតូចដែលជាយុទ្ធសាស្ត្រមួយ ប្រកបដោយប្រសិទ្ធភាពក្នុងការធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការដាក់បញ្ចូលប្រព័ន្ធចម្រុះមួយមាន៖ ដំណាំស្រូវ សួនដំណាំគ្រួសារ មានដំណាំបន្លែ ដំណាំរួមផ្សំ និងឈើហូបផ្លែការចិញ្ចឹមសត្វខ្នាតតូច និងចិញ្ចឹមត្រីតាមគ្រួសារ និងប្រើប្រាស់ធាតុចូលនៅមូលដ្ឋាន ដូចជាជីធម្មជាតិ ការបង្កើតឲ្យមានប្រព័ន្ធផលិតស្បៀងនិងអាហារូបត្ថម្ភពេញមួយឆ្នាំសម្រាប់គ្រួសារ និងទីផ្សារគឺជាកិច្ចការដែលគ្រប់អង្គភាពទាំងអស់ត្រូវយកចិត្តទុកដាក់មិនអាចមើលរំលងបានឡើយ។

ទី៤. ជំរុញកសិករ និងសហគមន៍កសិកម្ម ឲ្យចេះប្រមូលផ្តុំគ្នាធ្វើឯកទេសកម្មក្នុងការផលិតស្រូវ និងកែច្នៃអង្ករពូជមួយ ឬពីរ ដែលសមស្របទៅតាមតំបន់ និងតាមតម្រូវការទីផ្សារ។ ពង្រឹង ពង្រីកមុខរបរ និងសេវាកម្មរបស់ខ្លួន ដូចជាការផលិតពូជការផ្សាំពូជ ចិញ្ចឹមត្រីចិញ្ចឹមសត្វ បើកស្តង់លក់សម្ភារកសិកម្ម ការស្តុកស្បៀងអាហារតាមគ្រួសារ និងសហគមន៍ ដើម្បីធានាបានការផ្គត់ផ្គង់ស្បៀងអាហារក្នុងគ្រួសារ និងសហគមន៍ និងប្រព័ន្ធស្បៀងមាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ កសិករ និងសហគមន៍កសិកម្ម ត្រូវចេះគ្រប់គ្រងដឹកនាំ ស្វែងរកដៃគូស្វែងរកទីផ្សារ ដូចជា ចងក្រងសហគមន៍ផលិតស្រូវ និងបង្កើតឲ្យមានឃ្លាំងស្តុកស្រូវ មានម៉ាស៊ីនកិនស្រូវតាមសហគមន៍ ដើម្បីប្រមូលទិញស្តុកស្រូវអង្ករ បង្កើនសមត្ថភាពក្នុងការចរចាតម្លៃ ធានាសន្តិសុខស្បៀងអាហារក្នុងសហគមន៍ បង្កើនការងារដល់មូលដ្ឋាន និងមានវត្ថុធាតុដើមក៏ដូចជាតម្លៃបន្ថែមដូចជា ចុងអង្ករអង្កាម កន្ទក់ជាដើមនៅក្នុងមូលដ្ឋាននិងរួមចំណែកកាត់បន្ថយការធ្វើចំណាកស្រុកជានិច្ចកាលចាំបាច់។



*ទិដ្ឋភាពផ្តល់ស្រូវពូជដល់ប្រជាកសិករក្នុងពិធីទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា*








*ទិដ្ឋភាពផ្ដល់ពូជស្រូវ និងពូជឈើដល់ប្រជាកសិករក្នុងពិធីទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា*

ទី៥. ជំរុញបង្កើតបណ្ដាញធុរកិច្ច និងការទំនាក់ទំនងមុខរបររវាងកសិករ សហគមន៍កសិកម្ម ជាមួយនឹងវិស័យឯកជន និងអ្នកផ្ដល់សេវាកសិកម្មនានា ដើម្បីផ្ដល់សេវាផ្គត់ផ្គង់ធាតុចូលកសិកម្ម និងជំរុញឱ្យមានការឈានចូលទីផ្សារ នូវផលិតផលរបស់កសិករ និងសហគមន៍កសិកម្មព្រមទាំងជួយលើកកម្ពស់ផលិតផលកសិកម្ម និងតម្លៃផលិតផលក្នុងស្រុក។

ទី៦. អង្គភាពជំនាញពាក់ព័ន្ធ មន្ទីរកសិកម្មរាជធានីខេត្ត

និងមន្ត្រីកសិកម្មនៅថ្នាក់មូលដ្ឋានត្រូវជំរុញឲ្យកសិករត្រៀមលក្ខណៈធ្វើស្រូវប្រដេញទឹកនៅរដូវទឹកសម្រកខាងមុខ និងស្រូវរដូវប្រាំងដើម្បីបំពេញការខូចខាតដោយគ្រោះធម្មជាតិនៅរដូវវស្សាឆ្នាំ ២០១៣នេះឱ្យបានទាន់ពេលវេលា និងផ្ដល់នូវនិរន្តរភាពប្រព័ន្ធស្បៀងសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ សហការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ជំរុញការអនុវត្តកម្មវិធីស្បៀងបម្រុងឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ហើយក៏មិនត្រូវមើលរំលងអំពីការរួបរួមបន្តការពារភពផែនដីក៏ដូចជាធនធានធម្មជាតិតាមគ្រប់មធ្យោបាយដែលយើងមានសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ពិសេសការលើកកម្ពស់កសិកម្មមខុនាតតូចប្រកបដោយនិរន្តរភាពរបស់ប្រជាពលរដ្ឋដែលមានចំនួនដ៏ច្រើនកំពុងរស់នៅតំបន់ជនបទ ដែលជាការរួមចំណែកមួយក្នុងការជួយគាំទ្រដល់និរន្តរភាពនៃបរិស្ថានពិភពលោកផងដែរ។

**-គណៈអធិបតីជាទីគោរព និង អង្គពិធីជាទីមេត្រី**

ជាថ្មីម្តងទៀតក្នុងឱកាសទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៣នេះ ខ្ញុំសូមអំពាវនាវដល់ដៃគូអភិវឌ្ឍ ផ្នែកឯកជន អង្គការជាតិ-អន្តរជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ សូមបន្តការគាំទ្រដល់ការលើកកម្ពស់វិស័យកសិកម្ម និងសន្តិសុខស្បៀង ដើម្បីធានាបានទាំងបរិមាណ និងគុណភាពស្បៀងអាហារ និងប្រសិទ្ធភាពនូវប្រព័ន្ធផ្គត់ផ្គង់ និងចែកចាយស្បៀងឱ្យមាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីកាត់បន្ថយភាពអត់ឃ្លាន និងរក្សាចីរភាពនៃកំណើនសេដ្ឋកិច្ចជាតិទាំងក្នុងតំបន់ និងសាកលលោក។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវជាតិ អន្តរជាតិ បងប្អូនតំណាងកសិករ និងសហគមន៍កសិកម្ម ព្រមទាំងក្មួយៗនិស្សិតទាំងអស់ដែលបានចូលរួមយ៉ាងគគ្រឹកគគ្រេងក្នុងទិវាដ៏មានអត្ថន័យ និងមានសារៈសំខាន់នេះ និងសូមគោរពជូនពរ សូមមានសុខភាពល្អប្រសើរ ទទួលបានជ័យជំនះថ្មីៗថែមទៀត និងទទួលនូវ ពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ !***

# សមិទ្ធផលសំខាន់ៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់សន្តិសុខស្បៀង និងកំណើនសេដ្ឋកិច្ច ចីរភាព ការអភិវឌ្ឍ

ដោយបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខែវិច្ឆិកា ឆ្នាំ២០១៣

## ១. សភាពការណ៍រួម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចនូវសមិទ្ធផលសំខាន់ៗជាច្រើនក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលនីតិកាលទី៤នៃរដ្ឋសភា លើការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ព្រមទាំងការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព ដើម្បីធានាចីរភាពកំណើនសេដ្ឋកិច្ច សន្តិសុខស្បៀងពន្លឿនការកាត់បន្ថយភាពក្រីក្រ និងរក្សាបាននូវនិរន្តរភាពបរិស្ថាន រួមមាន ផ្នែកដំណាំកសិកម្ម ផលិតកម្មនិងបសុព្យាបាល ដំណាំកៅស៊ូ ជលផលនិងវារីវប្បកម្ម និងព្រៃឈើ។ ទន្ទឹមនឹងនេះវិស័យកសិកម្ម មានសក្ដានុពល កាលានុវត្តភាពនិងមានឧត្តមភាពប្រៀបធៀប (Comparative Advantage) សម្រាប់ទីផ្សារកសិផល និងជាវត្ថុធាតុដើមនៅក្នុងតំបន់ និងនៅលើសាកលលោកដូចជាផលិតផលស្រូវ អង្ករ និងកសិផលនានាមានដំឡូងមី ពោត សណ្ដែកបាយ សណ្ដែកសៀង ផលិតផលជ័រកៅស៊ូធម្មជាតិផលិតផលសត្វនិងផលិតផលត្រីជាដើម។ស្ថិតក្នុងបរិបទតម្រូវការស្បៀងអាហារកង្វះអាហារូបត្ថម្ភ និងកំណើនប្រជាជននៅលើសាកលលោក វិស័យកសិកម្មនៅតែដើរតួនាទីសំខាន់ក្នុងចីរភាពកំណើនសេដ្ឋកិច្ច និងសេដ្ឋកិច្ច-សង្គម ដែលបានផ្ដល់ដល់ប្រជាពលរដ្ឋក្រីក្រ អ្នកជួបបញ្ហាអសន្តិសុខស្បៀងអាហារដោយវិស័យកសិកម្ម ផ្ដល់នូវស្បៀង



ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះពិនិត្យស្ថានភាពប៉ះពាល់ដោយទឹកជំនន់ នៅខេត្តកណ្ដាល

ក្រាហ្វិកទី១. ការលូតលាស់វិស័យកសិកម្មឆ្នាំ ២០០៨-២០១២




ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

អាហារ វត្ថុធាតុសរសៃ និងថាមពល(Fibre and Energy) ចំណីសត្វ ចំណីអាហារដែលមានប្រភពមកពីសត្វមានដូចជា ផលិតផលសាច់ ស៊ុត ទឹកដោះ ត្រី និងវារីវប្បកម្ម ក៏ដូចជាប្រេងឆា។ល។

ទោះបីនាបច្ចុប្បន្នវិស័យកសិកម្មប្រឈមមុខនឹងតម្រូវការស្បៀងអាហារច្រើន តាមតម្រូវការកំណើនប្រជាជនយ៉ាងរហ័ស ការរងសម្ពាធលើធនធានធម្មជាតិ ការបម្រែបម្រួលអាកាសធាតុ និងការប្រកួតប្រជែងទីផ្សារផលិតផលកសិកម្ម។ល។ ក៏វិស័យកសិកម្មធានាបានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណពី ៤% ទៅ ៥% នៅចន្លោះឆ្នាំ២០០៨-២០១២ និង កំណើនជាមធ្យមប្រមាណ ៤,៣% ក្នុងឆ្នាំ ២០១២ ព្រមទាំងបានចូលរួមចំណែកក្នុងផលិតផលសរុបក្នុងស្រុក(GDP) ប្រមាណ ២៧,៥% ដែលក្នុងនោះមានការចូលរួមពីអនុវិស័យដំណាំកសិកម្មមានប្រមាណ៥៤,៨% ជលផល ២៥,៤% ផលិតកម្មសត្វ ១៤,១ % និងព្រៃឈើ ៥,៧% (MAFF, April 2013)។ ក្នុងឆ្នាំ២០១២ កន្លងទៅនេះផលិតស្រូវសរុបចំនួនប្រមាណ៩,២៩ លានតោន និងមានសល់ស្បៀងអាហារក្រៅពីហូបចុកគិតជាស្រូវប្រមាណ ៤,៧៣ លានតោន និងគិតជាអង្ករសល់ប្រមាណជាង ៣ លានតោនសម្រាប់នាំចេញ។

ក្រាហ្វិកទី២.ការចូលរួមរបស់វិស័យ និងអនុវិស័យកសិកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិឆ្នាំ២០១២







ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

## ២. ការបង្កើនផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម

វិស័យកសិកម្មមានសក្ដានុពល និងកាលានុវត្តភាព ដែលមានវិសាលភាពផ្ទៃដីសម្រាប់ដំណាំកសិកម្មមានប្រមាណជាង ៥,៥ លានហិកតា ក្នុងនោះមានដំណាំស្រូវចំនួនជាង៣ លានហិកតា ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មប្រមាណជាង ១ លានហិកតា ដំណាំឈើហូបផ្លែមានប្រមាណ ២០០ពាន់ហិកតា ដំណាំកៅស៊ូមានជាង២៨០ពាន់ហិកតា និងដីសម្រាប់ដំណាំកសិ-ឧស្សាហកម្មនានាតាមរយៈការវិនិយោគដីសម្បទាន សេដ្ឋកិច្ចប្រមាណជិត ១,២ លានហិកតា។

### ក.ផលិតកម្មដំណាំស្រូវ

ស្រូវជាដំណាំស្បៀងមួយសំខាន់ជាងគេសម្រាប់ប្រជាជនប្រមាណពាក់កណ្ដាលនៃប្រជាជនលើសាកលលោក ហើយនៅព្រះរាជាណាចក្រកម្ពុជា ស្រូវជាដំណាំស្បៀងមួយសំខាន់ សម្រាប់ប្រជាជនកម្ពុជាដែលជាប្រភពថាមពលប្រមាណពី ៦៨% ទៅ ៧០%នៃបរិមាណកាឡូរីចាំបាច់ប្រចាំថ្ងៃ។ ចាប់ពីឆ្នាំ១៩៩៥មកកម្ពុជាធានាបាននូវសន្តិសុខស្បៀងអាហារ ដោយមានសល់អង្ករប្រមាណជាង២៣០ ពាន់តោន ហើយបរិមាណអង្ករសល់នេះ បានកើនឡើងយ៉ាងរហ័សដល់ជាង ២ លានតោនអង្ករនៅឆ្នាំ២០០៨ និងកើនដល់ជាង ៣លានតោនក្នុងឆ្នាំ ២០១២។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដាំដុះដំណាំស្រូវបានកើនឡើងយ៉ាងរហ័សពី២,៦លានហ.ត និងមានបរិមាណផលស្រូវប្រមាណ៧,១៧ លានតោននៅឆ្នាំ២០០៨ ហើយកើនដល់ជាង៣លានហិកតា និងមានបរិមាណស្រូវប្រមាណ ៩,២៩ លាន តោននៅឆ្នាំ២០១២ និងមានសល់ស្បៀងអាហារក្រៅពីហូបចុកគិតជាស្រូវប្រមាណ ៤,៧៣



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីទិវាស្បៀងអាហារពិភពលោក ឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា*

ក្រាហ្វិកទី៣.ស្ថានភាពផលិតកម្មស្រូវឆ្នាំ២០០៣-២០១២




ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

លានតោន និងគិតជាអង្ករសល់ប្រមាណជាង ៣ លានតោនសម្រាប់នាំចេញ។ ផលិតកម្មស្រូវបានកើនឡើងក្នុង១ឆ្នាំៗ ប្រមាណជាង៦០ម៉ឺនតោន ក្នុងរយៈពេល៥ឆ្នាំពីឆ្នាំ២០០៨ទៅ២០១២។

នៅក្នុងឆ្នាំ២០១៣នេះទោះបីប្រឈមនឹងមានភាពមិនប្រក្រតីនៃបាតុភូតធម្មជាតិក៏ដោយដូចជាមានកង្វះទឹកនៅដើមរដូវ និងមានជំនន់ទឹកភ្លៀងនៅតាមតំបន់មួយចំនួនក៏ដោយ ក៏ស្ថានភាពបង្កបង្កើនផលនៅរដូវវស្សាឆ្នាំ ២០១៣ ជារួមមានកម្រិតល្អប្រសើរទូទាំងប្រទេស បានអនុវត្តលើសផែនការ ដោយការដាំដុះដំណាំស្រូវបានសរុបចំនួនប្រមាណ ២.៥៦២លានហិកតា ដោយមានទិន្នផល ២,៩២១ តោនក្នុង១ ហិកតា និងផ្ទៃដីដាំដុះនៅរដូវប្រាំងឆ្នាំ២០១៣-២០១៤ មានប្រមាណ០,៥ លានហិកតា និងទិន្នផលមធ្យម៤,៤០៥ តោន ក្នុង១ហិកតា ព្រមទាំងបរិមាណផលស្រូវសរុបប្រចាំទទួលបានប្រមាណ៩,៣៤ លានតោន។



*ពិធីសំណេះសំណាល ជាមួយប្រជាកសិករ របស់ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** ក្នុងឱកាសចុះពិនិត្យស្ថានភាពប៉ះពាល់ដោយទឹកជំនន់នៅខេត្តកណ្តាល*

ក្រាហ្វិកទី៣.ស្ថានភាពផលិតកម្មស្រូវឆ្នាំ២០០៣-២០១២




ប្រភព:ក្រសួងកសិកម្ម ខែមេសា២០១៣

បរិមាណនាំអង្ករចេញក្នុងរយៈពេលពីឆ្នាំ២០០៨ ដល់ឆ្នាំ ២០១៣ មានការកើនឡើងយ៉ាងរហ័ស ទៅក្នុងប្រទេសចំនួន៥៧ នៅលើសាកលលោក ដោយបរិមាណអង្ករនាំចេញមានចំនួន ៥.០០០តោន នៅក្នុងឆ្នាំ ២០០៨មានកើនឡើងដល់ជាង២០៥ ពាន់តោនក្នុងឆ្នាំ២០១២ និងនៅ ឆ្នាំ២០១៣ មានរហូតដល់ជាង១៧៩ ពាន់តោន។

### ខ.ផលិតកម្មដំណាំរួមផ្សំ ដំណាំឧស្សាហកម្ម

នៅក្នុងឆ្នាំ២០១២ កន្លងមកនេះ ផ្ទៃដីដាំដុះដំណាំរួមផ្សំ និងដំណាំកសិ-ឧស្សាហកម្មមានផ្ទៃដីដាំដុះសរុប ៩១២ពាន់ហិកតា ទទួលបានបរិមាណផលសរុបជាង ១០,៨៥ លានតោន ក្នុងនោះផ្ទៃដីដាំដុះដំណាំដំឡូងមីច្រើនជាងគេមាន ៣៩២ ពាន់ហិកតា និងទទួលបានបរិមាណផលសរុបចំនួនជាង៨លានតោន។ ដំណាំហូបផ្លែមានប្រមាណ២០០ ពាន់ហិកតា។

ក្រាហ្វិកទី៨.ផ្ទៃដីដាំដុះដំណាំបួនមុខ( ពោត ដំឡូងមី សណ្តែកបាយ និងសណ្តែកសៀង ) ឆ្នាំ ២០០៤-២០១២




ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

### គ.ផលិតកម្មដំណាំកៅស៊ូ

ការដាំដុះដំណាំកៅស៊ូមានសន្ទុះកើនឡើងជាលំដាប់ អាស្រ័យដោយមានការចូលរួមពីផ្នែកឯកជន និងផ្នែកកៅស៊ូ គ្រួសារ គួបផ្សំទៅនឹងតម្លៃកៅស៊ូធម្មជាតិនៅទីផ្សារខ្ពស់ សក្តានុពលដីសម្រាប់ដាំដុះដំណាំកៅស៊ូ ជាពិសេសគោលនយោបាយសេរីភាវូបនីយកម្មលើការលក់ផលិតផលកៅស៊ូគ្រួសារក្នុងស្រុក។ល។ នៅក្នុងឆ្នាំ២០១២ កន្លងទៅនេះ ដំណាំកៅស៊ូ បានដាំ

ក្រាហ្វិកទី៦. ផលិតកម្មដំណាំកៅស៊ូ និងការនាំចេញ ឆ្នាំ ២០០៧-២០១២




ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

ដុះនៅក្នុងខេត្តចំនួន១៩ លើផ្ទៃដីសរុបចំនួនជាង ២៨០ពាន់ហិកតា ក្នុងនោះផ្ទៃដីធ្វើអាជីវកម្មចំនួនជាង ៥៥,៣ ពាន់ហិកតា ដែលទទួលបានផលិតផលជ័រកៅស៊ូធម្មជាតិ សរុបចំនួន ជាង៦៤,៥ពាន់តោន និងនាំចេញផលិតផលកៅស៊ូស្ងួតប្រមាណជាង៦៩,៩ពាន់តោន។ តាមសន្ទុះកើនឡើងនេះរហូតដល់ឆ្នាំ ២០២០ ផ្ទៃដីដាំដុះកៅស៊ូនឹងកើនឡើងដល់ ៤០០ ពាន់ហិកតា និងបរិមាណជ័រកៅស៊ូធម្មជាតិ ប្រមាណ៣០០ពាន់តោនសម្រាប់នាំចេញ។




ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

## ៣. ផលិតកម្មសត្វ

វិស័យចិញ្ចឹមសត្វ ក៏មានតួនាទីសំខាន់ ក្នុងការចូលរួមចំណែកធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ កំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ។ ការចិញ្ចឹមសត្វបានចូលរួមដោយផ្ទាល់ ក្នុងតម្រូវការចំណីអាហារ និងបង្កើនប្រាក់ចំណូលគ្រួសារសម្រាប់ប្រជាជនកម្ពុជាដែលរស់នៅជនបទជាពិសេសកសិករតូចតាច។ ជាទូទៅផលិតកម្មមានកំណើន២% ក្នុង១ឆ្នាំ ដែលវិស័យនេះត្រូវបានខិតខំបន្ថែមទៀត សម្រាប់សម្រេចបានគោលដៅក្នុងការធានាការផ្គត់ផ្គង់ក្នុងស្រុកឲ្យបាន

ក្រាហ្វិកទី៧៖ ផលិតកម្មសត្វនៅកម្ពុជាឆ្នាំ ២០០៨-២០១២




ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

គ្រប់គ្រាន់ និងការធ្វើពាណិជ្ជកម្មក្នុងរយៈពេលមធ្យម និងវែង។ នៅកម្ពុជាមាននៅមានសក្ដានុពលច្រើនក្នុងការពង្រីកវិស័យចិញ្ចឹមសត្វ ដោយសារកម្ពុជា មានប្រភពចំណីសត្វច្រើន វាលស្មៅ និងអាកាសធាតុអំណោយផល។ ដោយកត្តានេះយើងបាន និងកំពុងជំរុញការវិនិយោគក្នុងវិស័យចិញ្ចឹមសត្វតាមរយៈផ្ដល់ជូនគ្រួសារកសិករខ្នាតតូចនូវកញ្ចប់សេវាកម្មនានា រួមមានបច្ចេកវិទ្យាពូជសត្វ ចំណីសត្វសេវាថែទាំសុខភាពសត្វ និងជីវសុវត្ថិភាពឥណទាន និងដំណោះស្រាយទីផ្សារ។ល។




ក្នុងឆ្នាំ ២០១២ កន្លងទៅនេះ ការចិញ្ចឹម គោក្របីចំនួនជាង ៤លានក្បាល ជ្រូកមាន ២,២ លានក្បាល និងបក្សីសរុបបានជាង២៣លានក្បាល និង មានការចិញ្ចឹមជាកសិដ្ឋានលក្ខណៈឧស្សាហកម្មបានចំនួនជាង៤,៩លានក្បាល។ ដោយឡែកមកដល់ពេល នេះមានភ្នាក់សុខភាពសត្វភូមិស្ម័គ្រចិត្តប្រមាណ១៤ពាន់នាក់ ត្រូវបានបណ្ដុះបណ្ដាល ហើយត្រូវបានផ្ដល់សេវាចាំបាច់បន្ទាន់លើ ផលិតកម្មសត្វនិងបសុសត្វទៅដល់កសិករនៅតាមមូលដ្ឋានភូមិ ឃុំ និងមានឡជីវឧស្ម័នចំនួន ២០ ពាន់ឡ។

## ៣.វិស័យជលផល

ត្រីនិងស្រូវអង្ករ ជាផ្នែកមួយនៃរបបអាហារប្រចាំថ្ងៃដ៏សំខាន់របស់ប្រជាជនកម្ពុជា។ ត្រីជាប្រភពស្បៀងអាហារ និងផ្ដល់ប្រូតេអ៊ីនសាច់យ៉ាងសំខាន់សម្រាប់ប្រជាជនកម្ពុជា។ ជលផល បានចូលរួមចំណែកមួយយ៉ាងសំខាន់ ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋក្រីក្រ និងបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ នៅឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការកែទម្រង់ស៊ីជម្រៅវិស័យជលផលជំណាក់កាលទី២ដោយសម្រេចលុបឡូត៍នេសាទទាំងអស់ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែង អភិរក្សជលផល។ ផលនេសាទប្រចាំឆ្នាំសរុបមានចំនួន៦៨២ ពាន់តោន កើនលើសឆ្នាំ

ក្រាហ្វិកទី៨៖ការអភិវឌ្ឍវិស័យជលផលឆ្នាំ ២០០៨-២០១២




ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣




មុនចំនួន៧៤ពាន់តោន ក្នុងនោះមាននេសាទសិប្បកម្ម នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារតាមវាលស្រែ នេសាទសមុទ្រ និងវារីវប្បកម្ម ក្នុងនោះដែរយើងបានបង្កើតកន្លែងភ្ញាស់ត្រីចំនួន២៩៦កន្លែង ផលិតកូនត្រីពូជបានចំនួន១៤០លានកូន។

សហគមន៍នេសាទ ៥១៦ សហគមន៍នេសាទដែលបានបង្កើតឡើង ដែលក្នុងនោះមានសហគមន៍នេសាទចំនួន៣២៨ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការ កំពុងចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិរក្សធនធានជលផល។

## ៤. វិស័យព្រៃឈើ

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបន្តអនុវត្តនូវដំណើរការកែទម្រង់វិស័យព្រៃឈើជាតិ ដោយបន្តជំរុញការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍព្រៃឈើប្រកបដោយនិរន្តរភាព។ នៅឆ្នាំ ២០១២នេះ បានរៀបចំឋានានុក្រមទិន្នន័យរូបភាព បានបោះបង្គោលព្រំប្រទល់ព្រៃឈើបានចំនួន៤.៩៦៨បង្គោល ដែលមានជាង ៧៥២ គីឡូម៉ែត្រ។ ក្នុងរយៈពេល៥ឆ្នាំ ២០០៨-២០១២ ការដាំសរុបបានជាង៨០ហិកតា ក្នុងដាំដោយរដ្ឋបាលព្រៃឈើចំនួន ៣.៨៣៨ហិកតា ជាលក្ខណៈគ្រួសារចំនួន ៦.១២០ ហិកតា និងក្នុងពិធីរុក្ខទិវាចំនួន ៣៣៦,៧៣ហិកតា។មកដល់នៅឆ្នាំ២០១២សហគមន៍ព្រៃឈើចំនួនសរុប ៤៥៣កន្លែង ស្មើនឹង ៣៩៩.៨៧៩ហិកតា ក្នុងនោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសទទួលស្គាល់សហគមន៍

ព្រៃឈើចំនួន៣៤២កន្លែងស្មើនឹង ៣០៨.៦០៣ហិកតា និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន២៤៦កន្លែងស្មើនឹង ២០៦.៤៤១ហិកតា។

**តារាង ការដាំឈើ និងសហគមន៍ព្រៃឈើ ឆ្នាំ ២០០៨-២០១២**

| ល.រ | ឆ្នាំដាំដុះ(ហត) | រដ្ឋបាលព្រៃឈើ (ហត) | កងទ័ព (ហត) | គ្រួសារ (ហត) | វត្តអារាម (ហត) | ក្រុមហ៊ុនឯកជន (ហត) | សរុប (ហត) |
|---|---|---|---|---|---|---|---|
| 1 | 2008 | 900 | 200 | 1,654 | 50.65 | 7,436 | **10,240.65** |
| 2 | 2009 | 1,000 | 0 | 385 | 69.00 | 17,924 | **19,378** |
| 3 | 2010 | 920 | 100 | 973.50 | 66.00 | 27,748 | **29,807.50** |
| 4 | 2011 | 530 | 0 | 314.50 | 67.50 | 3,590 | **4,502** |
| 5 | 2012 | 488 | 0 | 2,793 | 83.58 | 13,400 | **16,765** |
| **សរុប** | | **3,838** | **300** | **6,120** | **336.73** | **70,098** | **80,692.73** |

ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

**ក្រាហ្វិកទី៩៖ ការដាំឈើ និងសហគមន៍ព្រៃឈើ ឆ្នាំ ២០០៨-២០១២**




ប្រភព:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខែមេសា ឆ្នាំ២០១៣

## ៥. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក អ្វីៗដែលបានរៀបរាប់ខាងលើគឺជាសមិទ្ធផលដ៏ប្រសើរ ដែលសម្រេចបានក្នុងរយៈពេល៥ឆ្នាំ ពិសេសការអនុវត្តមានលក្ខណៈប្រទាក់ក្រឡាគ្នាប្រកបដោយប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា** ព្រមទាំងខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់

ជាន់ថ្នាក់ និងប្រជាកសិករ ដោយមានការគាំទ្រនិងចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍នានា វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានជួយឧបត្ថម្ភគាំទ្រនិងចូលរួមវិភាគទានយ៉ាងពេញទំហឹងក្នុងការលើកកម្ពស់ និងអភិវឌ្ឍន៍វិស័យកសិកម្មដែលជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។





# មតិសំណេះសំណាលរបស់ លោកជំទាវ ហោ ម៉ាលីន រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីប្រកាសក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣



*លោកជំទាវ **ហោ ម៉ាលីន** រដ្ឋលេខាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងពិធីប្រកាសក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម*

សូមគោរព :

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ ឯកឧត្តមទីប្រឹក្សា អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តម លោក លោកស្រីក្រុមប្រឹក្សាភិបាលអាណត្តិទី៤ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិក កម្មករ និងក្មួយៗនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មទាំងអស់ជាទីស្រឡាញ់រាប់អាន !

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយសនិងសេចក្តីសោមនស្សរីករាយជាអនេកប្បការ ដោយបានមកចូលរួមជាគណៈអធិបតីក្នុងពិធីប្រកាសក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងជួបសំណេះសំណាលជាមួយ លោក លោកស្រី សាស្ត្រាចារ្យ មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ បុគ្គលិក កម្មករ និងក្មួយៗនិស្សិត នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម នាពេលនេះ។ ក្នុងនាមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមពាំនាំយកនូវសេចក្តីនឹករលឹកដ៏ជ្រាលជ្រៅ និងការសាកសួរសុខទុក្ខ របស់សម្តេចចំពោះមន្ត្រីរាជការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិក កម្មករ ក៏ដូចជាការសិក្សារៀនសូត្ររបស់ក្មួយៗនិស្សិតគ្រប់ៗរូប ដែលជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិនាពេលអនាគត ដែលជានិច្ចកាល សម្តេចតែងតែយកចិត្តទុកដាក់ខ្ពស់ ដល់វិស័យកសិកម្ម និងការបណ្តុះបណ្តាលធនធានមនុស្សលើគ្រប់វិស័យ និយាយដោយឡែកវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

បន្ទាប់ពីបានស្តាប់ នូវរបាយការណ៍ របស់ឯកឧត្តម ង៉ោ ប៊ុនថាន សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្នុងនាមថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ មន្ត្រីសាស្ត្រាចារ្យ បុគ្គលិក និងកម្មករទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានខិតខំប្រឹងប្រែងតស៊ូរហូតសម្រេចបាននូវសមិទ្ធផលធំៗ ជាបន្តបន្ទាប់ក្នុងការកសាងនិងអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់វិស័យកសិកម្មដ៏មានសក្តានុពលរបស់យើង ហើយនេះគឺជាការឆ្លើយតបទៅនឹងប្រសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានលើកឡើងថា យើងមានភារកិច្ចចម្បងចាំបាច់ គឺត្រូវធ្វើឲ្យសម្រេចគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា។ យ៉ាងណាមិញ ការអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនបានលុះត្រាតែយើងខិតខំអភិវឌ្ឍន៍ធនធានមនុស្សឲ្យមានទាំងចំណេះដឹង ចំណេះធ្វើកាយសម្បទាមាំមួន មានសីលធម៌ល្អ ចរិយាសម្បត្តិល្អ គុណធម៌ថ្លៃថ្លា និង

ចេះរួមរស់ជាមួយគ្នាដោយសន្តិភាព។ ដើម្បីទទួលបាននូវធនធានមនុស្សបែបនេះ យើងត្រូវតែខិតខំ ផ្ដល់សេវាអប់រំដល់ប្រជាពលរដ្ឋគ្រប់រូប គ្រប់វ័យ តាមគ្រប់រូបភាព និងប្រកបដោយគុណភាពខ្ពស់ ពិសេសការផ្សារភ្ជាប់ទ្រឹស្ដីទៅនឹងការអនុវត្តជាក់ស្ដែងតាមគោលការណ៍អនុវត្តកសិកម្មល្អ ដែលកសិករអាចទទួលយកទៅអនុវត្តបាន។ រាជរដ្ឋាភិបាលយល់យ៉ាងច្បាស់ថា ការងារអភិវឌ្ឍធនធានមនុស្សគឺជាកត្តាស្នូលក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៤នៃរដ្ឋសភាកន្លងមកហើយជាពិសេសទៅទៀតនាពេលនេះ យើងកំពុងចាប់ផ្ដើមបន្តអនុវត្ត យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ។

ក្នុងន័យនេះ សាកលវិទ្យាល័យភូមិន្ទកសិកម្ម គឺជាគ្រឹះស្ថានអប់រំមានវ័យចំណាស់មួយក្នុងប្រទេសកម្ពុជា ដែលមកដល់ឆ្នាំនេះមានអាយុកាល៤៩ឆ្នាំហើយ ដូចបានរៀបរាប់ក្នុងរបាយការណ៍របស់ឯកឧត្តមសាកលវិទ្យាធិការ។ ជារួម សាកលវិទ្យាល័យមានបេសកកម្មបណ្ដុះបណ្ដាលធនធានមនុស្សគ្រប់កម្រិត ក្នុងវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និងវិស័យដីធ្លី ដើម្បីរួមចំណែក អនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា។ ធនធានមនុស្ស ដែលបានបណ្ដុះបណ្ដាលហើយនាពេលកន្លងមក បាននិងកំពុងបម្រើការងារយ៉ាងសកម្មក្នុងក្រសួងពាក់ព័ន្ធនានាដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងបរិស្ថាន ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។ល។ និង ក្រៅពីនេះមានបម្រើការងារនៅតាមអង្គការជាតិ-អន្តរជាតិ ក្រុមហ៊ុនឯកជននានា និងប្រកបរបរអាជីវកម្មផ្ទាល់ខ្លួន ។ល។

អង្គពិធីទាំងមូលជាទីមេត្រី !

ដូចដែលយើងទាំងអស់គ្នា បានដឹងស្រាប់ហើយថាៈ ភាពអត់ឃ្លាន របស់ប្រជាជនក្នុងពេលបច្ចុប្បន្នបានបង្កនូវក្ដីកង្វល់ យ៉ាងធំធេងដល់ពិភពលោក ដែលបានធ្វើឲ្យសភាពការណ៍នេះមានភាពខុសគ្នាពីទស្សនៈសហសវត្សរ៍ ដែលបានកំណត់ដោយអង្គការសហប្រជាជាតិកាលពីឆ្នាំ២០០០ គឺសំដៅយកឆ្នាំ២០១៥ ដើម្បីកាត់បន្ថយអ្នករងគ្រោះដោយការ



*លោកជំទាវ **ហោ ម៉ាលីន** រដ្ឋលេខាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីប្រកាសក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម*

អត់ឃ្លានឲ្យបានពាក់កណ្ដាល។ តាមការស្រាវជ្រាវបានឲ្យដឹងថា ឥឡូវនេះ ១/៦ នៃមនុស្សលោកបានទទួលរងទុក្ខដោយខ្វះអាហារូបត្ថម្ភ និងខ្វះស្បៀង មានអ្នកក្រប្រមាណ ៣/៤ នៃពិភពលោក រស់នៅដោយប្រកបរបរកសិកម្ម ហើយនេះជាចំណុចស្របមួយដែលបានបញ្ជាក់ថា : ប្រសិនបើគេចង់ដោះស្រាយបញ្ហាក្រីក្រក្នុងពិភពលោក គឺគេត្រូវផ្ដោតលើវិស័យកសិកម្មជាចម្បង។

ជាទូទៅការផ្គត់ផ្គង់ស្បៀងដល់ប្រជាជននៅលើពិភពលោកនេះ គឺជាបញ្ហាសំខាន់ ជាពិសេសក្នុងកាលៈទេសៈដែលកើតមានវិបត្តិសេដ្ឋកិច្ចសាកល ដែលប្រទេសកម្ពុជាយើងក៏ទទួលរងនូវផលប៉ះពាល់ក្នុងវិស័យផ្សេងៗផងដែរ។ ក៏ប៉ុន្តែវិស័យកសិកម្មនៅតែដំណើរការបានរលូនល្អដូចធម្មតា រហូតសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈ ហើយដែល សម្ដេចតេជោនាយករដ្ឋមន្ត្រី បានចាត់ទុកវិស័យកសិកម្មថាជាវិស័យអាទិភាពគ្រប់កាលៈទេសៈ។ ជាក់ស្ដែង ឯកឧត្តមសាកលវិទ្យាធិការក៏បានបង្ហាញរួចហើយ អំពីប្រវត្តិនៃការខិតខំប្រឹងប្រែងបើកគ្រឹះស្ថានឧត្តមសិក្សារបស់ក្រសួងកសិកម្ម ដោយចាប់ផ្ដើមពីវិទ្យាស្ថានបច្ចេកទេសកសិកម្មរហូតដល់សាកលវិទ្យាល័យ និងក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរួមចំណែកបណ្ដុះបណ្ដាលធនធានមនុស្សបម្រើឲ្យការអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា។ ក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩ យើងបានសុំជំនួយសាស្ត្រាចារ្យពីអតីតសហភាពសូវៀត រៀនជាភាសារុស្ស៊ី បង្រៀនដល់និស្សិតកសិកម្ម ហើយមកដល់



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីប្រកាសក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

បច្ចុប្បន្ននេះ យើងមានសមត្ថភាពគ្រប់គ្រាន់អាចម្ចាស់ការបានក្នុងការអភិវឌ្ឍន៍ និងគ្រប់គ្រងសាកលវិទ្យាល័យ ដោយខ្លួនយើង ដោយមានកម្មវិធីសិក្សាត្រឹមត្រូវ មានគ្រូបង្រៀនខ្លួនយើងផ្ទាល់ មានការទទួលស្គាល់ពីស្ថាប័នជាតិ និង អន្តរជាតិ ហើយជាពិសេសយើងមានសាស្ត្រាចារ្យ សាស្ត្រាចារ្យរងក្នុងវិស័យកសិកម្ម ដែលបានតែងតាំងដោយរាជរដ្ឋាភិបាល កម្ពុជានាឆ្នាំ២០១២ កន្លងមកថ្មីៗផងដែរ។

អង្គពិធីទាំងមូលជាទីមេត្រី !

សាកលវិទ្យាល័យភូមិន្ទកសិកម្មបានដំណើរការរបស់ខ្លួន ស្ថិតក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល ចាប់តាំងពីសាកលវិទ្យាល័យបានក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាលនាចុងឆ្នាំ១៩៩៩ ដែលមកដល់ពេលនេះមានក្រុមប្រឹក្សាភិបាល៣អណត្តិរួចមកហើយ បានបញ្ចប់បេសកកម្មរបស់ខ្លួន។ ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមអរគុណចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចាត់តាំងតំណាងរបស់ខ្លួន ឲ្យចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មគ្រប់អណត្តិកន្លងមក និងក្នុងអណត្តិថ្មី អាណត្តិទី៤នេះ។ ខ្ញុំសូមកោតសរសើរ ចំពោះក្រុមប្រឹក្សាភិបាលគ្រប់អណត្តិទាំងអស់ដែលបានជួយជ្រោមជ្រែងយ៉ាងពេញទំហឹង ក្នុងការដឹកនាំតម្រង់ទិសប្រកបដោយស្មារតីស្ថាបនានិងទទួលខុសត្រូវខ្ពស់ញ៉ាំងឲ្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម មានឲ្យដំណើរការបានរលូន និងទទួលបានជោគជ័យល្អ ក្នុងការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និង រៀបចំដែនដី ។

ដោយឡែក ថ្ងៃនេះទៀតសោត ជាថ្ងៃដែលយើងទាំងអស់គ្នាសប្បាយរីករាយ និងអបអរសាទរ ក៏ដូចជាទទួលស្វាគមន៍ចំពោះក្រុមប្រឹក្សាភិបាលថ្មី នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្នុងឱកាសដែលរាជរដ្ឋាភិបាលកម្ពុជាផ្តល់ការទុកចិត្តដល់ឯកឧត្តម លោក លោកស្រីទាំង១១រូប ក្នុងអណត្តិទី៤នេះ។ ខ្ញុំសង្ឃឹមថា ក្រោយពីទទួលបាននូវភារកិច្ចថ្មីនេះ ឯកឧត្តម លោក លោកស្រីសមាជិក សមាជិកាក្រុមប្រឹក្សាភិបាលទាំងអស់ ពិតជាមានការទទួលខុសត្រូវ និងយកចិត្តទុកដាក់ខ្ពស់ក្នុងការដឹកនាំសាកលវិទ្យាល័យ ឲ្យកាន់តែមានការរីកចម្រើនទាំងបរិមាណនិងគុណភាព។ ជាពិសេស ជំរុញការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសិក្សា ឲ្យមានភាពជឿនលឿនសមស្រប តាមសេចក្តីត្រូវការ របស់សាស្ត្រាចារ្យនិងនិស្សិត និងជំរុញផ្នែកបច្ចេកទេសវិទ្យាសាស្ត្រត់ឲ្យទាន់សភាពការណ៍រីកចម្រើននៃសេដ្ឋកិច្ចជាតិ និងក្នុងតំបន់។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនសម្រាប់ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រីសាស្ត្រាចារ្យ បុគ្គលិក និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ធ្វើការត្រិះរិះពិចារណានិងអនុវត្តឲ្យបានល្អប្រសើរមានដូចខាងក្រោម ៖

១. ក្រុមប្រឹក្សាភិបាលត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការដឹកនាំ ជាពិសេសត្រូវប្រជុំពិនិត្យ ដោះស្រាយការងារឲ្យបានទៀងទាត់តាមកាលកំណត់ និងតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

២. មន្ត្រីរាជការ សាស្ត្រាចារ្យបុគ្គលិកនៃសាកលវិទ្យាល័យទាំងមូល ត្រូវមានស្មារតីសាមគ្គីភាព ឯកភាពគ្នា និង




សកម្មភាពថតរូបអនុស្សាវរីយ៍ក្នុងពិធីប្រកាសក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

ភាពស្មោះត្រង់ជាមួយគ្នា ជាពិសេសត្រូវអនុវត្តឲ្យបាន តាមប្រសាសន៍របស់ សម្ដេចតេជោនាយករដ្ឋមន្ត្រី គឺត្រូវចេះដុះក្អែលខ្លួនឯងឲ្យបានស្អាត និងត្រូវចេះព្យាបាលជំងឺ។

៣. សាកលវិទ្យាល័យត្រូវបន្តយកចិត្តទុកដាក់ការអភិវឌ្ឍន៍លើកកម្ពស់សមត្ថភាព សាស្ត្រាចារ្យ និងគ្រូបង្រៀនទាំងអស់ជាប្រចាំទាំងកម្រិតសញ្ញាបត្រ ទាំងចំណេះដឹងផ្នែកទ្រឹស្ដី និងការអនុវត្តន៍ជាក់ស្ដែង។ យើងតោងគិតផងដែរថា ដើម្បីអភិវឌ្ឍកសិកម្មគឺទាមទារឲ្យមានធនធានមនុស្សប្រកបដោយគុណភាពទាំងចំណេះដឹងនិងចំណេះធ្វើ រួមទាំងសីលធម៌វិជ្ជាជីវៈខ្ពស់ ជាពិសេសត្រូវប្រមើលមើលអំពីទិសដៅយុរអង្វែងរបស់យើងក្នុងការធ្វើសមាហរណកម្ម ទៅក្នុងសហគមន៍អាស៊ាននាឆ្នាំ២០១៥ ខាងមុខនេះ។ ដូច្នេះ ការពង្រឹកគុណភាពអប់រំឲ្យបានសមស្របគ្រប់កម្រិតសិក្សាតាមមុខជំនាញនីមួយៗតាមនិយាមជាតិនិងអន្តរជាតិ គឺជាកិច្ចការអាទិភាពដែលយើងទាំងអស់គ្នាត្រូវគិតគូរជាចម្បង។ ពិតណាស់ថាគ្មានការស្រាវជ្រាវ គឺគ្មានការអភិវឌ្ឍន៍ ហើយត្រូវយកទ្រឹស្ដីផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្ដែង។

៤. បន្តជ្រើសរើសគ្រូបង្រៀនទាំងពេញម៉ោង និងមិនពេញម៉ោងដែលមានសមត្ថភាពនិងមានគុណវុឌ្ឍិគ្រប់គ្រាន់ ធ្វើសំណើមកក្រសួងដើម្បីស្នើសុំផ្ដល់ឋានៈជាសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង ឬ សាស្ត្រាចារ្យ ដែលនេះជាការលើកទឹកចិត្តមួយដ៏ធំធេង សម្រាប់អាជីពគ្រូបង្រៀនកសិកម្មរបស់យើង។

៥. សាកលវិទ្យាល័យត្រូវខិតខំយកចិត្តទុកដាក់ ពង្រឹង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសិក្សា ជាពិសេសបន្ទប់ពិសោធន៍ និងកន្លែងស្រាវជ្រាវត្រូវមានមធ្យោបាយសម្ភារ ឧបករណ៍ពិសោធន៍ និងសារធាតុគីមីគ្រប់គ្រាន់ ដើម្បីផ្ដល់លទ្ធភាពឲ្យនិស្សិតបានសិក្សារៀនសូត្រត្រឹមត្រូវ និងតាមកម្មវិធីសិក្សាច្បាស់លាស់ស្របតាមគោលការណ៍ទ្រឹស្ដីផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្ដែង។

៦. ត្រូវបន្តជំរុញការយកចិត្តទុកដាក់ខ្ពស់ លើការងារសហប្រតិបត្តិការអន្តរជាតិ ជាពិសេសជាមួយសាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំល្បីៗលើពិភពលោក ដើម្បីផ្លាស់ប្ដូរបច្ចេកទេសវិទ្យាសាស្ត្រថ្មីៗ។



*សកម្មភាពជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាភិបាល ក្នុងពិធីប្រកាសក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម*

៧. សាកលវិទ្យាល័យត្រូវខិតខំអនុវត្ត និងបំពេញឲ្យបានគ្រប់ជ្រុងជ្រោយនូវរាល់ចំណុចខ្វះខាតទាំងឡាយ ដែលគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គទក) បានវាយតម្លៃលើស្តង់ដារទាំង៩ ដែលរួមមាន ស្តង់ដារទី១បេសកកម្ម ស្តង់ដារទី២រចនាសម្ព័ន្ធគ្រប់គ្រង ការគ្រប់គ្រង និងគម្រោងផែនការ ស្តង់ដារទី៣កម្មវិធីសិក្សា ស្តង់ដារទី៤បុគ្គលិកសិក្សា ស្តង់ដារទី៥និស្សិតនិងសេវាកម្មសម្រាប់និស្សិត ស្តង់ដារទី៦សេវាសិក្សា ស្តង់ដារទី៧ ទីតាំងសម្ភាររូបវន្ត ស្តង់ដារទី៨គម្រោងផែនការនិងការគ្រប់គ្រងថវិកា និងស្តង់ដារទី៩ការផ្សព្វផ្សាយព័ត៌មាន។

៨. សាស្ត្រាចារ្យ និងគ្រូបង្រៀនគ្រប់រូប ត្រូវយកចិត្តទុកដាក់ដុសខាត់ពង្រឹងជំនាញឯកទេសរបស់ខ្លួនឲ្យបានរឹងមាំល្អនិងច្បាស់លាស់ និងជាពិសេសត្រូវខិតខំរួមចំណែកបោះពុម្ពឯកសារ ឬសៀវភៅវិទ្យាសាស្ត្រផ្សេងៗ ពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន ដើម្បីផ្សព្វផ្សាយ ក៏ដូចជាសម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងម៉្យាងទៀតត្រូវធ្វើជាគំរូល្អលើការគោរពវិន័យ សេចក្ដីថ្លៃថ្នូ និងសីលធម៌សង្គមផងដែរ។

មុននឹងបញ្ចប់ពិធីប្រកាសក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មអាណត្តិទី៤នេះ ខ្ញុំសូមគោរពជូនពរគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវកិត្តិយស ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រីសាស្ត្រាចារ្យ និងក្មួយៗនិស្សិតទាំងអស់ សូមជួបប្រទះតែនឹងពុទ្ធពរ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# ផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង ក្នុងបរិបទប្រែប្រួល អាកាសធាតុ វេទិកាកសិករថ្នាក់ជាតិលើកទី៤

ក្រោមប្រធានបទ " រួមគ្នាធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពបន្សាំ នៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានានូវសន្តិសុខស្បៀង" នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ ថ្ងៃទី១៧ ១៨ ខែ តុលា ឆ្នាំ ២០១៣

ដោយបណ្ឌិត ម៉ាក់ សឿន ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ១. សេចក្តីផ្តើម

ការប្រែប្រួលការធាតុជាបញ្ហាសាកល ដែលកើតមានឡើងយ៉ាងច្បាស់ និងមានឥទ្ធិពលលើផលិតកម្មស្បៀងអាហារនៅក្នុងបណ្តាប្រទេសមួយចំនួនលើសាកលលោក ដោយការកើតមានឡើង៖ ការកើនឡើងកំដៅ ទឹកជំនន់ រាំងស្ងួត ភ្លៀងមិនទៀងទាត់ សត្វល្អិត ជំងឺ ការកើនឡើងកម្ពស់ទឹកប្រៃហូរចូលដីស្រែ ចំការ។ល។ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទទួលរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុរួចមកហើយតាមរយៈការកើតឡើងពីភាពប្រក្រតីនៃអាកាសធាតុ ដូចជាមានព្រឹត្តិការណ៍ទឹកជំនន់ ភាពរាំងស្ងួត សត្វល្អិត និងជំងឺបំផ្លាញ ខ្យល់ព្យុះ ការកើនឡើងកម្ពស់ទឹកសមុទ្រ ដែលបណ្តាលឲ្យមានផលិតភាពកសិកម្មទាប និងមានផលប៉ះពាល់ដល់សន្តិសុខស្បៀង និងភាពក្រីក្រ ដោយមានឆ្នេរសមុទ្រវែងរហូតដល់ ៤៣៥គីឡូម៉ែត្រ និងមានរយៈកម្ពស់ទាប ផ្ទៃដីវាលទំនាបតាមអាងទន្លេគង្គក្រោម តំបន់ទន្លេសាប ហើយមានប្រជាពលរដ្ឋរស់នៅច្រើន និងមានសកម្មភាពសេដ្ឋកិច្ចពឹងផ្អែកលើមុខរបរកសិកម្ម ធនធានជលផល ព្រៃឈើ និងធនធានធម្មជាតិ ហើយមានផ្ទៃដីស្រែទំនាបពឹងដោយរបបទឹកភ្លៀង ប្រមាណជាង ២.៥លានហិកតា។



វិស័យកសិកម្មបានទទួលរងពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ តែវិស័យកសិកម្មក៏បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបន្សាំ បង្កើនភាពធន និងបន្ធូរបន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុដើម្បីធានាប្រព័ន្ធផលិត ចែកចាយ និងផ្គត់ផ្គង់ស្បៀង មាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមរយៈការប្រើប្រាស់ និងការអនុវត្តល្អប្រសើរនៃបច្ចេកវិទ្យាកសិកម្ម៖ ពូជដំណាំ ពូជសត្វ ការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ ប្រពលវប្បកម្មដំណាំ សត្វ ច្បារដំណាំគ្រួសារ កសិកម្មអភិរក្ស ប្រព័ន្ធដំណាំស្បៀង និងថាមពលចម្រុះ ការប្រើប្រាស់ថាមពលទាបនៃប្រព័ន្ធវារីវប្បកម្ម ប្រព័ន្ធគ្រប់គ្រងព្រៃឈើ ដី និងទឹកមាននិរន្តរភាព និងក្សេត្រ រុក្ខកម្ម។ល។ ដើម្បីបម្រើឲ្យគ្រប់ទិដ្ឋភាពទាំងអស់នៃប្រព័ន្ធស្បៀងមួយមានប្រសិទ្ធភាពដោយផ្ដោតលើភាពមានស្បៀងគ្រប់គ្រាន់ និងការទទួលបានស្បៀង ស្បៀងមានអាហារូបត្ថម្ភគ្រប់គ្រាន់ ហើយផ្ដោតលើអ្នកប្រើប្រាស់មានលទ្ធភាពជ្រើសរើសទៅតាមតម្រូវការគុណភាពរបបអាហារហូបចុកមានសុខភាព។

## ២. ផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង

ស្ថិតក្នុងបរិបទតម្រូវការស្បៀងអាហារ កង្វះអាហារូបត្ថម្ភ និងកំណើនប្រជាជននៅលើសាកលលោក វិស័យកសិកម្មនៅតែដើរតួនាទីសំខាន់ក្នុងចីរភាពកំណើនសេដ្ឋកិច្ច និងសេដ្ឋកិច្ច-សង្គម ដែលបានផ្ដល់ដល់ប្រជាពលរដ្ឋក្រីក្រ អ្នកជួបបញ្ហាអសន្តិសុខស្បៀងអាហារ ព្រមទាំងប្រជាជនជួបប្រទះនឹងភាពអត់ឃ្លាន ប្រមាណ១ពាន់លាននាក់នៅលើសាកលលោក ដោយវិស័យកសិកម្មផ្ដល់នូវស្បៀងអាហារ វត្ថុធាតុសរសៃ និងថាមពល (Fibre and Energy) សម្រាប់តម្រូវការកើនឡើងយ៉ាងរហ័សរបស់ប្រជាពលរដ្ឋនៅជនបទ និងទីក្រុង សម្រាប់ជីវភាពរស់នៅ និងតម្រូវការរបបហូបចុកប្រចាំថ្ងៃ។ បច្ចុប្បន្ននេះនៅលើសាកលលោក ផលិតកម្មកសិកម្ម និងបញ្ហាសន្តិសុខស្បៀង ប្រឈមមុខនឹងតម្រូវការស្បៀងអាហារច្រើន តាមតម្រូវការកំណើនប្រជាជនយ៉ាងរហ័សជាពិសេសនៅតំបន់ទីក្រុង និងជាយក្រុង ការរងសម្ពាធលើធនធានធម្មជាតិ ការបម្រែបម្រួលអាកាសធាតុ និងការប្រកួតប្រជែងទីផ្សារផលិតផលកសិកម្ម។ល។

វិស័យកសិកម្មបានផ្ដល់និងផ្គត់ផ្គង់នូវគ្រាប់ធញ្ញជាតិសម្រាប់ស្បៀងអាហារ និងចំណីសត្វ ចំណីអាហារដែលមានប្រភពមកពីសត្វមានដូចជាផលិតផលសាច់ ស៊ុត ទឹកដោះ ត្រី និងវារីវប្បកម្ម ក៏ដូចជាប្រេងឆា។ល។ តម្រូវការបង្កើនផលិតកម្មស្បៀងអាហារ ក៏មានតម្រូវការកម្លាំងពលកម្មច្រើននៅជនបទ ការទទួលយកវិធីសាស្ត្រ



ផលិតកម្មមានប្រសិទ្ធភាពខ្ពស់ និងមានចីរភាព ព្រមទាំងវិធីសាស្ត្របន្សាំ និងបន្ធូរបន្ថយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការប្រើប្រាស់វិធីសាស្ត្រប្រព័ន្ធបច្ចេកទេសចម្រុះ និងជាយុទ្ធសាស្ត្រមួយចាំបាច់សម្រាប់ដោះស្រាយធានានូវបរិមាណ និងគុណភាពស្បៀងអាហារទាំងនៅទីក្រុង ជាយក្រុង និងជនបទ តាមរយៈខ្សែសង្វាក់ផ្គត់ផ្គង់ស្បៀងអាហារឆាប់រហ័ស ការទំនាក់ទំនងដ៏រឹងមាំរវាងទីក្រុងនឹងជនបទ និងធានាការគ្រប់គ្រងបាននូវធនធានធម្មជាតិ ព្រមទាំងវិធានការត្រៀមបម្រុងនឹងការប្រែប្រួលអាកាសធាតុ។



នៅកម្ពុជានាពេលបច្ចុប្បន្ន និងពេលអនាគត វិស័យកសិកម្មនៅតែដើរតួនាទីសំខាន់ក្នុងការជំរុញការផលិតក្នុងស្រុក ការបង្កើតការងារ និងកែលម្អជីវភាពរស់របស់ប្រជាពលរដ្ឋ ធានាបាននូវចីរភាពកំណើនសេដ្ឋកិច្ច ការកែលម្អសន្តិសុខស្បៀង និងពន្លឿនការកាត់បន្ថយភាពក្រីក្រ។ វិស័យកសិកម្មបានចូលរួមចំណែកក្នុងផលិតផលសរុបក្នុងស្រុកប្រមាណ ២៧,៥ភាគរយនៅឆ្នាំ ២០១២ និងបានរក្សាកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណពី៤ទៅ៥ភាគរយនៅចន្លោះឆ្នាំ ២០០៦-២០១២។ នៅឆ្នាំ២០១២ វិស័យកសិកម្មមានកំណើនជាមធ្យមប្រមាណ៤.៣% ក្នុងនោះមានការចូលរួមពីអនុវិស័យដំណាំកសិកម្មមានប្រមាណ៥៤.៨% ជលផល ២៥.៤% ផលិតកម្មសត្វ ១៤.១%និងអាជីវកម្មព្រៃឈើមាន៥.៧%។ នេះជាសមិទ្ធផលដែលសម្រេចបាន តាមរយៈទទួលយកទៅប្រើប្រាស់នូវបច្ចេកវិទ្យាសមស្រប ធាតុចូលនិងសេវាគាំទ្រផ្សេងៗទៀតក្នុងចំណោមប្រជាកសិករ។

ជាក់ស្តែងក្នុងឆ្នាំ២០១២កន្លងមកនេះ វិស័យផលិតកម្មដំណាំមាន៖ ផលិតស្រូវបានសរុបចំនួនប្រមាណ ៩,៣លានតោន និងមានសល់ស្បៀងអាហារក្រៅពីហូបចុកគិតជាស្រូវប្រមាណ ៤,៧លាន និងគិតជាអង្ករសល់ប្រមាណ៣លានតោនសម្រាប់នាំចេញ។ ដំណាំផ្សេងៗទៀតដូចជាដំណាំបន្លែ ឈើហូបផ្លែ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មក៏បានកើនឡើងគួរឲ្យកត់សម្គាល់ដែរ ក្នុងនោះផ្ទៃដីដាំណាំកៅស៊ូបានកើនឡើងជិត ៣០០ពាន់ហិកតា។

ក្រៅពីផលិតកម្មដំណាំកសិកម្ម វិស័យចិញ្ចឹមសត្វនិងជលផល ក៏មានតួនាទីសំខាន់ ក្នុងការចូលរួមចំណែកធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ កំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ។ ការចិញ្ចឹមសត្វបានចូលរួមដោយផ្ទាល់ ក្នុងតម្រូវការចំណីអាហារ និងបង្កើនប្រាក់ចំណូលគ្រួសារសម្រាប់ប្រជាជនកម្ពុជាដែលរស់នៅជនបទ ជាពិសេសកសិករតូចតាច។ ជាទូទៅផលិតកម្មមានកំណើន២%ក្នុង១ឆ្នាំ ដែលវិស័យនេះត្រូវបានខិតខំ



បន្ថែមទៀត សម្រាប់សម្រេចបានគោលដៅក្នុងការធានាការផ្គត់ផ្គង់ក្នុងស្រុកឲ្យបាន គ្រប់គ្រាន់ និងការធ្វើពាណិជ្ជកម្មក្នុងរយៈពេលមធ្យម និងវែង។ នៅកម្ពុជាមាននៅមានសក្តានុពលច្រើនក្នុងការ ពង្រីកវិស័យចិញ្ចឹមសត្វ ដោយសារកម្ពុជាមានប្រភពចំណីសត្វច្រើន វាលស្មៅ និងអាកាសធាតុ អំណោយ ផល។ ដោយកត្តានេះ យើងបាន និងកំពុងជំរុញការវិនិយោគក្នុងវិស័យចិញ្ចឹមសត្វ តាមរយៈផ្តល់ជូនគ្រួសារ កសិករខ្នាតតូច នូវកញ្ចប់សេវាកម្មនានា រួមមានបច្ចេកវិទ្យា ពូជសត្វ ចំណីសត្វ សេវាថែទាំសុខភាពសត្វ និង ជីវសុវត្ថិភាព ឥណទាន និងដំណោះស្រាយទីផ្សារ។ល។ ដែលមានដល់ពេលនេះមានភ្នាក់សុខភាពសត្វ ភូមិស្ម័គ្រចិត្តប្រមាណ១៤ពាន់នាក់ ត្រូវបានបណ្តុះបណ្តាល ហើយត្រូវបានផ្តល់សេវាចាំបាច់ បន្ទាន់លើ ផលិតកម្មសត្វ និងបសុសត្វទៅដល់កសិករ តាមមូលដ្ឋានភូមិ ឃុំ។

ត្រី និងស្រូវអង្ករ ជាផ្នែកមួយនៃរបបអាហារប្រចាំថ្ងៃដ៏សំខាន់របស់ប្រជាជនកម្ពុជា។ ត្រី ជាប្រភពស្បៀងអាហារ និងផ្តល់ប្រូតេអ៊ីនសាច់យ៉ាងសំខាន់ សម្រាប់ប្រជាជនកម្ពុជា។ ជលផល បានចូលរួមចំណែកមួយយ៉ាងសំខាន់ ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋក្រីក្រ និងបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។កន្លងមកផលនេសាទប្រចាំឆ្នាំ ដែលមានទាំងផលនេសាទទឹកសាប ទាំងសមុទ្រ និងផលិតផលវារីវប្បកម្ម មានចំនួនសរុបពី



៤០០ពាន់ ទៅ៦០០ពាន់តោន និងបានចូលរួមប្រមាណ១២%នៃផលទុនក្នុងស្រុក។ ការនេសាទតាមវាលស្រែជាផ្នែកមួយសំខាន់ ក្នុងការបង្កើនផលចាប់ ដែលមានរហូតដល់២៨% នៃផលនេសាទសរុបនៅកម្ពុជា ហើយបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងតម្រូវការអាហារប្រចាំថ្ងៃ។ លើសពីនេះទៅទៀត ស្រះជំរកត្រី ដែលត្រូវបានបង្កើតតាមភូមិ ឃុំ សម្រាប់បង្កើនផលិតត្រីប្រកបដោយនិរន្តរភាព និងអាចជួយផ្តល់សារសំខាន់ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ក្នុងការធ្វើនេសាទក្នុងដែលសារធារណៈ ជាពិសេសប្រជាពលរដ្ឋក្រីក្រ ក្នុងការនេសាទសម្រាប់ស្បៀងអាហារ និងប្រាក់ចំណូលក្នុងគ្រួសារ។

ជារួមវិស័យកសិកម្ម បានផ្តល់នូវប្រព័ន្ធផលិតកម្ម ចែកចាយ និងផ្គត់ផ្គង់ស្បៀងអាហារប្រកបនិរន្តរភាព និងសុវត្ថិភាព សម្រាប់ស្បៀងអាហារ និងអាហារូបត្ថម្ភរបស់ប្រជាជន ស្របតាមទិវាស្បៀងអាហារពិភពលោក ឆ្នាំ២០១៣ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៦ ខែ តុលា ២០១៣នេះ ក្រោមប្រធានបទ” ប្រព័ន្ធស្បៀងមាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ"។ ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខស្បៀងនេះ ប្រទេសកម្ពុជាបានទទួលជោគជ័យ ដោយសម្រេចបាននូវគោលដៅទី១ នៃគោលដៅសហសវត្ស ក្នុងការប្រយុទ្ធនឹងភាពក្រីក្រ និងអត់ឃ្លាន ក្នុងចំណោមប្រទេស៣៨ នៅលើសាកលលោក ដោយបានទទួលប័ណ្ណទទួលស្គាល់សមិទ្ធផលប្រយុទ្ធនឹងភាពអត់ឃ្លាននៃគោលដៅសហសវត្សគិតត្រឹមឆ្នាំ២០១២ មុនគោលដៅសហសវត្ស៣ឆ្នាំ ពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) នាខែមិថុនា ឆ្នាំ២០១៣។

## ៣. បញ្ហាប្រឈម

ទោះបីវិស័យកសិកម្មកម្ពុជាមានសក្តានុពល កាលនុវត្តភាព និងឧត្តមភាពប្រៀបធៀបក្នុងតំបន់យ៉ាងណាដ៏ដោយ ក៏យើងនូវមានបញ្ហាប្រកួតប្រជែងទីផ្សារកសិផលនៅក្នុងតំបន់ និងនៅលើសាកលលោក ដូចជាបញ្ហាខ្វះខាតលើបច្ចេកទេសវិទ្យាសម្រាប់លើកំពស់បរិមាណ និងគុណភាពផលិតផលកសិកម្ម និងមធ្យោបាយ កែច្នៃកសិផល ខ្វះខាតវត្ថុធាតុដើមសម្រាប់កែច្នៃចំណីសត្វ និងខ្វះការផ្គត់ផ្គង់ឥណទានដល់កសិករ ក្នុងផលិតកម្មដំណាំកសិកម្ម និងចិញ្ចឹមសត្វ ប្រព័ន្ធ និងមធ្យោបាយស្រោចស្រពសម្រាប់កសិកម្មនៅមានកំរិត សម្ពាធលើធនធានធម្មជាតិមាន៖ដី ទឹក ធនធានជលផល ធនធានព្រៃឈើ និងជីវសាស្ត្រចម្រុះ និងការ ប្រែប្រួលអាកាសធាតុមានការកើនឡើងកំដៅ ទឹកជំនន់ រាំងស្ងួត ភ្លៀងមិនទៀងទាត់ សត្វល្អិត ជំងឺ ការកើនឡើងកម្ពស់ទឹកប្រៃហូរចូលដីស្រែ ចំការ។

## ៤. វិធានការបន្សាំ ភាពធន់នឹងការប្រែប្រួលអាកាសធាតុ

ដើម្បីពង្រឹងសមត្ថភាពបន្សាំ ភាពធន់ និងបន្ធូរបន្ថយនឹងការប្រែប្រួលអាធាតុ ដើម្បីធានានិរន្តរភាពស្បៀងសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលនានា វិស័យឯកជន បានមានវិធានការ និងអនុវត្តកម្មវិធី គម្រោង និងសកម្មភាពនានាទាក់ទងនឹងការបង្កើនផលិតកម្មស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ តាមរយៈបង្កើនផលិតភាព ពិពិធភាវូបនីយកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ព្រមទាំងការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិមានប្រកបដោយនិរន្តរភាព និងការប្រើប្រាស់ថាមពលកកើតឡើងវិញដោយ៖

## ៤. វិធានការបន្សាំ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ

### ៤.១.ការគ្រប់គ្រងដំណាំ

ក. ការអភិវឌ្ឍ និងប្រើប្រាស់ពូជដំណាំមានទិន្នផលខ្ពស់ ធន់នឹងការរាំងស្ងួត ទឹកជំនន់ ដីប្រៃ មានអាយុ

កាលខ្លី ពូជត្រូវការទឹកតិច និងពូជមានប្រព័ន្ធឫសវែង។ល។ ដូចពូជថ្មីៗដែលមានបញ្ចេញឲ្យប្រើប្រាស់ក្នុងផលិតកម្មស្រូវ មានពូជសែនពិដោរ អ៊ីអ៊ែ៦៦ ជលសារ ពូជផ្ការំដួល ផ្ការំដេង និងផ្ការមៀត ព្រមទាំងពូជរាំងជ័យ ពូជខា៤ និងពូជខា៦។

ខ. ការកែលំអផលិតដំណាំមានដំណាំស្រូវ ដំណាំបន្លែ ដំណាំរួមផ្សំ និងដំណាំឈើហូបផ្លែដោយប្រើប្រាស់ពូជធន់ និងកែលំអបច្ចេកទេសដាំដុះ និងប្រសិទ្ធភាពគ្រប់គ្រងដំណាំ (គ្រប់គ្រងទឹកសារធាតុចិញ្ចឹមដំណាំ សត្វល្អិត និងជំងឺ ស្មៅ) និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងបច្ចេកទេសក្រោយប្រមូលផល។ ជំរុញអនុវត្តប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ(ប.វ.ស) និងវិធានការចម្រុះគ្រប់គ្រងដំណាំ។

គ. ការកែលម្អការគ្រប់គ្រងដី និងជីជាតិដីៈ បង្កើនប្រសិទ្ធភាពជីជាតិ(សារធាតុចិញ្ចឹម)ដំណាំដូចជាប្រសិទ្ធភាពជីអាសូត ជីធម្មជាតិមានពពួកសណ្តែក ជីស្រស់ ជីកំប៉ុស្ត ជីលាមកសត្វ ព្រមទាំងគ្រប់គ្រងដី និងជីសរីរាង្គឲ្យបានត្រឹមត្រូវ។ ជំរុញការប្រើប្រាស់ជីតាមតម្រូវការជាក់លាក់របស់ដំណាំ ដោយអនុវត្ត Site Specific Nutrient Management (SSNM)។ និងបង្កើនសារធាតុសរីរាង្គនៅក្នុងដី។ល។

ឃ. ការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ អនុវត្តពិពិធកម្មកសិកម្មក្នុងកសិដ្ឋាន ស្រែចំការតាមគ្រួសារ មានដំណាំស្រូវ ដំណាំរួមផ្សំ ដំណាំឈើហូបផ្លែ ដំណាំពហុប្រយោជន៍ ចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈគ្រួសារ រោងជីកំប៉ុស្ត និងឡជីវឧស្ម័ន។ល។

ង. ការអនុវត្តកសិកម្មអភិរក្សៈ ការអនុវត្តអប្បរមាការគ្រប់គ្រងភ្ជួររាស់ដី ការផ្លាស់មុខដំណាំ និងដាំដំណាំគំរបដី និងប្រើជីកំប៉ុស្ត។ល។

**៤.២. ការកែលម្អការចិញ្ចឹមសត្វៈ** ជ្រើសរើស និងប្រើប្រាស់ពូជសត្វដែលធន់នឹងកំដៅ ការកែលំអចំណីសត្វ និងអាហារូត្ថម្ភសម្រាប់សត្វ និងកែលម្អសេវាបសុព្យាបាល សុខភាព និងអនាម័យសត្វ ព្រមទាំងជីវសុត្ថិភាព។ ជំរុញការគ្រប់គ្រងកាកសំណល់រឹង និងរាវពីការចិញ្ចឹមសត្វឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ព្រមទាំងកាកសំណល់ជាថាមពលកកើតឡើងវិញដូចជា ឡជីវឧស្ម័ន។

**៤.៣. ការកែលម្អជលផល និងវារីវប្បកម្មៈ** ជំរុញការធ្វើវារីវប្បកម្មមានការចិញ្ចឹមត្រីក្នុងស្រះ ក្នុងស្រះសិប្បនិមិត្ត ក្នុងស្រែ និងក្នុងបែ និងការគ្រប់គ្រង និងផ្តល់ចំណីឲ្យមានប្រសិទ្ធភាពជៀសវាងការបំពាយឧស្ម័នផ្ទះកញ្ចក់(មេតាន)។ អភិវឌ្ឍ និងពង្រឹងសហគមន៍នេសាទ និងគ្រប់គ្រងព្រៃលិចទឹក ព្រៃកោងកាង ស្មៅសមុទ្រ ធនាគារក្តាម ទីកន្លែងនេសាទ និងស្រះជំរកត្រី និងការពារការហូរច្រោះដីនៅតំបន់ឆ្នេរ។ល។

**៤.៤. ការកែលម្អការគ្រប់គ្រងទឹក និងប្រមូលទឹកៈ** សាងសង់ និងស្តារប្រព័ន្ធស្រោចស្រពតាមគ្រួសារ និងកសិដ្ឋាន ព្រមទាំងស្រះ អាងប្រមូល និងសន្សំទឹកភ្លៀង។ ការកែលំអការគ្រប់គ្រងទឹកក្នុងកសិដ្ឋានដូចជាជំរុញការអនុវត្តបច្ចេកទេសសន្សំសំចៃទឹក ស្រោចស្រពដំណក់ទឹក ប្រើដំណក់ចំហាយទឹក (ព្រីងគ្លើ) និងការប្រើបច្ចេកទេសបន្សើម និងបង្ហោកទឹក Alternative Wet and Dry-AWD)។

**៤.៥. ជំរុញអនុវត្តប្រព័ន្ធកសិរុក្ខ-រុក្ខកម្មៈ** ដាំឈើពហុប្រយោជន៍តាមគ្រួសារ កសិដ្ឋាននិងសហគមន៍ និងនៅលើដីទំនេរ ដើម្បីជាម្លប់ ជាជម្រក ប្រើប្រាស់ជាថាមពល ជារបាំងការពារខ្យល់ ជាចំណីសត្វ។ ពង្រឹងសហគមន៍ព្រៃឈើ។

## ៤.៦. ការបន្ធូរបន្ថយនឹងការប្រែប្រួលអាកាសធាតុ

ការបន្ធូរបន្ថយគឺជាវិធីសាស្ត្រឬយន្តការដើម្បីបន្ថយដំណើរបម្រែបម្រួលអាកាសធាតុដោយបន្ថយកម្រិតបំភាយឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាសតាមរយៈ៖

- ជំរុញការអភិវឌ្ឍន៍ និងប្រើប្រាស់ថាមពលកកើតឡើងវិញ មានកម្មវិធីឡជីវស្ម័នជាង ១៥,០០០ឡ និងការ

ប្រើជីវម៉ាស។ល។

- អនុវត្តការដាំដុះប្រព័ន្ធដំណាំចំរុះដំណាំស្បៀង និងដំណាំថាមពល (ឧ. ដំណាំដំឡូងមី ល្ហុងប្រេង។ល។)
- ជំរុញការដាំដំណាំកសិឧស្សាហកម្ម (ឧ.ដំណាំកៅស៊ូ និង ដូងប្រេង។ល។)
- ការដាំដុះព្រៃឈើឡើងវិញ
- ជំរុញការគ្រប់គ្រង និងដាំព្រៃឈើ និងព្រៃលិចទឹក
- កម្មវិធីឥណទានកាបោន។ល។

## ៥. ការកសាងសមត្ថភាពមន្ត្រី និងកសិករ

ការកសាងសមត្ថភាពមន្ត្រីកសិកម្ម និងកសិករពី ចំណេះដឹងពីការប្រែប្រួលអាកាសធាតុ និងវិធីសាស្ត្របន្សាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងបង្កើនសមត្ថភាពប្រព័ន្ធភាពធន់ដូចជា៖

- ភាពធន់លើផ្នែករូបសាស្ត្រមានៈ បង្កើនសមត្ថភាព និងការទទួលបាននូវបច្ចេកទេសផលិតកម្មកសិកម្ម ពូជដំណាំ ពូជសត្វ ការគ្រប់គ្រងទឹក(បរិមាណ និងគុណភាពទឹក)និងធនធានដី និងការកែលម្អជីជាតិដី។ល។
- ភាពធន់លើផ្នែកសេដ្ឋកិច្ចៈ ការទទួលបានប្រាក់ចំណូល ការគ្រប់គ្រងហានិភ័យ(ការធានារ៉ាប់រងដំណាំ និងសំណាញ់សុវត្ថិភាពសង្គម) ការទទួលបានឥណទាន ប្រាក់ចំណូលពីការងារក្រៅកសិកម្ម និងទីផ្សារកសិផល។ល។
- ភាពធន់លើផ្នែកសង្គម និងមនុស្សៈ ការទទួលបាននិងប្រើប្រាស់សេវាបច្ចេកទេស និងព័ត៌មានផ្សព្វផ្សាយ និងស្រាវជ្រាវកសិកម្ម ការទំនាក់ទំនងបណ្ដាញសង្គមដូចជាការចងក្រងចចនាសម្ព័ន្ធអង្គការកសិករ និងសហគមន៍កសិកម្ម ការបណ្ដុះបណ្ដាលលើបច្ចេកទេសកសិកម្ម។

## ៦.សន្និដ្ឋាន និងសំណូមពរ

ដើម្បីធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានានូវប្រព័ន្ធស្បៀងមាននិរន្តរភាពសម្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ"ការដាក់បញ្ចូលគ្នាចម្រុះនូវទស្សនទាន៖កសិកម្ម-ស្បៀងអាហារ-ទឹក-ថាមពល និងការប្រែប្រួលអាកាសធាតុ (Agriculture-Food-Water-Energy and Climate Change Nexus) ដោយជំរុញការអនុវត្តបច្ចេកទេស និងបច្ចេកវិទ្យាកសិកម្ម ដូចជាប្រព័ន្ធផលិតកម្ម ដំណាំស្រូវ និងប្រព័ន្ធផលិតកម្មដំណាំ កសិកម្មអភិរក្ស ជំរុញសាកវប្បកម្មនៅតំបន់ជាយក្រុង និងទីក្រុង ប្រព័ន្ធផលិតកម្មស្បៀងអាហារនិងថាមពល ប្រព័ន្ធវារីវប្បកម្មប្រើប្រាស់ថាមពលទាប ប្រព័ន្ធគ្រប់គ្រងព្រៃឈើ និងដីធ្លីប្រកបដោយចីរភាព និងកសិ-រុក្ខកម្ម។ ដើម្បីបន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន ការអនុវត្តផលិតកម្មកសិកម្មត្រូវគិតគូដល់ការគ្រប់គ្រងធាតុចូលកសិកម្មមានជី ថ្នាំពុលកសិកម្ម ទឹក និងដីធ្លីឲ្យមានប្រសិទ្ធភាព ការគ្រប់គ្រងកាកសំណល់កសិដ្ឋាន បង្កើនការប្រើប្រាស់ជីវឋាមពល និងការប្រើប្រាស់ឋាមពលកកើតឡើងវិញ ដូចជាឡជីវឧស្ម័នជាដើម។

ជំរុញការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ ក្នុងគ្រួសារ និងកសិដ្ឋានរបស់កសិករ ជាពិសេសគ្រួសារកសិករខ្នាតតូចជាយុទ្ធសាស្ត្រមួយ ដែលបានផលិតស្បៀងអាហារមានប្រសិទ្ធភាពវិជ្ជមានមួយលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការដាក់បញ្ចូលប្រព័ន្ធចម្រុះមួយមាន៖ ដំណាំស្រូវ សួនដំណាំគ្រួសារ មានដំណាំបន្លែ ដំណាំរួមផ្សំ និងឈើហូបផ្លែ ការចិញ្ចឹមសត្វខ្នាតតូច និងចិញ្ចឹមត្រីតាមគ្រួសារ និងប្រើប្រាស់ធាតុចូលនៅមូលដ្ឋាន ដូចជាជីធម្មជាតិ បានបង្កើតឲ្យមានប្រព័ន្ធផលិតស្បៀងនិងអាហារូបត្ថម្ភពេញមួយឆ្នាំសម្រាប់គ្រួសារ និងទីផ្សារ។ តម្រូវការសកម្មភាពកសិកម្មក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ សុំស្នើដាក់បញ្ចូល ក្នុងផែនការវិនិយោគឃុំ ដើម្បីភ្នាក់ងារផ្ដល់សេវាបច្ចេកទេសកសិកម្មនានា អន្តរាគមន៍ទាន់ពេលវេលា និងតម្រូវការព័ត៌មាន ឯកសារ បច្ចេកវិទ្យា និងទីផ្សារកសិកម្ម សូមទំនាក់ទំនងជាមួយភ្នាក់ងារផ្ដល់សេវាបច្ចេកទេសកសិកម្មនៅមូលដ្ឋាន និងតាមរយៈរដ្ឋអំណាចមូលដ្ឋានភូមិ ឃុំ ការិយាល័យកសិកម្មស្រុក និងមន្ទីរកសិកម្មខេត្ត។

# បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

*រៀបចំដោយៈនាយកដ្ឋានអភិវឌ្ឍវារីវប្បកម្ម នៃរដ្ឋបាលជលផល*

## ១- ការជ្រើសរើសទីតាំងជីកស្រះ

### គោលបំណង៖

- ជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រីបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីអនុវត្តទទួលបានជោគជ័យ
- និងបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង។

### តើយើងត្រូវជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រីយ៉ាងដូចម្តេច?

ស្រះគួរជីកៈ

- នៅជិតផ្ទះងាយស្រួលគ្រប់គ្រង
- ស្រះគួរជីកនៅកន្លែងទំនាបប៉ុន្តែមិនលិចទឹកនៅរដូវវស្សា (ឬលិចតិចតួចតែអាចលើកភ្លឺទប់បាន)
- ស្ថិតនៅទីវាលស្រឡះ គ្មានដើមឈើព័ទ្ធជុំវិញ
- ដីមិនជ្រាបទឹក ឬមានកម្រិតជ្រាបតិចតួច
- ជិតប្រភពទឹកប្រសិនបើមាន
- ស្រះជាប់ស្រែកាន់តែប្រសើរ
- នៅឆ្ងាយពីតំបន់ដែលមានការប្រើប្រាស់ថ្នាំពុលកសិកម្មផ្សេងៗ។





*មិនគួរជីកស្រះមានដើមឈើធំៗព័ទ្ធជុំវិញ*



*មិនគួរជីកស្រះជិតតំបន់ប្រើប្រាស់ថ្នាំពុលកសិកម្ម*



## ២- លក្ខណៈស្រះចិញ្ចឹមត្រី

### គោលបំណង៖

**ដើម្បីយល់ច្បាស់ពី**

- ទ្រង់ទ្រាយ ឬរូបរាង និងទំហំស្រះដែលអាចចិញ្ចឹមត្រីបាន
- លក្ខណៈបច្ចេកទេសនៃស្រះចិញ្ចឹមត្រី
- ការរៀបចំស្រះចិញ្ចឹមត្រីឲ្យបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីអនុវត្តទទួលបានជោគជ័យ។

**ស្រះចិញ្ចឹមត្រីគួរ**



គំរូស្រះចិញ្ចឹមត្រី

- ជីកមានរាងបួនជ្រុងទ្រវែង ដើម្បីងាយស្រួលគ្រប់គ្រង
- ស្រះគួរមានទំហំពី១០០ ម៉ែត្រការេឡើងទៅសមស្រប ដល់ការចិញ្ចឹមត្រីបានធំធាត់ល្អ
- ស្រះមានជំរៅសមស្របពី ១.៥ម៉ែត្រ ទៅ ២.៥ម៉ែត្រ អាស្រ័យទំហំស្រះដែលត្រូវជីក
- ស្រះត្រូវមានភ្លឺខ្ពស់ និងមាំល្អ ដើម្បីការពារទឹកលិច
- ស្រះត្រូវមានចំណោតភ្លឺស្រះ ដើម្បីការពារភ្លឺស្រះហូរច្រោះបាក់ដី និងជាកន្លែងត្រីរកចំណី និងពងកូន
- ស្រះចិញ្ចឹមត្រីគួរមានទំហំ និងលក្ខណៈដូចក្នុងតារាងខាងក្រោម :

| លរ | ក្រឡាផ្ទៃស្រះ (ម៉ែត្រការ៉េ) | បណ្ដោយស្រះ (ម៉ែត្រ) | ទទឹងស្រះ (ម៉ែត្រ) | ជម្រៅស្រះ (ម៉ែត្រ) | ចំណោតភ្លឺស្រះ (ម៉ែត្រ) | ទទឹងភ្លឺស្រះ (ម៉ែត្រ) |
|---|---|---|---|---|---|---|
| ១ | ៣០០ | ២០ | ១៥ | ២.៥ | ១ | ១ |
| ២ | ២៤០ | ២០ | ១២ | ២.៥ | ១ | ១ |
| ៣ | ២០០ | ២០ | ១០ | ២.៥ | ១ | ១ |
| ៤ | ១៥០ | ១៥ | ១០ | ២ | ០.៥ | ១ |
| ៥ | ១២០ | ១២ | ១០ | ១.៥ | ០.៥ | ១ |

- ស្រះត្រូវមានជើងទេរ (ជម្រាល) សមស្រប

ដើម្បីការពារការហូរច្រោះ ឬ បាក់ដី

- បាតស្រះត្រូវរាបស្មើហើយមានជម្រាលទៅជ្រុងម្ខាងដើម្បីងាយស្រួលពង្រីងទឹក និងប្រមូលផលត្រី
- ស្រះត្រូវដាំស្មៅនៅលើភ្លឺស្រះ និងដាំនៅលើជើងទេរភ្លឺស្រះ ដើម្បីការពារការហូរច្រោះបាក់ដីនៅពេលមានភ្លៀងធ្លាក់
- នៅតាមភ្លឺស្រះគួរបង្កប់បំពង់ សម្រាប់បង្ហូរទឹកចូលស្រះ
- ស្រះគួរធ្វើរបងព័ទ្ធជុំវិញ ដើម្បីការពារសត្វគោ ក្របី ជ្រូក ចុះទឹកស្រះនាំឲ្យខូចភ្លឺស្រះ និងល្អក់ទឹកស្រះ។ ម្យ៉ាងទៀត ការពារកុំឲ្យក្មេងទៅលេងក្បែរស្រះទឹក ដែលអាចនាំឲ្យលង់ទឹកស្រះបានងាយ។
- ក្រៅពីនេះត្រូវរៀបចំរណ្ដៅជីលាមកសត្វឲ្យនៅជាប់នឹងភ្លឺស្រះ ដើម្បីងាយស្រួលបង្ហូរទឹកជីចូលក្នុងស្រះចិញ្ចឹមត្រី។ រណ្ដៅជីគួរជីកដីទំហំបណ្ដោយប្រវែង២ម៉ែត្រ ទទឹងប្រវែង ១ម៉ែត្រ ជម្រៅ ១ម៉ែត្រ សំអាតបាតរណ្ដៅជី រួចក្រាលកម្រាលកៅស៊ូប្លា.ស្ទិកដើម្បីការពារទឹកជីលាមកសត្វជ្រាបចូលក្នុងដី។ យើងអាចប្រើពាងទឹកធ្វើជារណ្ដៅជីត្រាំជីលាមកសត្វក៏បាន ឬប្រើកង់អណ្ដូងរៀបធ្វើជារណ្ដៅជីក៏បាន។



គំរូស្រះចិញ្ចឹមត្រី



# ៣- របៀបជីកស្រះចិញ្ចឹមត្រី

## គោលបំណង៖

ដើម្បីយល់ច្បាស់ពី

- បច្ចេកទេសជីកស្រះចិញ្ចឹមត្រីតាមលំដាប់ លំដោយ
- ការរៀបចំស្រះចិញ្ចឹមត្រីត្រឹមត្រូវតាមលក្ខណៈស្រះចិញ្ចឹមត្រីដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ

**ឧទាហរណ៍៖** យើងត្រូវជីកស្រះមានរាងជាចតុកោណកែងដែលមានបណ្ដោយ១៥ ម៉ែត្រ ទទឹង១០ម៉ែត្រ និងជម្រៅ ២ម៉ែត្រ ដូចនេះផ្ទៃក្រឡាស្រះមានទំហំ = បណ្ដោយ ១៥ម៉ែត្រ X ទទឹង ១០ម៉ែត្រ = ១៥០ ម៉ែត្រការ៉េ។

- ដំបូងយើងត្រូវវាស់ទំហំបណ្ដោយ និងទទឹងស្រះដែលត្រូវជីកដោយបោះបង្គោលនៅជ្រុងទាំង ៤នៃស្រះ រួចចងខ្សែព័ទ្ធជុំវិញ។
- បន្ទាប់មកយើងត្រូវកំណត់រកផ្ទៃបាតស្រះ ដែលត្រូវជីកតាមរូបមន្តដូចខាងក្រោម:
- Sb= ( L- LS ) X ( W- LS )

  Sb=ផ្ទៃបាតស្រះ

  ( L- LS )= ប្រវែងបណ្ដោយបាតស្រះ

  ( W- LS ) = ប្រវែងទទឹងបាតស្រះ

  L= ប្រវែងបណ្ដោយស្រះ

  LS=ប្រវែងគម្លាតជើងទេរស្រះ

  W= ប្រវែងទទឹងស្រះ



- ជាទូទៅជើងទេរស្រះត្រូវឲ្យមានជម្រាល 1: 1.5
- រួចបោះបង្គោលនៅជ្រុងទាំង ៤ នៃបាតស្រះ ដោយចងខ្សែព័ទ្ធជុំវិញ
- បន្ទាប់មកត្រូវចាប់ផ្ដើមជីកស្រះឲ្យមានជម្រាល 1: 1.5 ជាគំរូចាប់ពីគែមមាត់ស្រះចុះក្រោមរហូតដល់ចំណុចគែមបាតស្រះ និងឲ្យបានជម្រៅស្រះ ២ម៉ែត្រ។ រួចយកខ្សែទាញវាស់ជម្រាលជើងទេរក្នុងករណីជើងទេរស្រះរាបស្មើល្អ យើងចាប់ផ្ដើមជីកស្រះដែលមានជើងទេរស្រះគំរូនេះបន្តរហូតដល់ចប់។
- យើងអាចជីកស្រះ ដោយកំណត់យកជើងទេរគំរូជារាងកាំជណ្ដើរដូចក្នុងរូបភាពខាងក្រោម។
- ជាទូទៅអាចម៍ដីដែលជីកបាននៅស្រទាប់លើ ជាប្រភេទដីមានជីវជាតិល្អ ដូចនេះត្រូវប្រមូលអាចម៍ដីនេះ ទុកសម្រាប់ដាក់នៅលើភ្លឺស្រះសម្រាប់ដាំស្មៅ ការពារការហូរច្រោះបាក់ភ្លឺ និងជើងទេរស្រះនៅពេលមានភ្លៀងធ្លាក់។




- គួរជីកស្រះដោយទុកចំណោភ្លឺពី ០,៧ ម៉ែត្រ ទៅ ១ ម៉ែត្រ ឬតាមស្ថានភាពដីជាក់ស្ដែង



ត្រូវបុកបង្ហាប់ភ្លឺ និងជើងទេរស្រះ



ត្រូវដាំស្មៅពីលើភ្លឺស្រះ



គំរូស្រះចិញ្ចឹមត្រី



បច្ចេកទេសជីកស្រះរាងជាកាំជណ្ដើរ



ស្រះចិញ្ចឹមត្រីជីកមិនបានត្រឹមត្រូវ

# ៤- ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម

- លើកភ្លឺព័ទ្ធជុំវិញស្រះ រួចដាំស្មៅ ដើម្បីកាត់បន្ថយការហូរច្រោះដែលធ្វើឲ្យទឹកល្អក់ ។

**គោលបំណង៖**

១. កំចាត់ត្រីកាច និងសត្វកាចដទៃទៀត ដូចជា កង្កែប អន្ទង់ ពស់ ក្តាម កុំឲ្យស៊ីកូនត្រី ក្រោយពេលកូនត្រីដាក់ចិញ្ចឹមក្នុងស្រះ។

២.សម្លាប់មេរោគដែលមាននៅក្នុងស្រះចិញ្ចឹមត្រី

៣.បង្កើនសារធាតុចិញ្ចឹមក្នុងស្រះសម្រាប់ត្រីក្រោយពេលស្រះបានរៀបចំល្អហើយ

៤. និងការពារត្រីកាច និងសត្វកាចដទៃទៀតដូចជា កង្កែប អន្ទង់ ពស់ ក្តាម កុំឲ្យចូលស្រះស៊ីកូនត្រីក្រោយពេលរៀបចំស្រះបានល្អហើយ។

### ក. ចំពោះស្រះចាស់

បូមពង្រីងចាប់ត្រីកាចសំអាតស្រះ និងស្តារភក់បាតស្រះ (ទុកជម្រៅ ១៥ស.ម ឬ១តឹកកន្លះ)





បាចកំបោរ (៥–១០គ.ក្រ/១០០ម²)



ដាក់ជីធម្មជាតិក្រាលបាតស្រះ



រួចបញ្ចូលទឹកក្នុងស្រះដោយប្រើតម្រង



១អាទិត្យក្រោយទឹកស្រះមានពណ៌បៃតងសម្បូរចំណីធម្មជាតិ (សត្វនិងរុក្ខជាតិប្លង់តុង)

**សូមរង់ចាំអានវគ្គបន្តនៅលេខ៤៩**

គតិលេខ៤៧

# បច្ចេកទេសចិញ្ចឹមមាន់ ជាលក្ខណៈគ្រួសារ

ដោយ: នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

## វដ្ដផលិតកម្មមាន់ និងការថែរក្សាកូនមាន់

### ១. វដ្ដផលិតកម្មមាន់

វដ្ដផលិតកម្ម ឬ រយៈពេលញាស់មួយសំបុករបស់មេមាន់ ១ក្បាល មានរយៈពេល ៥៦ថ្ងៃ ប្រសិនបើអ្នកចិញ្ចឹមអនុវត្តតាមបច្ចេកទេសបង្ហាញខាងក្រោម។ ដូច្នេះមេមាន់ ១ក្បាល អាចទទួលបានកូនមាន់ជាមធ្យម ៥-៧ សំបុក ក្នុង ១ឆ្នាំ។




គំនូសតាងវដ្ដផលិតកម្មកូនមាន់

### សម្គាល់:

បើសិនជាកសិករមានបទពិសោធន៍គ្រប់គ្រាន់ នោះកសិករអាចបំបែកកូនចេញពីមេ បន្ទាប់ពីញាស់រួចភ្លាម ដូច្នេះក្នុង ១ឆ្នាំ កសិករអាចទទួលបានកូនមាន់ពី ៧-៨សំបុក សម្រាប់មេមួយក្បាល ។ ប៉ុន្តែកូនមាន់ទាំងនោះត្រូវការថែរក្សាយ៉ាងត្រឹមត្រូវ ។

### ២. ការថែរក្សាកូនមាន់ទើបញាស់

កូនមាន់ដែលទើបញាស់ ងាយរងគ្រោះ និង អត្រាស្លាប់ខ្ពស់ ប្រសិនបើមិនបានថែរក្សាត្រឹមត្រូវ ។ ដូច្នេះ ដើម្បីការពារកូនមាន់កុំឱ្យស្លាប់ ត្រូវអនុវត្តដូចខាងក្រោម:

- ថែរក្សានៅកន្លែងដែលមានសុវត្ថិភាព
- កម្រាលត្រូវតែស្ងួត (អាចប្រើចំបើង ឬអង្កាម ជាកម្រាល ដើម្បីងាយស្រួលក្នុងការប្រមូលរៀងរាល់ថ្ងៃ
- ដាក់កូនមាន់ ២០ក្បាល ក្នុង ១ម$^{២}$
- កន្លែងដែលមានបរិយាកាសក្ដៅល្មម និងស្អាតល្អ

❖ ផ្ដល់នូវទឹក និងចំណីអាហារដែលងាយស្រួលរំលាយ និងគ្រាប់ល្អិតៗ គ្រប់គ្រាន់។

**តើត្រូវបំបែកកូនមាន់ ចេញពីមេនៅអាយុ ១០ថ្ងៃ ដូចម្ដេច ?**

ក. រៀបចំទ្រុងសម្រាប់ដាក់កូនមាន់រួចជាស្រេច ដោយបាតទ្រុងដាក់អង្កាម ឬកំទេចអាចម៍រណារ

ខ. ត្រូវយកទាំងមេ និងកូន ទៅដាក់ក្នុងទ្រុងកូនមាន់ជាមួយគ្នា ក្រោយពីកូនញាស់អស់

គ. ពេលកូនមាន់អាយុបាន ១០ថ្ងៃ ត្រូវដកមេចេញពីកូនទៅដាក់ក្នុងទ្រុងមេពង ។ មិនអនុញ្ញាតឱ្យមេមាន់ចូលក្នុងទ្រុង ឬមកក្បែរកូនមាន់ឡើយ ។

ឃ. ត្រូវយកបាវ ឬក្រដាសព័ទ្ធជុំវិញទ្រុងកូនមាន់ដើម្បីរក្សាកំដៅ ។

បើសិនត្រជាក់ខ្លាំង ឬ ពេលយប់ ត្រូវបន្ថែមកំដៅដោយប្រើក្អមធ្យូងកំដៅ ឬអំពូលភ្លើង(មូល) ៧០វ៉ាត់ ។

ង. កូនមាន់អាយុបាន ១ខែ ត្រូវយកទៅចិញ្ចឹមនៅក្នុងទ្រុងបំប៉នរហូតដល់ពេលលក់។

**តើត្រូវផ្ដល់កំដៅកូនមាន់ដូចម្ដេច ដើម្បីឱ្យលូតលាស់ល្អ ?**

ការក្រុងរបស់មេៈ បើសិនមេមាន់ វាក្រុងកូនរបស់វាក្រោមស្លាប នោះកូនមាន់ នឹងទទួលកំដៅពីមេវា ៣៥-៣៧ អង្សាសេ។

ការចិញ្ចឹមគ្មានមេៈ ត្រូវផ្ដល់កម្ដៅឱ្យកូនមាន់ដូចមេមាន់ដែរ

❖ បើសីតុណ្ហភាពទាប នោះកូនមាន់នឹងខ្សោយ រងា ឈឺ ហើយបណ្ដាលឱ្យការលូតលាស់យឺត

❖ បើសីតុណ្ហភាពខ្ពស់នឹងធ្វើឱ្យរោមកូនមាន់ដុះមិនល្អ

❖ ត្រូវត្រៀមកម្ដៅសម្រាប់កូនមាន់

❖ ត្រូវផ្ដល់ទឹក និងចំណីឱ្យបានគ្រប់គ្រាន់ និងមានគុណភាព



*ផ្ដល់កំដៅកូនមាន់ដោយប្រើរងើកធ្យូង*



*ផ្ដល់កម្ដៅកូនមាន់ដោយប្រើអំពូលភ្លើងមូល*

សញ្ញាបង្ហាញពីកម្ដៅក្នុងទ្រុងកូនមាន់

❖ កម្ដៅល្មមគ្រប់គ្រាន់ៈ កូនមាន់ដើររកស៊ីរាយប៉ាយល្អពេញក្នុងទ្រុង

❖ កម្ដៅខ្លាំងជ្រុលៈ កូនមាន់ឃ្លាតឆ្ងាយពីប្រភពកម្ដៅ ឬ ស្រែកយំពេញទ្រុង ឬ រត់ប្រសេចប្រសាច

❖ កម្ដៅត្រជាក់ខ្លាំងៈ កូនមាន់ប្រមូលផ្ដុំគ្នា ឬ គរលើគ្នា




សញ្ញាសំខាន់ៗស្តីពីការផ្តល់កំដៅកូនមាន់







## ការកែលម្អពូជ និងការជម្រុះមាន់

គោលបំណងសំខាន់ គឺដើម្បីបង្កើនផលិតកម្មសាច់ និងផលិតកម្មស៊ុតខ្ពស់ ។ វិធីសាស្រ្តល្អបំផុតក្នុងការកែលម្អពូជមាន់ គឺការបង្កាត់ខ្វែងរវាងពូជមាន់ក្នុងស្រុកជាមួយពូជនាំចូល ។

### ១. ការបង្កាត់ពូជ

ការជ្រើសរើសពូជ ដោយប្រើបាពូជកូនកាត់មេអ៊ីសាប្រោន ជាមួយបាមាន់ជល់ មកបង្កាត់ជាមួយមេមាន់ស្រុកផ្តល់នូវ ៖

- បង្កើនការលូតលាស់ដើម្បីឆាប់បានលក់(ខែ)
- បង្កើនគុណភាពសាច់ (សាច់ច្រើន)
- រក្សារសជាតិឆ្ងាញ់ដូចមាន់ពូជក្នុង ស្រុក
- អាចចិញ្ចឹមក្នុងលក្ខណៈលែងសេរី



មាន់គកពូជកូនកាត់ (មេអ៊ីសាប្រោន ជាមួយបាមាន់ជល់)



បាថ្មីចិញ្ចឹមលែងដូចមាន់ពូជក្នុងស្រុក



កូនមាន់ពូជកូនកាត់

### ២. ការជម្រុះ

តាមធម្មតាកសិករមិនដែលជម្រុះមាន់ទេ លើកលែងតែវាស្លាប់ ឬឈឺដោយសារជំងឺ ។ ការទុកមេ បាមាន់ ចិញ្ចឹមរហូតដល់អាយុច្រើនជាង ៣ឆ្នាំ វាមិនអាចផ្តល់លទ្ធផលល្អទេ ព្រោះវាអាចធ្វើឱ្យមេមាន់ផ្តល់ពងតិច និង អត្រានៃការញាស់តិចដែរ ជាពិសេសអត្រាស្លាប់ខ្ពស់ ដូច្នេះដើម្បីឱ្យទទួលបាននូវលទ្ធផលល្អ ត្រូវជម្រុះមេមាន់ និងបាមិនឱ្យអាយុលើសពីអាយុ ៣ឆ្នាំ ។ បើសិនជាទុកមេ ត្រូវផ្លាស់ប្តូរបាចេញ ដោយទិញបាថ្មីមកជំនួសវិញ តែត្រូវប្រយ័ត្នការជាន់ឈាមចំពោះបាថ្មី និងប្រយត្ន័ចំពោះការផ្ទុកនូវជមឺឆ្លង ។

## ចំណីអាហារសម្រាប់មាន់

### ១. ការផ្ដល់ចំណី

ការផ្ដល់ចំណីវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការចិញ្ចឹម ៖

#### ការចិញ្ចឹមព្រលែងសេរី

មាន់ដើររកស៊ីចំណីដោយខ្លួនឯង ហើយនៅពេលយប់ដេកលើចុងឈើ ។ នៅពេលថ្ងៃមាន់ដើររកស៊ីចំណីជុំវិញភូមិ ។ ចំណីដែលមាន់ដើររកស៊ីខ្លួនឯងរួមមាន ខ្យង កណ្ដៀរ ដង្កូវ ជន្លេន សត្វល្អិត ស្មៅ ស្លឹករុក្ខជាតិ រុក្ខជាតិទឹក អនុផលក្រោយពេលប្រមូលផល ... ប៉ុន្តែការរកស៊ីចំណីដោយខ្លួនឯងមាន់មិនអាចស៊ីបានគ្រប់គ្រាន់ឡើយ ដូច្នេះត្រូវផ្ដល់ចំណីបន្ថែមដល់មាន់ទាំងនោះ ដូចជាកាកសំណល់ផ្ទះបាយ និងអនុផលកសិកម្ម ។



*ការផ្ដល់ដើមចេកហាន់ជាចំណីបន្ថែមដល់មាន់*

#### ការចិញ្ចឹមដោយមានទីធ្លា

មាន់ដើររកស៊ីចំណីពេញទីធ្លាដោយខ្លួនឯងហើយនៅពេលយប់គេឲ្យដេកក្នុងទ្រុង ។

#### ការចិញ្ចឹមពាក់កណ្ដាលវប្បកម្ម

មាន់ដើររកស៊ីចំណីដោយខ្លួនឯងក្នុងកន្លែងកំណត់មួយ និងផ្ដល់ចំណីបន្ថែមដល់មាន់ទាំងនោះ ដូចជា កាកសំណល់ផ្ទះបាយ និងអនុផលកសិកម្ម ។

ការចិញ្ចឹមមាន់ដាក់ទ្រុងបង្ខាំង គឺមាន់ពឹងផ្អែកទាំងស្រុងទៅលើការផ្ដល់ចំណីឱ្យ ។ តម្រូវការចំណីនេះ មានការកើនឡើងទៅតាមអាយុ និងទម្ងន់របស់វា ។ មាន់ត្រូវការចំណីដែលមានគុណភាព សម្រាប់ទ្រទ្រង់រាងកាយ ការរីកលូតលាស់ ផលិតកម្មស៊ុត និងសាច់។ កូនមាន់តូចៗដែលមានអាយុពី ១ ថ្ងៃ ដល់ ៤៥ ថ្ងៃ ត្រូវការចំណីដែលមានគុណភាពល្អ និងមានគុណភាពខ្ពស់ ដើម្បីការលូតលាស់របស់វា ។

ការផ្ដល់ចំណីបន្ថែម មានសារៈសំខាន់ណាស់ ព្រោះវាជួយរក្សាមាន់នៅរដូវខ្សត់ចំណី (រដូវប្រាំង)ជួយផ្ដល់បន្ថែមនូវប្រភពវីតាមីន រ៉ែ ប្រូតេអ៊ីន និងថាមពល ដែលខ្វះនៅក្នុងចំណីពេលវារកស៊ីដោយខ្លួនឯង ដើម្បីឲ្យមាន់មាន៖

- សុខភាពល្អ
- ការលូតលាស់ធំធាត់លឿន
- ការបន្តពូជល្អ

ក្រៅពីចំណី ត្រូវផ្ដល់ទឹក ដល់មាន់ឱ្យបានគ្រប់គ្រាន់ជាប្រចាំ ។

### ២. វត្ថុធាតុដើមសម្រាប់ផ្សំចំណី

#### ២.១ ស្រូវ និងអនុផល

ជាចំណីដែលគេប្រើសម្រាប់ផ្ដល់ជាចំណីបន្ថែមដោយផ្ដល់នូវ ៖



- ចុងអង្ករ ជាចំណីផ្តល់នូវថាមពល
- កន្ទក់ ជាចំណីផ្តល់នូវថាមពល និងមានប្រូតេអ៊ីនពី ៨-១២% ហើយសំបូរផូស្វ័រ និង វីតាមីន បេ ។

## ២.២ ពោត

កសិករកម្រប្រើណាស់ តែពោតជាប្រភេទចំណីមាន់ដែលមានប្រសិទ្ធិភាពខ្ពស់ ដែលកសិករគួរតែកិនធ្វើជាចំណីសម្រាប់មាន់ ព្រោះវា

- ជាប្រភពផ្តល់នូវថាមពល
- មានប្រូតេអ៊ីនពី ៩-១០%
- ជាអ្នកផ្តល់ពណ៌(ជួយបង្កើនពណ៌លឿងនៅស្បែក និងស៊ុត)



## ២.៣ សណ្តែកសៀង

គេកម្រផ្តល់ឲ្យមាន់ចិញ្ចឹមព្រលែងសេរីណាស់។ សណ្តែកសៀងមានសារៈសំខាន់បំផុតសម្រាប់ផ្សំជាចំណី ប៉ុន្តែគេចាំបាច់ត្រូវតែចម្អិនជាមុន ដោយលីង ឬស្ងោរក្នុងរយៈពេលពី ២០-៣០នាទី ។ វាផ្តល់នូវ

- ប្រភពផ្តល់ថាមពល (សំបូរជាតិប្រេង)
- មានប្រូតេអ៊ីនលើសពី ៤០%



## ២.៤ មើមដំឡូងមី

មើមដំឡូងមីមានថាមពលខ្ពស់ តែវាខ្សត់ ប្រូតេអ៊ីន ។ ប៉ុន្តែមើមដំឡូងមីមានជាតិល្វីង ដូចនេះដើម្បីឲ្យមាន់ស៊ីបានច្រើន ចាំបាច់ត្រូវតែលាយជាមួយវត្ថុធាតុដើមផ្សេងៗទៀត ។

គ្រប់ផ្នែកទាំងអស់របស់ដំឡូងមី មុននឹងប្រើប្រាស់ជាចំណីសត្វ ត្រូវហាលឲ្យស្ងួតដើម្បីកាត់ជាតិពុល ។



## ២.៥ ស្លឹកដំឡូងមី

មុននឹងប្រើចាំបាច់ត្រូវហាលជាមុន ។

- វាសំបូរប្រូតេអ៊ីន (មានលើសពី ២០%)
- សំបូរវីតាមីន និងសំបូរសារធាតុផ្តល់ពណ៌ ដែលជួយបង្កើនពណ៌លឿងដល់ស្បែក និងស៊ុត
- ជួយបង្កើនភាពស៊ាំ ដែលជួយទៅលើសុខភាព
- សម្រាប់មាន់ពង គេប្រើ ១០ក្រាម ក្នុងមួយក្បាល ក្នុងមួយថ្ងៃ ។



## ៣. សមាសធាតុចំណីសំបូរជាតិសាច់(ប្រូតេអ៊ីន)

ប្រូតេអ៊ីនមានសារៈសំខាន់សម្រាប់ជួយការលូត

លាស់របស់រាង្គកាយ សាច់ ស្បែក សម្រាប់ផលិតពង។ ប្រូតេអ៊ីន អាចរកបានពី កន្ទក់ ចុងអង្ករ ត្រី ម្សៅត្រី ម្សៅត្រីក្រៀម កង្កែប ជន្លេន កូនដង្កូវ សត្វល្អិត ពពួកសណ្តែក សាច់ដូងស្ងួត ស្លឹកកន្ធំថេត ស្លឹកដំឡូងឈើស្ងួត ត្រកួន ចក បាយទា ។ល។

ចំពោះប្រភេទរុក្ខជាតិបន្លែត្រូវហាលឱ្យស្ងួតល្អ និង បុកឱ្យម៉ត់មុនឱ្យមាន់ស៊ី ។ ចំណែកឯការកែច្នៃស្លឹកដំឡូងឈើស្ងួតជាប្រភពប្រូតេអ៊ីនអាចអនុវត្តដូចតទៅ៖

- យកតែស្លឹកដំឡូងមីផ្នែកខាងចុងប្រហែល ៣ ទៅ ៤ តឹក
- កាប់ចិញ្ច្រាំស្លឹកដំឡូងមីឱ្យតូចល្អិត ហើយហាលឱ្យស្ងួតល្អ
- បន្ទាប់មកយកស្លឹកដែលស្ងួតបុកឱ្យម៉ត់ជាម្សៅ
- លាយម្សៅស្លឹកដំឡូងមីស្ងួត ជាមួយសារធាតុផ្សំចំណីផ្សេងៗទៀតដែលកសិករមាន។


ជន្លេន


កម្ពិស


កូនត្រី


សាច់ខ្យង


កណ្ដូប


ចង្រិត


មេភ្លៀង


កណ្ដៀរ


ដង្កូវ


សណ្ដែកបាយ


សណ្ដែកសៀង


ស្លឹកដំឡូងមី


ស្លឹកកន្ធំថេត

ប្រភពចំណីផ្តល់នូវប្រូតេអ៊ីន

## ៤. សមាសធាតុចំណីសំបូរថាមពល

ជាសារធាតុមួយ ជួយផ្តល់ថាមពលក្នុងការរស់នៅ ផលិត ឬស៊ីចំណី និងការធ្វើចលនា ។ ប្រភពថាមពល អាចមាននៅក្នុងពោត ចុងអង្ករ កន្ទក់ កាកដូងស្ងួត មើមរុក្ខជាតិ កាកសំណល់បន្លែ ដំឡូងជ្វា កាកសំណល់ផ្លែឈើ ពពុះស្ករត្នោត ស្ករ កាកសំណល់ប្រេង-ខ្លាញ់។

ប្រភពចំណីអាហារផ្តល់ថាមពល


ស្រូវ និងអង្ករ


ពោត


ដំឡូងជ្វា


កន្ទក់

ចំពោះមើមដំឡូងមី និងត្រាវ គេអាចកាត់ហាលថ្ងៃ បន្ទាប់មកបុក ឬ កិនឱ្យម៉ត់សម្រាប់ចំណីមាន់។

**ចូរប្រយ័ត្ន !**

ចិតយកសំបកមើមដំឡូងចេញ ពីព្រោះវាមានជាតិពុល។

## ៥. សមាធាតុចំណីសំបូរជីវជាតិរ៉ែ

សារធាតុរ៉ែជាពិសេស កាល់ស្យូម និងផូស្វ័រ មានសារៈសំខាន់ធ្វើឱ្យឆ្អឹងលូតលាស់ល្អ និងបង្កើតសំបកស៊ុត។ កង្វះកាល់ស្យូម និងផូស្វ័រ បណ្តាលឱ្យមាន់លូតលាស់យឺត មេមាន់រាគពង (ពងចេញមកមានសំបកទន់ៗ) និង ចឹកស៊ីពង ឬ សំបកពងខ្លួនឯង។ ប្រភពនៃជីវជាតិរ៉ែមានៈ សំបកខ្ចងខ្ចៅ សំបកក្តាម ឆ្អឹងត្រី អំបិល ថ្មើមសត្វ។



*របៀបផលិតម្សៅកាល់ស្យូម*

## ៦. សមាសធាតុចំណីសំបូរវីតាមីន

ចំណីដែលសំបូរទៅដោយវីតាមីនមានៈរុក្ខជាតិបៃតង ស្លឹកបាស កន្ទំថេត ស្មៅ ត្រកួន ចក ។ល។




រុក្ខជាតិសំបូរវីតាមីន

**បំរាមៈ**

មិនត្រូវឲ្យមាន់ស៊ីបន្លែ ឬរុក្ខជាតិបៃតងដែលបាញ់ថ្នាំពុលឡើយ ព្រោះវាអាចបណ្តាលឲ្យមាន់មាន សុខភាពមិនល្អ ( ឈឺ ) និងស្លាប់ ជាពិសេសកូនមាន់ ។

## របៀបធ្វើថ្នាលស្មៅ និងបន្លែជាចំណីមាន់

កសិករគួរតែធ្វើថ្នាលដាំស្មៅច្រើនប្រភេទ លាយជាមួយត្រកួននៅជិតផ្ទះ ឬជិតទ្រុងមាន់ ដើម្បីងាយស្រួលផ្គត់ផ្គង់ចំណីមាន់ ដែលជួយកាត់បន្ថយការចំណាយលុយទិញ ឬ ចំណាយពេលវេលាច្រើនសម្រាប់ដើររក។មុនផ្តល់ឱ្យមាន់ស៊ីត្រូវហាន់វាឱ្យល្អិតៗជាមុនរួចយកទៅច្របល់លាយជាមួយចំណីផ្សំផ្សេងៗទៀត។



*ថ្នាលដាំស្មៅលាយជាមួយត្រកួន*



*ហាន់ស្មៅ និងត្រកួនឲ្យល្អិតៗលាយជាមួយចំណី*

## ៧. ការចិញ្ចឹមជន្លេនក្រហម សម្រាប់ជាចំណីបំប៉ន

### ៧.១ សារៈប្រយោជន៍របស់ជន្លេនក្រហម

- ងាយស្រួលចិញ្ចឹម
- ជន្លេនសំបូរដោយប្រូតេអ៊ីន
- ផ្ដល់ជាចំណីជាតិសាច់ (ប្រូតេអ៊ីន) សម្រាប់ឱ្យមាន់លូតលាស់ល្អ
- ជួយកាត់បន្ថយការចំណាយលើចំណីសម្រាប់ចិញ្ចឹមមាន់





ពូជជន្លេនក្រហម

### ៧.២ របៀបចិញ្ចឹមជន្លេន ដើម្បីឲ្យលូតលាស់បានល្អ

**ក-ទីកន្លែងសមស្របសម្រាប់ចិញ្ចឹមជន្លេន**

- មានទីទួលមិនលិចទឹក ឬទឹកហូរកាត់
- មានផ្ទៃដីបាតរាបស្មើ
- មិនមានសំបុកស្រមោចនៅក្បែរ
- ធានាសុវត្ថិភាពពីការបំផ្លាញពីកត្តាផ្សេងៗ

**ខ-របៀបរៀបចំ ការចិញ្ចឹម**

ដើម្បីឱ្យបានជោគជ័យ ត្រូវអនុវត្តដូចខាងក្រោម៖

- ដាក់របាព័ទ្ធជុំវិញ ២ ជាន់ផុតពីដី ដែលមានទទឹង១,២ម បណ្ដោយ ២,៥ម ទៅ ៣ម និងកម្ពស់ ០,៣ម (៣តឹក)។
- របាខាងក្រោមមានកម្ពស់ពីដី ០,១៥ម និងរបាខាងលើមានកម្ពស់ពីដី ០,៣ម
- ជញ្ជាំង និងបាតក្រាលដោយផ្ទាំងកៅស៊ូក្រាស់ រួចចោះរន្ធតូចៗនៅបាតដើម្បីកុំឲ្យជាំទឹក
- ដាក់លាមកគោស្រស់កម្រាស់ ០,១ ម
- ស្រោចទឹកឱ្យសើម ទើបដាក់ពូជជន្លេន បន្ទាប់មកអាចស្រោចទឹកពីលើបន្តិចទៀត
- ធ្វើដំបូលការពារកម្ដៅ និងភ្លៀងឱ្យបានជិតល្អ
- ធ្វើគម្របពីលើដើម្បីការពារពីការស៊ីបំផ្លាញពីសត្វផ្សេងៗ (សត្វគីង្គក់ ហ៊ីង កង្កែប ថ្លែន ស្រមោច...)



រៀបចំកន្លែងចិញ្ចឹម និងដាក់លាមកគោ



ស្រោចទឹកឱ្យសើមល្មម



*ដាក់ពូជជន្លេនចិញ្ចឹម*



*កាធ្វើជំបូលការពារកំដៅ និង ភ្លៀង*

**គ-របៀបថែទាំ និងផ្ដល់ចំណី**

- ស្រោចទឹក ២ថ្ងៃម្ដងការពារកុំឱ្យស្ងួត
- បន្ថែមចំណីដោយលាមកគោ ៣ ថ្ងៃ ម្ដង

**ឃ-ការផ្ដល់ចំណី(ជន្លេន)ឱ្យមាន់ស៊ី**

- រយៈពេល ២ ខែអាចប្រមូលផលជន្លេន ឲ្យមាន់ស៊ីបាន



*ការដាក់ជន្លេនឲ្យមាន់ជាចំណីបន្ថែម*

- ក្នុង ១ថ្ងៃ អាចផ្ដល់ជន្លេនឱ្យមាន់មួយ ក្បាលស៊ីចំនួនពី ៣-៤ជន្លេន

## ៨. ការផលិតកូនដង្កូវ

**ដើម្បីផលិតបានជាកូនដង្កូវត្រូវ ៖**

- យកកាកសំណល់ផ្ទះបាយ និងបន្លែ ដាក់ចូលក្នុងធុង ដើម្បីឲ្យរុយពងដាក់
- ដើម្បីឲ្យបានកូនដង្កូវច្រើន  អាចបន្ថែមលាមកមាន់ទៅក្នុងធុងនោះ
- នៅពេលក្ដៅខ្លាំង ត្រូវគ្របធុងនោះ ដើម្បីចៀសវាងកុំឲ្យពងរុយងាប់
- កូនដង្កូវអាចត្រូវប្រមូលទៅឲ្យមាន់ស៊ីបាន នៅពេលវាលូតលាស់បានពី ៥-១០ថ្ងៃ ។
- បើលើសពីនេះ កូនដង្កូវនឹងលូតលាស់ ក្លាយជារុយ ។





# បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

**តពីលេខ ៤៧**

*ដោយៈ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល*

## ៩. ជំងឺផ្តាសាយ

ជំងឺនេះមានសភាពធ្ងន់ ពេលថ្ងៃជ្រូកមានសភាពធម្មតា លុះដល់ព្រឹកឡើងជ្រូក ៩០%ឈឺ ។ ជ្រូក ចាប់ផ្តើមក្អក ពិបាកដកដង្ហើម សីតុណ្ហភាពឡើងលើសពី ៤០អង្សាសេ ។ ប៉ុន្តែជ្រូកនឹងជាសះស្បើយវិញក្នុងរយៈពេល ៥ថ្ងៃក្រោយ ។

ជំងឺនេះគ្មានថ្នាំព្យាបាលទេ ព្រោះវាបង្កឡើងដោយ វីរុស តែអាចព្យាបាលដោយប្រើអុកស៊ីតេត្រាស៊ីគ្លីន រយៈពេល ៣ថ្ងៃ ដើម្បីទប់ស្កាត់ជំងឺឆ្លៀតឱកាស ដូចជាជំងឺសារទឹក មីកូប្លាស្មា ... ។

## ១០. ជំងឺរលាកសួត

ច្រើនកើតនៅពេលផ្តាច់ដោះ និងជ្រូកសាច់ ។ ជំងឺនេះបណ្តាលមកពីអាកាសធាតុត្រជាក់ ទ្រុងសើម និងគ្មានអនាម័យ ។

### ១០.១. រោគសញ្ញា

- ដកដង្ហើមញាប់ និងក្អកមួយៗ
- កំដៅលើសពី ៤០អង្សាសេ
- ភ្នែកក្រហម
- ចេញពណ៌ខៀវនៅលើស្បែក ។



*កូនជ្រូកពិបាកដកដង្ហើមធ្ងន់ធ្ងរ*

### ១០.២. មូលហេតុ

- ជំងឺសារទឹក : ៩០% នៃជ្រូកដែលកើតមីកូប្លាស្មា នឹងកើតជំងឺសារទឹក
- ជំងឺផ្សេងៗទៀត : ១០% គឺសាល់ម៉ូណែលឡូស (ស្រួចស្រាវ)
- និងវីរុស : អូហ្សេស្គី ផ្តាសាយជ្រូក និងជំងឺត្រចៀកខៀវ

### ១០.៣. ការព្យាបាល

- អង់ទីប៊ីយ៉ូទិកដែលមានសកម្មភាពប្រឆាំងនឹងពួក មីកូប្លាស្មាមាន ហ្វ្លរហ្វេនីកុល (Florfenicol) អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) អង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine) ដោយប្រើកម្រិតទ្វេដង នៅថ្ងៃទី ១ ។

## ១១. ជំងឺអាក់ទីណូបាក់ស៊ីលូស (Actinobacillus)

ជំងឺនេះបង្កដោយមេរោគអាក់ទីណូបាក់ស៊ីលូស (Actinobacillus) ។

### ១១.១. រោគសញ្ញា

- ឈាមហូរមានពពុះចេញពីច្រមុះ
- កើតលើជ្រូកដែលមានអាយុពី ៨-១៦ សប្តាហ៍
- រយៈពេលសម្ងំរបស់មេរោគ ១២ម៉ោង
- ក្អកម្តងពី ១-៣ដង (ក្អកមានរយៈពេលខ្លី)
- ពិបាកដកដង្ហើម ជ្រូកចុះខ្សោយកម្លាំង
- ត្រចៀកពណ៌ខៀវ
- សីតុណ្ហភាពលើស ៤០អង្សាសេ ជ្រូកអាចស្លាប់ភ្លាមៗ ហើយអត្រាស្លាប់ខ្ពស់ ។

### ១១.២. ការព្យាបាល

- អាម៉ុកស៊ីលីន (Amoxicillin)



*ឈាមហូរមានពពុះចេញពីច្រមុះ*



ជ្រូកឈឺដោយជំងឺអាក់ទីណូបាក់ស៊ីលូស

- អង់រ៉ូហ្លុកសាក់ស៊ីន ( Enrofloxacine )
- សែហ្វទីយ៉ូហ្វៀរ ( Ceftiofur )

ដោយចាក់កម្រិតទ្វេដងនៅថ្ងៃទី១ចាក់សាច់ដុំ រយៈពេល ៣-៥ថ្ងៃជាប់គ្នា



សួតកើតជំងឺមីកូប្លាស្មា



សួតកើតជំងឺសារទឹក



សួតកើតជំងឺអាក់ទីណូបាក់ស៊ីលូស

## ១២ . ជំងឺអូហ្យេស្គី

ជំងឺនេះបង្កឡើងដោយវីរុស ហើយអាចបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់កូនជ្រូក ។

### ១២.១. រោគសញ្ញា

- កូនជ្រូកអាចស្លាប់ ១០០% តែបើកើតឡើងចំពោះជ្រូកធំ អាចស្លាប់ ១-២ក្បាល
- កូនជ្រូកក្អួត រាគ ញាក់ញ័រ កន្ត្រាក់ខ្លួន ធាក់ជើងខ្វៃៗ
- ជួនកាលជ្រូកប្រកាច់ ដោយសារមេរោគវាយលុកលើប្រព័ន្ធប្រសាទ
- ហើម ឬគ្រាប់ភ្នែកលៀន រឹងថ្គាម
- មេដើម រលូតកូន



### ១២.២.ការព្យាបាល

ជំងឺនេះគ្មានថ្នាំព្យាបាលទេ តែអាចចាក់អង់ទីប៊ីយ៉ូទិក ដូចជា អំពីស៊ីលីន អាម៉ុកស៊ីលីន ...ដើម្បីប្រឆាំងនឹងជំងឺឆ្លៀតឱកាសផ្សេងទៀត ។

### ១២.៣.ការការពារ

ចាក់ថ្នាំការពារឲ្យបានទៀងទាត់ តាមការណែនាំរបស់ក្រុមហ៊ុនផលិតថ្នាំ ។

## ១៣ . ជំងឺរាគ

ជំងឺរាគអាចបណ្ដាលមកពីទឹក ពីចំណី និងមេរោគ ។ ជាទូទៅទោះបីជាកូនជ្រូករាគ ក៏វានៅតែបន្តស៊ីចំណី គ្រាន់តែការលូតលាស់របស់វាយឺត ។

### ១៣.១. រាគបណ្ដាលមកពីទឹក

ទឹកអណ្ដូង ឬត្រពាំង ដែលនៅជិតទ្រុងជ្រូក តែងតែមានលាមកជ្រូកហូរ ឬជ្រាបចូល ជាហេតុធ្វើឲ្យទឹកនោះ ក្រខ្វក់ និងមានមេរោគ ។



លាមករាគមានសុទ្ធតែទឹក

ក. រោគសញ្ញា

កូនជ្រូករាគមានសុទ្ធតែទឹក និងលាមកមានពណ៌លឿង

ខ. ការព្យាបាល

ប្រើទ្រីមេតូព្រីម ជាមួយស៊ុលហ្វា

១៣.២. រាគបណ្តាលមកពីចំណី

វត្ថុធាតុដើមខ្លះមានគុណភាពអន់ ដូចជាពោត មានជាតិពុលមីកូតុកស៊ីន (ផ្សិតក្លួត) ម្សៅត្រីរក្សាទុកមិនបានល្អ ចំណីដែលមានតែកន្ទក់សុទ្ធ ឬកន្ទក់មានគុណភាពអន់ ធ្វើឲ្យជ្រូករាគមានសភាពផុកៗ ពណ៌ត្នោតស្រាល ។

ការព្យាបាល

ធ្វើការប្តូរចំណី ។



លាមករាគមានពណ៌ត្នោត

១៣.៣. រាគបណ្តាលមកពីមេរោគអ៊ីកូលី (E.Coli)

ជំងឺនេះបង្កឡើងដោយមេរោគអ៊ីកូលី (E.Coli) ។ ពេលផ្តាច់ដោះគឺជាពេលមួយដែលទឹកដោះចុះថយ និងអង់ទីគ័ររបស់កូនជ្រូកចុះខ្សោយ ជាឱកាសល្អដែលមេរោគអ៊ីកូលីបង្កបញ្ហាលើពោះវៀន បណ្តាលឲ្យកូនជ្រូក មានជំងឺរាគរុំរ៉ៃ ។

ប្រសិនបើពេលផ្តាច់ដោះកូនជ្រូកនៅក្មេងពេក ឬទម្ងន់តិចជាង ៦គក្រ ជាហេតុធ្វើឲ្យពួកវាងាយរាគ ។ ការរាគនេះកើតមានឡើងក្នុងកំឡុងពេល ៥ ថ្ងៃក្រោយពេលផ្តាច់ដោះ បង្កឲ្យកូនជ្រូកឈឺ និងស្លាប់ ។ កូនជ្រូក រាគ លាមកមានពណ៌ប្រផេះស លឿង និងបៃតង រាវ ឬម្សៅផុកៗ ។

គួរផ្តល់ចំណីផ្សំស្រេចដល់កូនជ្រូក ដែលមានជាតិប្រូតេអ៊ីន ២០% ព្រោះងាយស្រួលរំលាយ និងជួយឲ្យកូនជ្រូកលូតលាស់លឿន ។



កូនជ្រូករាគ លាមកមានពណ៌បៃតង




អង់រ៉ូហ្វុកសាក់ស៊ីន ៥% (Enrobioflox)

ការព្យាបាល

- ចាក់កូលីស្ទីន (Ampidexalone, Biocolistine, Ampicoli) ២សេសេ/ក្បាល ព្រឹក និងល្ងាច
- ឬចាក់អង់រ៉ូហ្វ្លុកសាក់ស៊ីន ៥% (Enrobioflox) ២សេសេ/ ក្បាល/ថ្ងៃ
- លាយកូលីស្ទីន (Colistin) ក្នុងចំណីឲ្យកូនជ្រូកស៊ីរយៈពេល ៣ថ្ងៃ ។

១៣.៤. រាគបណ្ដាលមកពីមេរោគកុកស៊ីឌីយ៉ូស៊ីស (Coc-cidiosis)

ជំងឺនេះកើតលើកូនជ្រូកអាយុពី ៧-២១ថ្ងៃ ។

ក. រោគសញ្ញា

- រាគប្រែពីពណ៌លឿង ទៅជាពណ៌ប្រផេះបៃតង។ កូនជ្រូកស្គមជ្រីវជ្រួញខុសពីធម្មតា ។

ខ. ការព្យាបាល

- ប្រើស៊ុលហ្វា (សិបទ្រីល សុលហ្វា ៣៣ ...)

គ. ការការពារ

- បញ្ចូកតុលត្រាសេរីល (បេកុក ឬ អង់ទីកុក) (Toltrazuril) ១មល តាមមាត់ ពេលកូនជ្រូកមានអាយុ ៣ថ្ងៃ ។



លាមកកូនជ្រូកមានជំងឺ Coccidiosis



កូនជ្រូកផ្ដាច់ដោះបន្ទាប់ពីមានជំងឺ Coccidiosis

១៣.៥. រាគបណ្ដាលមកពីមេរោគក្លូស្ទ្រីដ្យូម

ជំងឺនេះកើតឡើងចំពោះកូនជ្រូកដែលដើររកចំណីស៊ីដោយខ្លួនឯង ។

ក. រោគសញ្ញា

- កូនជ្រូករាគខ្លាំង មានក្លិនស្អុយ ជាទូទៅមានលាយឈាម
- កើតលើកូនជ្រូកអាយុពី១-៧ថ្ងៃ
- កូនជ្រូកស្លាប់ច្រើន

ខ. ការព្យាបាល

- ចាក់អាម៉ុកស៊ីលីន យកល្អគួរបញ្ចូកតាមមាត់។



កូនជ្រូកដើររកស៊ីចំណីដោយខ្លួនឯង



កូនជ្រូករាគបណ្ដាលមកពីមេរោគ ក្លូស្ទ្រីដ្យូម

១៣.៦. រាគបណ្ដាលមកពីជំងឺសាល់ម៉ូណែលឡ

ជំងឺនេះកើតឡើងលើជ្រូកក្នុងដំណាក់កាលកំពុងលូតលាស់ ។ ពេលដែលជ្រូកជាពីជំងឺប៉េស្ដ ជាទូទៅវានឹងកើតជំងឺសាល់ម៉ូណែលឡាតាមក្រោយ ។

ក. រោគសញ្ញា

- រាគមានតែទឹក ក្លិនស្អុយ អាចមានលាយឈាម
- ឈឺចាប់ពេលដកដង្ហើម (ក្អក)
- ស្បែកខ្លួន និងស្បែកកន្ទុយមានពណ៌ក្រហមហើយ

ត្រចៀកមានពណ៌ខៀវ

- ខាន់លឿង ព្រោះថ្លើមខូច

ខ. ការព្យាបាល

- ចាក់អង់រ៉ូហ្លកសាក់ស៊ុន ។

គ. ការការពារ

- មិនត្រូវចាក់វ៉ាក់សាំងទេ
- ធ្វើអនាម័យទ្រុង ធ្វើការសម្លាប់មេរោគ និងកំចាត់កុំឲ្យមានសត្វកណ្ដុរ ។





រាគមានតែទឹកលាយឈាម

១៣.៧. រាបណ្ដាលមកពីរលាកពោះវៀន

ជំងឺនេះកើតឡើងចំពោះលើជ្រូកក្នុងដំណាក់កាលកំពុងលូតលាស់ ។

សភាពរ៉ាំរ៉ៃ: លាមករាគសុទ្ធតែទឹក មានពណ៌ ប្រផេះ ដែលធ្វើឲ្យការលូតលាស់យឺត

សភាពស្រួចស្រាវ : លាមករាគ មានលាយឈាម ធ្វើឲ្យជ្រូកមានសភាពស្លេកស្លាំង ។

ក. ការព្យាបាល

- ប្រើទីឡូស៊ីន (Tylosin) ដូចជាទីឡូបូក (Tylo+) និង ទីប៊ីយ៉ង់ (Tylbian) ... ។



រាគមានពណ៌ប្រផេះ

ខ. ការការពារ

- នៅពេលផ្លាស់ប្ដូរជ្រូកទៅទ្រុងបំប៉ន ត្រូវលាយទីឡូស៊ីន ជាមួយអុកស៊ីតេត្រាស៊ីគ្លីន (Tylosin + Oxytetracycline) ឲ្យវាស៊ីរយៈពេល ៥ថ្ងៃ
- ធ្វើអនាម័យទ្រុង ធ្វើការសម្លាប់មេរោគ និងកំចាត់កុំឲ្យមានសត្វកណ្ដុរ ។

**១៤. ព្រូនអាស្ការីស** (Ascaris)

អាស្ការីសមាននៅក្នុងពោះវៀន និងសួត ។ វាមានប្រវែងពី ២៥០-៤០០មម ។ មានព្រូនជាច្រើនរស់នៅក្នុងពោះវៀន បានស្រូបយកជីវជាតិ ដែលជ្រូកបានលេបចូល ធ្វើឲ្យជ្រូកមានការលូតលាស់យឺត ។ នៅពេលដែលកូនព្រូនធ្វើបន្លាស់ទីក្នុងសួត បណ្ដាលឲ្យជ្រូកក្អក ។

ការការពារ / ការព្យាបាល

- ចាក់អ៊ីវ៉ែមិចទីន(Ivermectine) ។



ព្រូននៅជាប់គូថជ្រូក

## ១៥. ក្លូន ឬអ៊ែរកនី

កើតឡើងដោយសារការដាច់សន្ទះផ្ចិត ឬក្រលៀន ដែលធ្វើឲ្យពោះវៀនធ្លាក់ទៅក្រោមស្បែក ធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់របស់សត្វ ។ ការធ្លាក់ពោះវៀននេះគ្មានការព្យាបាលទេ ។

### ១៥.១. រោគសញ្ញា

- ហើមទំហំពី ៣០-២០០មម លយចេញពីផ្ចិត និង ពោះ ឬពីមុខពងស្វាស ។



*ជ្រូកកើតក្លូន ដោយសារដាច់សន្ទះផ្ចិត*

### ១៥.២. ការការពារ

- ចាក់អាម៉ុក អិលអេ លើកូនជ្រូកដែលទើបនឹងកើតបាន ២៤ម៉ោង ។
- មិនត្រូវក្រៀវកូនជ្រូកដែលធ្លាក់ពោះវៀនឡើយ ។

## ១៦. ជំងឺរលាកតម្រងនោម ឬផ្លោកនោម

ជំងឺនេះច្រើនកើតលើមេជ្រូក និងជ្រូកសាច់ ។ ប៉ុន្តែជ្រូកស៊ីចំណីជាធម្មតា ។

### ១៥.១. រោគសញ្ញា



*ខ្ទុះលើកម្រាលឥដ្ឋ*

- ជាជំងឺរ៉ាំរ៉ៃ តែមិនបណ្ដាលឲ្យជ្រូកស្លាប់ទេ
- ខ្ទុះលាយជាមួយទឹកនោម ឬមានទឹកហូរចេញពណ៌ស ជាប់ប្រដាប់បន្តពូជ
- មានខ្ទុះនៅលើកម្រាល ឬនៅជាប់ទ្រុង ។

### ១៥.២. ការព្យាបាល

- ប្រើអង់ទីប៊ីយ៉ូទិក ដូចជាចាក់ ឬលាយក្នុងចំណី នូវអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ឬ ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+sulfa) ។

### ១៥.៣. ការការពារ

- ផ្ដល់ទឹកស្អាត និងឲ្យជ្រូកផឹកទឹកឲ្យបានគ្រប់គ្រាន់។

## ១៧. ជំងឺរលាកស្បូន ឬផ្លោកនោម

មេជ្រូកមិនស៊ីចំណី ហើយបង្ហាញអាការៈឈឺចាប់ ។ ជំងឺនេះកើតមានឡើងក្រោយពេលមេជ្រូកកើតកូនបាន ៤-៥ថ្ងៃ

### ១៦.១. រោគសញ្ញា

- ភ្នែកក្រហម
- គ្រុនក្ដៅ សីតុណ្ហភាពលើស ៤០អង្សាសេ
- ទឹកពណ៌ស ឬពណ៌ត្នោត ហូរតាមប្រដាប់បន្តពូជ
- ជុំវិញប្រដាប់បន្តពូជមានភាពសើម ហើយហូរឈាម
- ទឹកនោមមានលាយឈាម និងខ្ទុះ
- អត់ទឹកដោះ
- មានសញ្ញាលៀសដោះ
- ជាទូទៅជ្រូកនឹងស្លាប់ក្នុងពេល ២-៣ថ្ងៃ ក្រោយ។



*ឈាមហូរតាមប្រដាប់បន្តពូជ*



ហូរខ្ទុះតាមប្រដាប់បន្តពូជ



ទឹកនោមមេជ្រូកមានពណ៌លឿងខ្ចី

១៦.២.ការព្យាបាល

- ចាក់អង់ទីប៊ីយ៉ូទិក ដូចជាអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine) ២ដង/ថ្ងៃ
- ប្រើអង់ទីប៊ីយ៉ូទិកដូចជា អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ឬ ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+sulfa) ។

## ១៨. ដំបៅលើប្រដាប់បន្តពូជ

ពេលប្រដាប់បន្តពូជមានដំបៅ មេជ្រូកមិនអាចបង្កាត់បាន ព្រោះវាមានការលំបាកក្នុងការកើតកូន ហើយមេរោគក៏ងាយឆ្លងចូលក្នុងស្បូន ។ មូលហេតុបណ្តាលឲ្យមានដំបៅនៅប្រដាប់បន្តពូជ គឺមុតដោយសារខាំគ្នា ឬត្រដុសទ្រុង

១៨.១. រោគសញ្ញា

- មានស្នាមដាច់
- បូស ឬហើម ។

១៨.២. ការព្យាបាល

- យកមេជ្រូកឈឺចេញពីហ្វូង
- ប្រើអង់ទីប៊ីយ៉ូទិកដូចជា អាម៉ុកស៊ីលីន (Amoxi-cillin) ។

## ១៩. ទឹកនោមមានពណ៌ខុសពីធម្មតា

រាល់ពេលមេជ្រូកនោម ត្រូវពិនិត្យមើលទឹកនោមរបស់វា បើទឹកនោមប្រែពីពណ៌លឿងខ្ចីទៅជាពណ៌លឿងចាស់ បានន័យថា មេជ្រូកផឹកទឹកមិនគ្រប់គ្រាន់ ធ្វើឲ្យកំហាប់ទឹកនោមប្រែពណ៌ លាមកស្ងួត ភ្នែកខូង ។

១៩.១. ផលប៉ះពាល់

- ចំពោះមេបំបៅកូន ការផលិតទឹកដោះតិច
- ចំពោះមេដើម ធ្វើឲ្យរលាកផ្លោកនោម
- ចំពោះជ្រូកសាច់ ធ្វើឲ្យការលូតលាស់យឺត ដោយសារវាស៊ីចំណីតិច

១៩.២. ការព្យាបាល

- ចំពោះមេដើម ឲ្យវាផឹកទឹកពី ២០-៣០លីត្រ/ថ្ងៃ
- ចំពោះមេបំបៅកូន ឲ្យវាផឹកទឹកពី ៣៥-៤៥លីត្រ/ថ្ងៃ ។

## ២០. ដំបៅក្រពះ

មូលហេតុដែលធ្វើឲ្យក្រពះមានដំបៅ ដោយសារគុណភាពវត្ថុធាតុដើមក្នុងចំណីអន់ និងក្នុងចំណីមានជាតិសរសៃមិនគ្រប់គ្រាន់ ។



ក្រពះមានដំបៅ

### ២០.១. រោគសញ្ញា

- ជាទូទៅកើតលើមេជ្រូក និងជ្រូកសាច់
- មិនស៊ីចំណី តែសីតុណ្ហភាពក្នុងខ្លួនឡើង
- ស្បែកស្លេកស្លាំង (ដោយសារហូរឈាម)
- លាមកខ្មៀន (លាមកពណ៌ខ្មៅ)
- ក្អួត

### ២០.២. ការព្យាបាល

- ផ្តល់ចំណី ៤-៥ដង/ថ្ងៃ ដោយលាយជាមួយទឹក ដើម្បីឲ្យចំណីទន់
- ផ្តល់បន្លែស្រស់
- ចាក់ការ៉ាស៊ីល (Carasil) អេម៉ាតូប៉ង់ (Hematopan) ដើម្បីជំរុញឲ្យវាស៊ីចំណី
- ផ្តល់វីតាមីនបេ១២ (Vitamin $B_{12}$) ។

## ២១. ការប្រកាច់

ការប្រកាច់បង្កឡើងដោយមេរោគ ស្ត្រិបតូកុកគូស (Streptococcus) ។ ជំងឺនេះច្រើនកើតលើកូនជ្រូកផ្តាច់ដោះ ។ ជួនកាលមានកូនជ្រូកស្លាប់ ១-២ ក្បាល ដោយមិនបញ្ចេញរោគសញ្ញា ។ ចំណែកកូនជ្រូកដែលឈឺ ឬស្លាប់ ច្រើនតែកូនជ្រូកដែលធំជាងគេ ។



*កូនជ្រូកប្រកាច់*

### ២១.១. រោគសញ្ញា

- ដើរទ្រេតទ្រោត រួចប្រកាច់ជើងខ្វែៗ
- កូនជ្រូកដេកផ្ងៀង ហើយញាក់ៗ បែកពពុះមាត់
- លាមកខ្មៀន (លាមកពណ៌ខ្មៅ
- មានសីតុណ្ហភាព ៤១អង្សាសេ
- កូនជ្រូកអាចនិងស្លាប់នៅ ២-៣ម៉ោងក្រោយ

### ២១.២. ការព្យាបាល

- យកកូនជ្រូកដែលឈឺចេញ និងដាក់វានៅកន្លែងស្ងាត់
- ដំបូងចាក់ដិចហ្សាមេតាហ្សូន (Dexamethasone) ឬតុលហ្វេឌីន (Tolfedine)
- បន្ទាប់មកចាក់អាម៉ុកស៊ីលីន (Amoxicillin)
- ផ្តល់វីតាមីនបេ១២ (Vitamin $B_{12}$) ។

### ២១.៣. ការការពារ

- មុននឹងយកកូនជ្រូកទៅដាក់នៅទ្រុងផ្តាច់ដោះ ត្រូវធ្វើការសម្លាប់មេរោគក្នុងទ្រុងជាមុនសិន ។
- នៅពេលមានកូនជ្រូកណាមួយឈឺ ចាំបាច់ត្រូវលាយអាម៉ុកស៊ីលីន (Amoxicillin) ក្នុងចំណីឲ្យកូនជ្រូកទាំងអស់ក្នុងទ្រុងស៊ី រយៈពេល ៥ថ្ងៃជាប់គ្នា ។

## ២២. ជំងឺតេតាណូស

ជំងឺតេតាណូស បណ្តាលមកពីមិនបានធ្វើអនាម័យល្អនៅពេលក្រៀវ ឬពេលកាត់ទងផ្ចិត ។



*រោគសញ្ញានៃជំងឺតេតាណូស*

### ២២.១. រោគសញ្ញា

- រឹងជើង និងសាច់ដុំ
- កន្ទុយត្រង់

### ២២.២. ការព្យាបាល

- ដំណាក់កាលដំបូងប្រើប៉េនីស៊ីលីនកម្រិតខ្ពស់ប្រចាំថ្ងៃ (កម្រិតទ្វេដង) ។

## ២៣. ជំងឺហើម

កើតឡើងដោយសារការផ្តាច់ដោះ និងការផ្លាស់ប្តូរចំណី ជំងឺនេះបង្កឡើងដោយបាក់តេរី (E.Coli) ដែលធ្វើឲ្យ

បែកសរសៃឈាម ជាពិសេសសរសៃឈាមខួរក្បាល (រោគសញ្ញាប្រព័ន្ធប្រសាទលេចចេញឡើង)។



ជាំឈាមនៅបរិវេណភ្នែក

២៣.១. រោគសញ្ញា

- កើតឡើង ២សប្តាហ៍ ក្រោយពេលផ្តាច់ដោះ
- ជ្រូកមិនអាចបញ្ជាខ្លួនឯងបាន ដើរដូចមនុស្សស្រវឹង
- ភ្នែកក្រហម (រលាកជុំវិញបរិវេណភ្នែក) ដោយមានហូរទឹកមកជាមួយ មិនយូរប៉ុន្មានត្របកភ្នែកនឹងបិទជិត ហើយស្អិត
- មានសីតុណ្ហភាពលើស ៤១អង្សាសេ
- ជាំឈាមក្រោមស្បែក
- កូនជ្រូកស្លាប់លឿន ដោយមិនទាន់បានព្យាបាល

២៣.២. ការព្យាបាល

- យកកូនជ្រូកដែលឈឺចេញ និងដាក់វានៅកន្លែងស្ងាត់
- ចាកទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+sulfa) ឬអង់រ៉ូហ្វ្លុកសាក់ស៊ីន (Enrofloxacine) ។

២៣.៣. ការការពារ



នៅពេលប្រឹងដើរ ជ្រូកមិនអាចបញ្ជាខ្លួនឯងបាន

- ផ្តល់ចំណីពិសេសដល់កូនជ្រូកផ្តាច់ដោះ
- ប្រើក្លរីនសម្លាប់មេរោគអឺកូលី (E.Coli) ក្នុងទឹក

## ២៤. ជំងឺរលាកសន្លាក់

ជំងឺនេះបង្កឡើងដោយសារបាក់តេរី ស្រ្តិបតូកុកកូស (Streptococcus) ដែលតែងកើតលើកូនជ្រូកកំពុងបៅដោះ។

២៤.១. រោគសញ្ញា

- ខ្វកជើង ហើមសន្លាក់
- ជ្រូកមានសភាពឈឺចាប់
- មិនចង់ក្រោកឈរ



កូនជ្រូកមានបញ្ហារលាកសន្លាក់

២៤.២. ការព្យាបាល

- ប្រើឡាំងកូមីស៊ីន (Lincomycin) អាម៉ុកស៊ីលីន Amoxicillin) ។

២៤.៣. ការការពារ

- ត្រូវចាក់អាម៉ុកស៊ីលីន អិលអេ (Amoxicillin LA) ក្រោយពេលកូនជ្រូកកើតបាន ១ថ្ងៃ ។

## ២៥. បែកក្រចកជើង

ការបែកក្រចកជើងច្រើនមាននៅចន្លោះខ្នែងក្រចក និងក្រចកជើង ដោយសារកម្រាលមិនល្អ ។

២៥.១. រោគសញ្ញា

- ជ្រូកពិបាកដើរ ព្រោះហើមកជើង
- សភាពហើម មាននៅជុំវិញកជើង ហើយបង្កជាបូស

២៥.២. ការព្យាបាល

- ប្រើឡាំងកូមីស៊ីន (Lincomycin) / ទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (TMP+sulfa)

- កម្រាលទ្រុងត្រូវរាយអង្កាមពីលើ
- បាញ់ស្ព្រាយពពួកអុកស៊ីតេត្រាស៊ីគ្លីន ( Spray OTC ) ត្រង់មុខរបួស ។



ស្នាមដំបៅនៅជើង



ព្យាបាលដោយប្រើ អុកស៊ីតេត្រាស៊ីគ្លីន ( Spray OTC )

## ២៦. ជំងឺអុតក្តាម ( FMD )

### ២៦.១. រោគសញ្ញា

- ក្រចកជើងលឿន
- ជ្រូកចូលចិត្តដេក
- នៅពេលដើរ ជ្រូកមានសភាពឈឺចាប់ ហើយស្រែកខ្លាំង
- មានពងដោរនៅគល់ក្រចក និងច្រមុះ។

### ២៦.២. ការព្យាបាល

- ទ្រីមេតូព្រីមជាមួយស៊ុលហ្វា ( TMP+sulfa )អុកស៊ីតេត្រាស៊ីគ្លីន ( OTC )
- សំអាតមុខរបួសជាមួយសាប៊ូ ហើយបាញ់ស្ព្រេពពួកអុកស៊ីតេត្រាស៊ីគ្លីន ( Spray OTC )
- ប្រើអាណាលហ្សាំង ( Analgine ) តុលហ្វេឌីន ( Tolfedine ) ដើម្បីបញ្ចុះកំដៅ ។

### ២៦.៣. ការការពារ

- ចាក់វ៉ាក់សាំងការពារជំងឺអុតក្តាម ។



# ជំងឺប្រផេះសលើស្លឹកកៅស៊ូ

ដោយៈ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ជំងឺប្រផេះសលើស្លឹក ជាជំងឺដែលកើតមានលើដើមកៅស៊ូស្ទើរគ្រប់ទិសទីពាសពេញបណ្តាប្រទេសដាំកៅស៊ូលើសាកលលោក។ នៅទ្វីបអាស៊ីដែលជាកន្លែងដាំកៅស៊ូច្រើនជាងគេនោះ ( ប្រហែល៩៣%នៃផលិតផលកៅស៊ូធម្មជាតិសរុបលើពិភពលោក ) មានតែប្រទេសប្រជាមានិតចិនមួយទេ ដែលពុំសូវកើតនូវជំងឺនេះខ្លាំងក្លា។ ជំងឺប្រផេះសលើស្លឹកកើតខ្លាំងនៅប្រទេសម៉ាឡេស៊ី ពិសេសនៅតាមតំបន់ក្បែរឆ្នេរសមុទ្រដែលឧស្សាហ៍មានភ្លៀងរលឹមតិចៗ ក្នុងពេលយប់ និងរយៈពេលខ្លីនារដូវប្រាំង ព្រោះវាអំណោយផលដល់ការរីកដុះដាលនៃផ្សិតប៉ារ៉ាស៊ីត ឈ្មោះអូអ៊ីដ្យូម ( Oidium )។ នៅទ្វីបអាហ្វ្រិក ជំងឺនេះកើតឡើងច្រើននៅប្រទេសហ្សាអៀរ និងតំបន់ទំនាបនៃប្រទេសកុងហ្គោ ចំណែកនៅអាហ្វ្រិកខាងលិច គេជួបប្រទះជំងឺនេះតែបន្តិចបន្តួចប៉ុណ្ណោះ។

ចំពោះប្រទេសកម្ពុជា ជំងឺប្រផេះសលើស្លឹកកើតមាននៅគ្រប់តំបន់ដែលមានចម្ការកៅស៊ូ។ ប៉ុន្តែការរាតត្បាតនៃជំងឺនេះជួនខ្លាំងជួនខ្សោយ អាស្រ័យទៅតាមពូជកៅស៊ូ និងការប្រែប្រួលនៃអាកាសធាតុក្នុងបណ្តាឆ្នាំនីមួយៗដែលជាកត្តា រួមផ្សំធ្វើឲ្យផលិតផលជ័រឡើងចុះមិនទៀងទាត់។

ជំងឺនេះ កើតឡើងលើដើមកៅស៊ូគ្រប់វ័យតាំងពីក្នុងថ្នាលកូនដើមស៊ីដលីង ( Seedling ) និងតាមចម្ការដែលស្លឹកនៃមែកក្រោមៗ មិនសូវបានទទួលពន្លឺថ្ងៃគ្រប់គ្រាន់ ( រូបទី១ និងរូបទី២ )។ ម៉្យាងទៀតវាអាចកើតមាននៅគ្រប់រដូវ តែសំខាន់ជាងគេគឺនៅដើមរដូវប្រាំង ពេលដែលដើមកៅស៊ូចាប់ផ្តើមលាស់ស្លឹកថ្មី។ នៅក្នុងចម្ការជួនកាលជំងឺនេះ បណ្តាលឲ្យស្លឹកខ្ចីទើបលាស់ថ្មីនេះស្លោកហើយជ្រុះក្រាលមកលើផ្ទៃដី។





(រូបទី១)កូនកៅស៊ូដែលកើតជំងឺមានសញ្ញារួញស្លឹក(រូបទី២)ដើមកៅស៊ូប្រែពណ៌ពីត្នោតក្រៀវទៅជាបៃតងលឿង

## បុព្វហេតុនៃជំងឺ:

ជំងឺនេះបណ្តាលពីផ្សិតម្យ៉ាងឈ្មោះ OidiumheveaSteinm។ ផ្សិតនេះរីករាលដាលខ្លាំង នៅក្នុងលក្ខខណ្ឌអាកាសធាតុក្តៅហើយសើម គឺថាប្រសិនបើរដូវស្លឹកកៅស៊ូទើបលាស់ថ្មីនោះប៉ះនឹងអាកាសធាតុពេលថ្ងៃក្តៅស្អុះស្អាប់ ហើយពេលយប់មានធ្លាក់សន្សើមឬភ្លៀងរលឹមតិចៗ ដែលខ្មែរយើងហៅថារលឹមរោយស្បៃនោះ វាជាលក្ខណៈ អំណោយផលដល់ការរីករាតត្បាតនៃជំងឺនេះ។ ផ្សិតខាងលើនេះកើតមានដូចគ្នានៅលើ ផ្កាកៅស៊ូ ដោយបណ្តាល ឲ្យជ្រុះ ផ្កានិងមិនកាន់ផ្លែ។

ការឆ្លងជំងឺពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតដោយស្ព័រ (Spores) ដែលបើុងតាមខ្យល់ ឬតាមរយៈ សត្វស្លាប ដែលហើរមកទំពីកន្លែងមួយទៅកន្លែងមួយទៀត។ ពេលប៉ះនឹងលក្ខខណ្ឌសមស្រប ស្ព័រនេះក៏ដុះជាប្រូតាល់ ហើយចាក់ចូលទៅក្នុងស្រទាប់ជាលិកានៃស្លឹកខ្ចី ដោយទំលុះស្រទាប់គុយទីន (La cuticule) ដែលនៅមានស្រទាប់ស្តើងខ្ចីនៅឡើយ ជួនកាលស្ព័រក៏អាចជ្រៀតចូលទៅក្នុងជាលិកានៃស្លឹកតាមប្រហោងស្តូម៉ាត (Stomates) ដែរ។ ពេលនោះផ្សិត Oidium បឺតជញ្ជក់យកជីជាតិពីកោសិកា (អេពីដែម) នៃស្លឹកខ្ចី ហើយក្នុងរយៈពេល៤ទៅ៥ថ្ងៃក្រោយមក ផ្សិតនេះលូតលាស់ពេញរូបរាងហើយបង្កើតបានជាស្ព័រថ្មីទៀតយ៉ាងច្រើនដេរដាស រួចបន្តរាតត្បាតទៅកាន់ស្លឹកនៃដើមដទៃទៀត។

## រោគសញ្ញា:

ស្លឹកកៅស៊ូដែលទើបលាស់ក្នុងដំណាក់កាលទី១ ប្រហែល២ទៅ៣ថ្ងៃដំបូង ឆាប់ទទួលរងជំងឺនេះជាងគេ។ ពេលចាប់ផ្តើមដំបូង គេសង្កេតឃើញស្លឹកខ្ចីតូចៗឡើងស្រពោនរួញ ហើយមានសរសៃមីសេល្យូម ( Mycelium ) ឆ្មារៗ ពណ៌សនៅលើផ្ទៃស្លឹកផ្តុំជាចំនុចមានទំហំ ២-៣មីលីម៉ែត្រ រហូតដល់ ១-២ សង់ទីម៉ែត្រ។ បណ្តុំផ្សិតនេះមានពណ៌ស ស្អាប់ដូចជាធូលីហើយប្រឡាក់ជាប់តាមម្រាមដៃ បើសិនយើងបានប៉ះវា។

ស្លឹកដែលកើតជំងឺនេះធ្ងន់ធ្ងរ ធ្វើឲ្យផ្ទៃស្លឹកដែលរួញខ្វរនេះ ប្រែពណ៌ពីត្នោតភ្លាវទៅជាបៃតងលឿង ចាប់ពីចុងស្លឹកមក ឬជួនកាលពីសង្ខាងគែមស្លឹកមក ក្រោយមកក្លាយទៅជាពណ៌ក្រម៉ៅ មុនពេលដែលវាជ្រុះមកដី ក្នុងអំឡុងពេល ៥ទៅ៦ថ្ងៃ បន្ទាប់ពីកើតជំងឺ ដោយបន្សល់ទុកនូវទងស្លឹកនៅជាប់នឹងមែកមួយរយៈ មុននឹងវាជ្រុះមកដីដែរ ( រូបទី៣ និងរូបទី៤)។

ចំពោះស្លឹកថ្មីដែលមានអាយុលើសពី១០ថ្ងៃ ស្រទាប់គុយទីននៃស្លឹកចាប់ផ្តើមក្រាស់ជាងមុន ហើយស្លឹកមានពណ៌បៃតងខ្ចី។ នៅរយៈពេលនេះការរាតត្បាតនៃផ្សិតអូអ៊ីដ្យូម ( Oidium ) ពុំបណ្តាលអោយជ្រុះស្លឹកមកដីទេ។ ផ្នែកនៃជាលិកាស្លឹកដែលកើតជំងឺត្រូវងាប់ព័ទ្ធជុំវិញស្នាមងាប់នេះដោយរង្វង់ពណ៌លឿងលើផ្ទៃស្លឹក ឯផ្នែកស្លឹកដែលនៅរស់មានពណ៌លឿងព្រាលហើយបើគេយកស្លឹកនេះទៅឆ្លុះនឹងពន្លឺ ផ្ទៃស្លឹកនេះមានពណ៌ចាំងថ្លាខុសពីស្លឹកល្អធម្មតា។

ក្នុងករណីដែលជំងឺនេះកើតឡើងធ្ងន់ធ្ងរ អាចធ្វើឲ្យស្លឹកខ្ចីទើបលាស់ត្រូវតែជ្រុះមកក្រាលលើដី ហើយចេះតែបន្តជ្រុះសារជាថ្មីនៅពេលដែលដើមកៅស៊ូព្យាយាមដុះស្លឹកថ្មី ហើយធ្វើអោយដើមកៅស៊ូចុះខ្សោយមិនសូវមានស្លឹកនាំអោយផលិតផលជ័រកៅស៊ូធ្លាក់ចុះ។ ស្លឹកដែលមានអាយុលើសពី៣សប្តាហ៍មិនទទួលរងជំងឺនេះទេ។



(រូបទី៣)រោគសញ្ញាជំងឺប្រផេះស



(រូបទី២)រោគសញ្ញាជំងឺប្រផេះស



រោគសញ្ញាជំងឺប្រផេះស

## វិធានការការពារ

នៅប្រទេសកម្ពុជា ជំងឺប្រផេះសគេប្រទះឃើញកើតមានស្ទើរតែគ្រប់ពូជកៅស៊ូ គ្រាន់តែពូជខ្លះកើតខ្លាំង ឯពូជខ្លះទៀតមិនសូវធ្ងន់ធ្ងរ ( ពូជដែលជ្រុះនិងលាស់ស្លឹកថ្មីមុនគេមិនសូវរងជំងឺនេះខ្លាំងទេ ដូចជាពូជ PB 86 ជាដើម )។ នៅប្រទេសម៉ាឡេស៊ីពូជដែលកើតជំងឺនេះច្រើនជាងគេមានពូជ PB5/51, Tjir 1, PB28/59, RRIM605 និង RRIM628 ( យោង តាមសៀវភៅ Maladies of Hevea in Malaysia )។

ដើម្បីការពារ ពុំគប្បីដាំពូជកៅស៊ូណាដែលងាយកើតជំងឺខាងលើនៅក្នុងតំបន់ដែលរងការរាតត្បាតជំងឺនេះទេ។ ម៉្យាងវិញទៀតគេអាចបន្ថយ ឬជៀសវាងការកើតជំងឺនេះចំពោះដើមកៅស៊ូធំដោយវិធីជំរុះស្លឹកចាស់មុនរដូវកាល គឺគេបាញ់ថ្នាំជំរុះស្លឹក ប្រហែលរយៈពេលមួយខែមុនពេលជ្រុះស្លឹកតាមធម្មជាតិ ប្រយោជន៍អោយដើមកៅស៊ូលូតលាស់សន្លឹកថ្មីមុនដើមរដូវក្ដៅមកដល់។

ការបំប៉នបន្ថែមជីអាសូត លាយជាមួយជីគីមីដទៃទៀតទៅលើចម្ការកៅស៊ូនៅចុងរដូវភ្លៀងក៏អាចកាត់បន្ថយនូវការកកើតជំងឺខាងលើនេះបានដែរ។ បច្ចុប្បន្ននេះ គេនិយមប្រើ នៅប្រទេសមួយចំនួនដូចជា វៀតណាម ម៉ាឡេស៊ី ជាដើម។ រីឯប្រទេសស្រីលង្កានិងឥណ្ឌូនេស៊ី គេអនុវត្តន៍ការបាញ់ថ្នាំមុននៅពេលដើមកៅស៊ូទើបចាប់ផ្ដើមលាស់សន្លឹកថ្មី ចំពោះចម្ការណាដែលមានរយៈកម្ពស់ចាប់ពី៣០០ម៉ែត្រឡើងទៅ។

## វិធានការព្យាបាល

ដោយប្រើម្សៅស្ពាន់ធ័រព្រាចលើអាកាសតាមយន្តហោះ ឬប្រើម៉ាស៊ីនព្រាចម្សៅ ( Motor powder use ) ពីដីចំនួនពី៤ទៅ៥ដង បាញ់អំឡុង៥ថ្ងៃម្ដងដោយបរិមាណម្សៅស្ពាន់ធ័រ ៣-៥គីឡូក្រាម/ហិកតា សំរាប់ព្រាចម្ដង។

ប្រើថ្នាំប្រឆាំងស្ព័រ (Anti-sporulante) ដូចជាប្រភេទថ្នាំឈ្មោះ Tridemorpheក្នុងបរិមាណថ្នាំ៥៦០ក្រាម លាយជាមួយប្រេង១២លីត្រ សំរាប់មួយហិកតាបាញ់ម្ដង ដោយប្រើម៉ាស៊ីនបាញ់ថ្នាំបាញ់៣សារ ចន្លោះពេលក្នុងការបាញ់ម្ដង ក្នុងរយៈពេលពី៧ទៅ១០ថ្ងៃ។

ចំណែកឯនៅថ្នាលបណ្ដុះកូន គេប្រើពពួកថ្នាំសម្លាប់ផ្សិតដែលមានសារធាតុដើមពីជាតិ Acidedithiocarbamique ដូចជា ManebeឬMancozebe ដោយលាយកំហាប់ធាតុសកម្មនៃថ្នាំ៨០០ក្រាម ក្នុងទឹក ២០០លីត្របាញ់ ២ដងមួយសប្ដាហ៍។



*ការប្រើម៉ាស៊ីនព្រាចម្សៅស្ពាន់នៅប្រទេសវៀតណាម*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៣៩៦ កសក

## សារាចរណែនាំ
## ស្តីពី
## វិធានការជំរុញការស្តារឡើងវិញការខូចខាតដោយគ្រោះទឹកជំនន់រដូវវស្សា ឆ្នាំ ២០១៣

នៅរដូវវស្សាឆ្នាំ២០១៣ នេះ ជាទូទៅភ្លៀងបានចាប់ផ្តើមធ្លាក់តាំងពីដើមរដូវដោយមានរបាយស្មើល្អនៅស្ទើរទូទាំងប្រទេស ផ្តល់អំណោយផលល្អដល់ការងារបង្កបង្កើនផលស្រូវ ជាពិសេសស្រូវបង្កើនរដូវដែលអាចអនុវត្តបានលើផ្ទៃដីចំនួន ២២៩.៨៦៩ហិកតា តិចជាងឆ្នាំមុន១៧.៦១៧ហិកតា ដោយទទួលបានទិន្នផលជាមធ្យម ៣,៦៨០តោន/ហិកតា។ ចំពោះការដាំដុះស្រូវរដូវវស្សាក៏មានសន្ទុះលឿនគួរជាទីមោទនៈ ថ្វីត្បិតត្រូវជួបនឹងគ្រោះរាំងស្ងួតក្នុងចន្លោះចាប់ពីពាក់កណ្តាលខែកក្កដា រហូតដល់ដើមខែកញ្ញា ដែលបង្កការប៉ះពាល់ដល់សំណាប សន្ទូង និងស្រូវពង្រោះយ៉ាងច្រើនក៏ដោយ។ គិតត្រឹមថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ នេះ យើងសម្រេចស្ទូង-ព្រោះបានចំនួន ២.៥៥៥.៦៧៧ ហិកតា ស្មើនឹង១០៦,៥០% នៃផែនការ ២.៣៩៩.៦៣៧ ហិកតា លឿនជាងឆ្នាំមុនចំនួន ៦២.០៥៥ ហិកតា បើប្រៀបធៀបរយៈពេលដូចគ្នា។

ទន្ទឹមនឹងលទ្ធផលខាងលើ ដំណាំស្រូវរដូវវស្សានៅតាមបណ្តាខេត្តមួយចំនួន ត្រូវទទួលរងនូវគ្រោះទឹកជំនន់ជាបន្តបន្ទាប់ ហើយថ្មីៗនេះទៀត ក៏ត្រូវទទួលរងនូវបាតុភូតគ្រោះធម្មជាតិបង្កឡើងដោយទឹកជំនន់ទឹកភ្លៀងពីប៉ែកខាងលើ ដែលគិតត្រឹមថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ បានបង្កការប៉ះពាល់លើផ្ទៃដីសន្ទូង និងស្រូវពង្រោះចំនួន ២៨៦.៩២០ ហិកតា បណ្តាលឲ្យមានការខូចខាតចំនួន២៧.៧៩០ហិកតា។ គ្រោះធម្មជាតិនេះក៏នឹងអាចកើតមាននៅពេលដ៏ខ្លីខាងមុខ ដែលយើងមិនអាចមើលរំលងបាន ជាពិសេសការហក់ឡើងយ៉ាងគំហុកជាថ្មីទៀតនៃទឹកជំនន់ទន្លេមេគង្គស្របពេលមានទឹកជំនន់ទឹកភ្លៀងនៅប៉ែកខាងលើ។

ក្នុងគោលបំណងធានាបានសន្តិសុខស្បៀង និងឈានទៅសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយគ្រោះមហន្តរាយលើអាយុជីវិត សុខភាព និងផលិតកម្មសត្វ ពិសេសកុំឲ្យកើតមានការផ្ទុះជំងឺឆ្លងរាលដាលសត្វនាពេលខាងមុខនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់គ្រប់អង្គភាពបច្ចេកទេសក្រោមឱវាទនិងមន្ទីរកសិកម្មរាជធានី ខេត្ត ទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តនូវវិធានការចាំបាច់និងបន្ទាន់មួយចំនួនដូចខាងក្រោមៈ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣ ២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

១. ត្រូវតាមដានជាប្រចាំនូវស្ថានភាពឧតុនិយមនិងចាត់មន្ត្រីចុះវាយតម្លៃផលប៉ះពាល់ និងការខូចខាតជាបណ្ដើរៗ ដើម្បីទទួលបានតួលេខពិតប្រាកដ ដោយក្ដាប់ឲ្យបានទីតាំងនិងស្ថានភាពភូមិសាស្ត្រដែលមានលទ្ធភាពអាចស្ដារនូវការខូចខាតបាន។

២. ត្រូវពិនិត្យឡើងវិញនូវសន្និធិស្រូវពូជដែលមានតាមបណ្ដាខេត្តនីមួយៗទាំងបរិមាណនិងគុណភាព ហើយត្រូវត្រៀមលក្ខណៈជាស្រេចសម្រាប់កិច្ចអន្តរាគមន៍ស្ដារការខូចខាតឡើងវិញនៅពេលខាងមុខតាមស្ថានភាពភូមិសាស្ត្រជាក់ស្ដែង។

៣. ត្រូវសិក្សារកទីតាំងនិងលទ្ធភាពក្នុងការរៀបចំធ្វើថ្នាលសំណាបរួមជាពិសេសថ្នាលដាប៉ុកដើម្បីចែកជូនកសិករធ្វើការដកស្ទូងបានទាន់ពេលវេលានៅពេលទឹកជំនន់ចាប់ផ្ដើមស្រកនិងត្រូវបំផុសកសិករឲ្យស្ដារការខូចខាតនេះ ដោយធ្វើស្រែសន្ទូងដែលចំណេញទាំងពេលវេលា ទាំងបរិមាណគ្រាប់ពូជ (ប្រើគ្រាប់ពូជតិច) ទទួលបានទិន្នផលខ្ពស់និងទាន់រដូវកាលនៅពេលទឹកស្រកទៅវិញ។

៤. ត្រូវពិនិត្យលទ្ធភាពនិងត្រៀមលក្ខណៈផ្ដល់ពូជដំណាំផ្សេងទៀត (ដូចជា ឪឡឹក ពោត សណ្ដែក បន្លែ ដំឡូងជាដើម) ដែលត្រូវការទឹកតិចជាងដំណាំស្រូវជូនកសិករនៅមូលដ្ឋានណាដែលទទួលរងការខូចខាតពិសេសតាមភូមិសាស្ត្រដែលមានស្ថានភាពមិនសមស្របនឹងការធ្វើស្រែឡើងវិញ ដើម្បីស្ដារការខូចខាត និងធានាបាននូវសន្តិសុខស្បៀងជូនប្រជាពលរដ្ឋ។

៥. ត្រូវជំរុញការណែនាំដល់បងប្អូនកសិករឲ្យបង្កើនការថែទាំដំណាំស្រូវ ដែលមិនរងការខូចខាតដោយត្រូវកម្ចាត់ស្មៅ បំប៉នដី និងទប់ស្កាត់ពីការបំផ្លាញរបស់សត្វចង្រៃនិងជំងឺផ្សេងៗ។

៦. នៅពេលទឹកចាប់ផ្ដើមស្រក ត្រូវចលនាប្រមូលកម្លាំងប្រជាកសិករឲ្យរួបរួមគ្នាធ្វើការជួសជុល ឬលើកភ្លឺឡើងវិញដើម្បីរក្សាទឹកទុកក្នុងស្រែឲ្យបានគត់មត់ ចៀសវាងការកាប់ភ្លឺស្រែដាក់ទ្រូឬលប ដែលបណ្ដាលឲ្យបាត់បង់ទឹកអស់ពីស្រែ។

៧. ត្រូវពិនិត្យលទ្ធភាពជាក់ស្ដែងនូវតំបន់ដែលមានប្រភពទឹកសម្រាប់ស្រោចស្រព ដើម្បីកំណត់ឲ្យបានច្បាស់ពីទីតាំងនិងផ្ទៃដីដែលអាចធានាបានការស្រោចស្រពនិងស្ដារឡើងវិញ។

៨. ត្រូវចុះអប់រំបណ្ដុះបណ្ដាលបច្ចេកទេសដាំដុះដល់ប្រជាកសិករដើម្បីធានាការបង្កើនទិន្នផលឲ្យបានខ្ពស់ជាអតិបរមា និងមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។

៩. ត្រូវបំផុសប្រជាកសិករឲ្យជំរុញការអនុវត្តផលិតកម្មផ្សេងៗបន្ថែមទៀត តាមស្ថានភាពជាក់ស្ដែងក្នុងមូលដ្ឋាននីមួយៗដូចជាការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី និងមុខរបរបង្កើនប្រាក់ចំណូលដ៏ទៃទៀត។

១០. បន្តចុះពិនិត្យ តាមដាន ស្រាវជ្រាវសត្វល្អិត ងាប់ ដើម្បីមានវិធានការសង្គ្រោះនិងចាត់វិធានការបសុពេទ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព។

១១. បន្តការអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យបង្កើនការថែទាំ ផ្តល់ចំណី ទឹក ធ្វើជីវសុវត្ថិភាពសត្វ។ បំបែកសត្វឈឺពីសត្វជា ករណីមានផ្ទុះជំងឺ ធ្វើការពិនិត្យនិងព្យាបាលបន្ទាន់។

១២. រាយការណ៍ជាប្រចាំអំពីផលប៉ះពាល់អាយុជីវិត សុខភាពសត្វ និងអំពីស្ថានភាពជំងឺជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានវិធានការដោះស្រាយ។

១៣. ជំរុញនិងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ចូលរួមស្តារនិងដាំដំណាំចំណីសត្វឡើងវិញ និងត្រៀមពូជស្មៅដើម្បីចែកជូនប្រជាពលរដ្ឋសម្រាប់ដាំក្រោយពេលទឹកស្រកព្រមទាំងជំរុញនិងលើកទឹកចិត្តប្រជាពលរដ្ឋចិញ្ចឹមសត្វឡើងវិញ។

១៤. ត្រៀមចាក់ថ្នាំបង្ការជំងឺសត្វនៅតាមតំបន់ដែលចាំបាច់ ចុះពិនិត្យនិងព្យាបាលសត្វឈឺ និងត្រៀមអន្តរាគមន៍ការពារជំងឺឆ្លងរាលដាលសត្វ ករណីចាំបាច់រាយការណ៍តាមបណ្តាញផ្តល់ព័ត៌មានទាន់ហេតុការណ៍ដែលមានទូរស័ព្ទលេខ (០១២) ៨៣៣ ៧៩៥ (០១២) ២១៤ ៩៧០ ១២៨៧ និង ១២៨៩ ដើម្បីមានវិធានការទាន់ពេលវេលា។

ដើម្បីអនុវត្តការងារមានប្រសិទ្ធភាពខ្ពស់ អង្គភាពថ្នាក់កណ្តាល និងមូលដ្ឋានរាជធានី ខេត្ត គ្រប់ជាន់ថ្នាក់ត្រូវម្ចាស់ការបន្តយកចិត្តទុកដាក់តាមដានសភាពការណ៍និងជំរុញការងារផលិតកម្មជាប្រចាំព្រមទាំងរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីដោះស្រាយបញ្ហានិងការលំបាកផ្សេងៗជាមួយកសិករ ហើយរាយការណ៍អំពីវឌ្ឍនភាព និងការប្រឈមបានទាន់ពេលវេលា។

ទទួលបានសារាចរណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគ្រប់មន្ទីរកសិកម្មរាជធានី-ខេត្ត ត្រូវសហការឱ្យបានល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អនុវត្តការណែនាំនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ១០ ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត.អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់
- គ្រប់សាលារាជធានី-ខេត្ត

" ដើម្បីជូនជ្រាប "

- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្មរាជធានី-ខេត្ត

# សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ឯកឧត្តម បណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញទទួលជួបឯកឧត្តម KEVIN CHOEK ឯកអគ្គរដ្ឋទូតសឹង្ហបុរី នៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ការអញ្ជើញទទួលជួបលោកជំទាវឯកអគ្គរដ្ឋទូតសាធារណៈរដ្ឋប្រជាមានិតចិន នៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ការអញ្ជើញទទួលជួបឯកឧត្តម Philip Calvert ឯកអគ្គរដ្ឋទូតកាណាដា នៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ការអញ្ជើញទទួលជួបឯកឧត្តម Yuji Kumamaru ឯកអគ្គរដ្ឋទូតជប៉ុន នៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ការអញ្ជើញទទួលជួបឯកឧត្តម Eric Sidgwick នាយកប្រចាំប្រទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី(ADB) នៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ការអនុញ្ញាតឲ្យគណៈប្រតិភូចិន ខេត្តសាន់ទុងចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ការអញ្ជើញជាអធិបតីភាពក្នុងពិធីបើកការដ្ឋានសាងសង់មន្ទីរពិសោធន៍ នៅសាលាជាតិ
កសិកម្មព្រែកលៀប




សកម្មភាពជួបសំណេះសំណាលជាមួយប្រជាកសិករ និងពិនិត្យស្ថានភាពសត្វនៅគ្រាមានទឹកជំនន់
នៅខេត្តកណ្តាល




ការពិនិត្យស្ថានភាពទឹកជំនន់ និងវាយតម្លៃផលប៉ះពាល់ ផលដំណាំរបស់ប្រជាកសិករដោយទឹកជំនន់
នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល





ឯកឧត្តម **ឌឹម តឹមសា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតី
ពិធីប្រជុំបូកសរុប និងវាយតម្លៃផលប៉ះពាល់ដោយទឹកជំនន់លើសត្វ និងផលិតកម្មសត្វ ឆ្នាំ២០១៣
និងវិធានការបសុពេទ្យនៅពេលទឹកសម្រក នៅនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល





ឯកឧត្តម **ម៉ម អំណត់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះពិនិត្យ
ស្ថានភាពការងារបង្កបង្កើនផលស្រូវ ចែកពូជស្មៅចំណីសត្វជូនប្រជាកសិករ នៅខេត្តកំពង់ធំ



ការចុះពិនិត្យស្ថានភាពការងារបង្កបង្កើនផលស្រូវ
និងវាយតម្លៃផលប៉ះពាល់ ផលដំណាំរបស់ប្រជា
កសិករដោយទឹកជំនន់នៅខេតពោធិសាត់



ការចុះពិនិត្យស្ថានភាពការងារបង្កបង្កើនផលស្រូវ
និងវាយតម្លៃផលប៉ះពាល់ ផលដំណាំរបស់ប្រជាក
សិករដោយទឹកជំនន់នៅខេត្តបាត់ដំបង





លោកជំទាវ **ហោ ម៉ាលីន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីគ្រងពាលីបើកកាដ្ឋានសាងសង់មន្ទីរពិសោធន៍ នៅសាលាជាតិកសិកម្មព្រែកលៀប និងពិធីតែងតាំងក្រុមប្រឹក្សាភិបាល សាកលវិទ្យាល័យភូមិន្ទកសិកម្ម អាណត្តិទី៤ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម





ឯកឧត្តម **ចាន់ សុវណ្ណ** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះពិនិត្យការទុកដាក់ពូជស្រូវ និងព្រោះគ្រាប់ស្រូវលើថ្នាលដាកប៉ុក នៅខេត្តព្រៃវែង





ឯកឧត្តម **តង់ ចាន់** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចែកសម្ភារបសុពេទ្យក្នុងពិធីប្រជុំបូកសរុប និងវាយតម្លៃផលប៉ះពាល់ដោយទឹកជំនន់លើសត្វ និងផលិតកម្មសត្វ ឆ្នាំ២០១៣ និងវិធានការបសុពេទ្យនៅពេលទឹកសម្រក នៅនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និងពូជជ្រូកនៅខេត្តព្រះសីហនុ



# ពូជស្រូវទាំង ១០

៙ ជ្រើសរើសពូជស្រូវប្រសព្វ ពូជស្រូវទាំង១០បានណែនាំ
បើអនុវត្តតាមលំនាំ ទិន្នផលគ្រប់គ្រាន់តាមផ្លូវការ។

៙ សែនពិដោរ ស្រូវពូជក្រអូប អ៊ីអ៊ែជាពូជឆាប់ចេញផ្កា
រំដួលរមៀតក៏អច្ឆារ្យ រំដេញ ផលសារ នាំចេញបាន។

៙ ផ្កាច័ន្ទសែនសរ និងរាំងជ័យ បានផលប្រពៃលើទីផ្សា
ខា៤ ខា៦ នោះផងណា គុណភាពស្តង់ដាតម្លៃខ្ពស់។

៙ ពូជស្រូវទាំង១០ បានបែងចែក ទិន្នផលជាផ្នែកតាមកម្រិត
ជាអង្ករវែងប្រណិត បាយទន់ឆ្ងាញ់ពិតក្លិនប្រហើរ។

៙ ពូជស្រូវទាំង១០មានគុណភាព នាំមកនូវលាភជូនខេមរា
អភិវឌ្ឍន៍សេដ្ឋកិច្ចដ៏អស្ចារ្យ ចម្រើនថ្លៃថ្លា ជាតិរុងរឿង។

*និពន្ធដោយៈ និស្សិតវិទ្យាសាស្ត្រកសិកម្ម*
*ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម*










នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម